# វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រ ទីក្រុងបៃតង

**ឯកសារណែនាំពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង**

**ខែ សីហា ឆ្នាំ ២០១៦**

សហការរៀបចំដោយ៖ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) នៃរាជរដ្ឋាភិបាលកម្ពុជា (RGC) វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) និង មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងផ្នែកបរិស្ថាន (ICEM)



# អារម្ភកថា

ខ្ញុំសូមអបអរសាទរ និងកោតសរសើរខ្ពស់ចំពោះក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ដែលបានបង្កើតនូវវិធីសាស្ត្រសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងនេះឡើង ដែលនឹងត្រូវប្រើប្រាស់ជាឯកសារបង្ហាញផ្លូវមួយសម្រាប់អ្នកធ្វើគោលនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលការណ៍អភិវឌ្ឍន៍ទីប្រជុំជនបៃតងប្រកបដោយនិរន្តរភាព និងគ្រប់ជ្រុងជ្រោយ ។

ការអភិវឌ្ឍទីក្រុងបៃតង និងប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា គឺជាគោលនយោបាយអាទិភាពដ៏សំខាន់មួយរបស់ ក.ជ.អ.ច. ។ ទីក្រុងគឺជាចំណុចកណ្តាលនៃសកម្មភាពសេដ្ឋកិច្ច ដែលអាចបង្កើតការងារ និងជំរុញកំណើនផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។ ទីក្រុងក៏ជាចំណុចស្នូលនៃការប្រើប្រាស់ធនធាន ដូចជាថាមពល ទឹក និងធនធានធម្មជាតិផ្សេងៗទៀតដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្ម ដើម្បីជាកម្លាំងចលករនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រទេសកម្ពុជាមានកាលានុវត្តភាពក្នុងការជំរុញបន្ថែមការអភិវឌ្ឍរបស់ខ្លួនតាមរយៈការអភិវឌ្ឍទីក្រុង ពង្រីកកាលានុវត្តភាពនៅក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ព្រមទាំងវិស័យអចលនទ្រព្យ។

ទន្ទឹមនឹងនេះ ទីក្រុងរបស់យើងមានការរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលធ្វើឱ្យធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធនៅទីក្រុងកំពុងតែរងសម្ពាធយ៉ាងខ្លាំង។ ហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលចាំបាច់ ដូចជាប្រព័ន្ធផ្គត់ផ្គង់ទឹក ការរក្សាអនាម័យទីក្រុង ការគ្រប់គ្រងកាកសំណល់ ប្រព័ន្ធដឹកជញ្ជូន និងថាមពល គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងអត្រានៃការរីកលូតលាស់យ៉ាងឆាប់រហ័សរបស់ទីក្រុង នៅឡើយ។ ការរងសម្ពាធរបស់ទីក្រុង និងទីប្រជុំជន នឹងមានកាន់តែខ្លាំងឡើងដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ការប៉ាន់ប្រមាណនៃការកើនឡើងកម្តៅសីតុណ្ហភាពមធ្យម និងហេតុការណ៍អាកាសធាតុខុសធម្មតា អាចជាកត្តាមួយដែលជំរុញឱ្យអ្នករស់នៅក្នុងទីក្រុងប្រើប្រាស់ថាមពលកាន់តែច្រើន ក្នុងការឆ្លើយតបទៅនឹងបញ្ហាកម្តៅកើនឡើងនេះ ក៏ដូចជាសម្រាប់គ្រប់គ្រងការលិចទឹកក្នុងទីក្រុង និងប្រព័ន្ធបង្ហូរទឹកចេញនៅក្នុងរដូវវស្សា។

បើសិនយើងមានការគ្រប់គ្រងបានល្អ ទីក្រុងរបស់យើងក៏នឹងផ្តល់កាលានុវត្តភាពយ៉ាងច្រើនក្នុងការទប់ស្កាត់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) បានផងដែរ។ ទីក្រុងក៏ជាបរិបទសមរម្យមួយដែលយើងអាចមើលឃើញពីភាពច្នៃប្រឌិតថ្មីៗជាច្រើនដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ ការប្រើយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីក្រុងឱ្យមានភាពបៃតង គឺជាកត្តាដ៏សំខាន់សម្រាប់ទីក្រុង និងទីប្រជុំជននានានៅក្នុងប្រទេសកម្ពុជា ដើម្បីឱ្យការរស់នៅក្នុងតំបន់ទីក្រុងប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ធានាឱ្យមានថាមពលគ្រប់គ្រាន់និងសុវត្ថិភាពនៃប្រព័ន្ធដឹកជញ្ជូន និងការជំរុញឱ្យមានការធ្វើពាណិជ្ជកម្មបៃតង។

ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារ នាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍

ដោយចីរភាព និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ក្នុងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត រៀបចំចងក្រងនូវឯកសារដ៏មានសារៈសំខាន់នេះឡើង។ ខ្ញុំសូមលើកទឹកចិត្ត និងសូមជំរុញឱ្យអ្នកធ្វើគោលនយោបាយជាតិនានាប្រើប្រាស់នូវឯកសារវិធីសាស្ត្រនេះឱ្យមានប្រសិទ្ធភាព ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងសម្រាប់ទីក្រុងផ្សេងទៀតនៅព្រះរាជាណាចក្រកម្ពុជា ក្រោមការជួយគាំទ្រពីបណ្ដាអង្គការដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងពីបណ្ដាអ្នកសិក្សាស្រាវជ្រាវ ។

**សាយ សំអាល់**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

# សេចក្តីថ្លែងអំណរគុណ

វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង បានរៀបចំឡើងដោយមានការគាំទ្រផ្នែកបច្ចេកទេសពីមជ្ឈមណ្ឌលអន្តរជាតិគ្រប់គ្រងបរិស្ថាន (ICEM) ហើយវាក៏ជាលទ្ធផលមួយនៃកម្មវិធីអភិវឌ្ឍន៍ទីប្រជុំជនបៃតង តំណាក់កាលទី ១ ដែលជាកម្មវិធីគ្រប់គ្រងរួមគ្នាដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និង វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដែលមានរាយនាមដូចខាងក្រោមនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងគាំទ្រដល់ដំណើរការសម្របសម្រួលលើការរៀបចំវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងនេះ ៖

| | |
|---|---|
| ឯកឧត្តម ទិន ពន្លក | អគ្គលេខាធិការ |
| ឯកឧត្តម កែន សេរីរដ្ឋា | អគ្គលេខាធិការរង |
| លោក តាំង ម៉េងអៀង | ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង |
| លោក យុន សុវិជា | អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង |
| លោក ចាន់ ពុទ្ធារ័ត្ន | មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង |
| លោក សាត ស៊ីតាក់ | មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង |

ក្រុមបុគ្គលិករបស់វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលគ្រប់គ្រងលើការរៀបចំវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងរួមមាន៖

| | |
|---|---|
| Adam Ward | ប្រធានតំណាង GGGI ប្រចាំប្រទេសកម្ពុជា និងវៀតណាម |
| Fiona Lord | អនុប្រធានតំណាង GGGI ប្រចាំកម្ពុជា |
| Pheakdey Heng | អ្នកវិភាគគោលនយោបាយជាន់ខ្ពស់ |
| James Seong-Cheol Kang | អ្នកឯកទេសប្រព័ន្ធដឹកជញ្ជូន |
| Okju Jeong | អ្នកឯកទេសអភិវឌ្ឍន៍ទីប្រជុំជន |

ក្រុមការងារគម្រោងមកពី ICEM ដែលបានផ្តល់បច្ចេកទេសបង្កើតវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង មានសមាជិកដូចខាងក្រោម៖

| | |
|---|---|
| Anthony Gad Bigio | ប្រធានក្រុម និងជាអ្នកឯកទេសអភិវឌ្ឍន៍ទីប្រជុំជនបៃតង |
| John Sawdon | អ្នកអភិវឌ្ឍសេដ្ឋកិច្ចបៃតង |
| Wayne Stone | អ្នកឯកទេសភាពងាយរងគ្រោះនិងភាពធន់ទីប្រជុំជន |
| Sok-Tharath Chreung | អ្នកឯកទេសវិនិយោគ និងហិរញ្ញវត្ថុបៃតង |
| Vin Spoann | អ្នកឯកទេសហេដ្ឋារចនាសម្ព័ន្ធបៃតង |
| Kong Pagnarith | អ្នកឯកទេសថាមពលបៃតង |
| Chhun Bunlong | អ្នកឯកទេសផែនទីទីប្រជុំជន |
| Nick Beresnev | អ្នកគ្រប់គ្រងគម្រោង |
| Nguyen Thi Phuong Thao | អ្នកសម្របសម្រួលគម្រោង |

# អក្សរកាត់

| | |
|---|---|
| BAU | ការព្យាករតាមទម្លាប់ធម្មតា |
| CBA | ការវិភាគលើផលចំណេញ ធៀបជាមួយនិងការចំណាយ |
| CEA | ការវិភាគទៅលើប្រសិទ្ធភាពនៃចំណាយ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GGGI | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| ICEM | មជ្ឈមណ្ឌលអន្តរជាតិគ្រប់គ្រងផ្នែកបរិស្ថាន |
| IRR | អត្រាការប្រាក់ ឬផលចំណេញដែលអាចទទួលបានពីការបណ្តាក់ទុនវិនិយោគក្នុងពេលបច្ចុប្បន្ន |
| LCDF | មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍន៍តិចតួច |
| LED | ប្រព័ន្ធបញ្ចេញបន្លឺប្រភេទ LED ( light-emitting diode ) |
| LEED | កម្មវិធីអន្តរជាតិស្តីពីវិញ្ញាបនបត្រស្តង់ដា ពីភាពដឹកនាំផ្នែករចនាសំណង់អគារដែលគិតគូរពីបរិស្ថាន និងការប្រើប្រាស់ថាមពល |
| MACC | ខ្សែកោង ដែលបង្ហាញពីការវិភាគជាតិការបូនតិច ក្នុងករណី BAU |
| MCA | ការវិភាគលក្ខខណ្ឌពហុវិនិច្ឆ័យ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoI | ក្រសួងមហាផ្ទៃ |
| NCDD | គណៈកម្មាការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NPV | តម្លៃពេលបច្ចុប្បន្ន |
| RGC | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| UNEP | កម្មវិធីបរិស្ថានសហប្រជាជាតិ |

# មាតិកា


សេចក្តីថ្លែងអំណរគុណ......iv

អក្សរកាត់......v

មាតិកា......vi

សេចក្តីផ្តើម......១

មូលន័យសង្ខេប......៣

**១. ការរៀបចំអភិបាលកិច្ច សម្រាប់ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង......៧**

**២. ការវាយតម្លៃលើទិន្នន័យមូលដ្ឋានក្នុងបរិបទទីប្រជុំជន......១១**

២.១. កំណើនប្រជាសាស្ត្រ ក្នុងពេលបច្ចុប្បន្ន និងអនាគត......១១

២.២. ទិន្នន័យមូលដ្ឋានផ្នែកសេដ្ឋកិច្ច និងនិន្នាការពេលអនាគត......១១

២.៣. បណ្តុំនៃការរស់នៅរបស់ប្រជាជនក្នុងសង្គម និងជនជាតិ និងរបាយនៃប្រាក់ចំណូល......១២

២.៤. អភិបាលកិច្ចសម្រាប់ការអភិវឌ្ឍទីប្រជុំជន និងហិរញ្ញវត្ថុរបស់សាលាក្រុង......១២

២.៥. ហានិភ័យធម្មជាតិ និងអាកាសធាតុមកលើទីក្រុង......១៤

២.៦. ស្ថានភាពបច្ចុប្បន្ននៃបរិស្ថានទីក្រុង និងផលប៉ះពាល់ពីការបំពុលបរិស្ថានមកលើសុខភាពសាធារណៈ១៤

**៣. ទស្សនៈវិស័យរួម នៃទីក្រុងបៃតង និងគោលដៅអភិវឌ្ឍន៍ក្រុង......១៦**

**៤. ការពិនិត្យឡើងវិញលើវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍទីក្រុងបៃតង......១៩**

៤.១ ការរៀបចំផែនការក្រុង......២០

៤.២. ភាពងាយរងគ្រោះនៃតំបន់ទីក្រុង......២១

៤.៣. ថាមពល......២១

៤.៤. គមនាគមន៍ (ដឹកជញ្ជូន)......២២

៤.៥. សំណង់បរិស្ថាន......២២

៤.៦. ផ្នែកផលិតកម្ម (កម្មន្តសាល)......២៣

៤.៧ ការគ្រប់គ្រងសំណល់រឹង (សំរាម)......២៣

៤.៨. ទីធ្លាសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌......២៤

**៥. ការកំណត់គោលដៅអភិវឌ្ឍន៍បៃតង និងសកម្មភាពអាទិភាព សម្រាប់វិស័យនគរូបនីយកម្មសំខាន់ៗ........២៥**

**៦. ការកំណត់នូវគម្រោងវិនិយោគអភិវឌ្ឍន៍ទីក្រុងបៃតង........................................................................២៨**

៦.១ ឧទាហរណ៍នៃការរៀបចំផែនការទីប្រជុំជនគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក.......២៩

៦.២ ឧទាហរណ៍ភាពរងគ្រោះរបស់ទីប្រជុំជនបៃតង និងផលប្រយោជន៍ដែលរំពឹងទុក ................................៣១

៦.៣ ឧទាហរណ៍ លើវិស័យថាមពល នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក................ ៣២

៦.៤ ឧទាហរណ៍លើវិស័យគមនាគមន៍ នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក ............. ៣៣

៦.៥ ឧទាហរណ៍លើវិស័យសំណង់បរិស្ថាននៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក..........៣៥

៦.៦ ឧទាហរណ៍លើវិស័យផលិតកម្ម (កម្មន្តសាល) នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍រំពឹងទុក...៣៦

៦.៧ ឧទាហរណ៍លើវិស័យគ្រប់គ្រងសំណល់រឹងនៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍រំពឹងទុក.......... ៣៧

៦.៨ ឧទាហរណ៍លើទីធ្លាសាធារណៈ បេតិកភណ្ឌវប្បធម៌ នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍រំពឹងទុក ..........................................................................................................................................៣៨

**៧. កំណត់អាទិភាពគម្រោងអភិវឌ្ឍន៍ទីក្រុងបៃតង ..........................................................................៤០**

**៨. ចំហាកនៃការអភិវឌ្ឍបៃតងនៅទីប្រជុំជន........................................................................................៤៧**

៨.១ បារ៉ាម៉ែត្រសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្រសម្រាប់ការបង្កើតចំហាក.........................................៤៧

៨.២ ការកំណត់និយមន័យលើ ការវិភាគចំហាក ................................................................................. ៤៨

៨.៣ ប្រភពព័ត៌មានបន្ថែម.................................................................................................................. ៥០

**៩. ការរៀបចំគម្រោងវិនិយោគអាទិភាពទីក្រុងបៃតង ............................................................................ ៥១**

៩.១ ការវិភាគពីស្ថានភាពហិរញ្ញវត្ថុ....................................................................................................... ៥១

៩.២ ការវិភាគពីការចំណាយ និងចំណូល (Cost-Benefit Analysis - CBA)............................................ ៥១

៩.៣ ការវិភាគពីប្រសិទ្ធភាពចំណាយ (Cost-Effectiveness Analysis - CEA)..........................................៥២

៩.៤ ខ្សែកោងតម្លៃ ដែលបង្ហាញពីការវិភាគជាតិការបូនតិច (MACC) ......................................................៥២

៩.៥ ខ្សែកោងតម្លៃនៃការបន្សាំ ...............................................................................................................៥៣

៩.៦ និយមន័យ លទ្ធភាពអាចអនុវត្តបាននៃគម្រោងអាទិភាព ............................................................... ៥៤

**១០. ការអនុវត្តការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង...............................................................៥៧**

# សេចក្តីផ្តើម

វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ត្រូវបានបង្កើតឡើងជាវិធានណែនាំមួយសម្រាប់អ្នកធ្វើគោលនយោបាយនៅក្នុងប្រទេសកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយនឹងផែនទីបង្ហាញផ្លូវសម្រាប់ការរៀបចំ និងអនុវត្តន៍គោលការណ៍អភិវឌ្ឍន៍បៃតងគ្រប់ជ្រុងជ្រោយ និងប្រកបដោយចីរភាព ទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីប្រជុំជន។ ការអភិវឌ្ឍបៃតងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺជាគោលដៅដ៏មានសារៈសំខាន់ និងជាដំណើរការដែលអាចផ្លាស់ប្តូរស្ថានភាពដែលកំពុងអនុវត្តន៍តាមទម្លាប់ធម្មតាក្នុងទីក្រុងបច្ចុប្បន្ន (ចំហាក BAU) ដើម្បីឆ្ពោះទៅរកចំហាកទីក្រុងដែលមានផាសុខភាពនៅក្នុងការរស់នៅ (ដូចមានបង្ហាញក្នុងរូបទី១ ខាងក្រោម)។

*រូបភាព១៖ ពីការធ្វើតាមទំលាប់ទៅទីក្រុងដែលអាចរស់នៅបាន*




*ប្រភព៖* Sandhu and Singru (2014) Enabling Green cities: An Operation Framework for Integrated Urban Development in Southeast Asia, Asian Development Bank Southeast Asia Working Paper Series

វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង គឺជាលទ្ធផលមួយនៃ**កម្មវិធីអភិវឌ្ឍន៍ទីប្រជុំជនបៃតងក្នុងប្រទេសកម្ពុជា តំណាក់កាលទីមួយ**។ កម្មវិធីនេះបាននឹងកំពុងអនុវត្តដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ជាតំណាង ជាមួយនិងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI)។

**ក.ជ.អ.ច.** គឺជាស្ថាប័នរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវលើការជំរុញការអភិវឌ្ឍជាតិក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។ ស្ថាប័ននេះមានការចូលរួមពីគ្រប់ក្រសួងនានាដែលពាក់ព័ន្ធដើម្បីជាបណ្ដាញរួមមួយ។ ស្ថាប័ននេះធ្វើការសម្របសម្រួលលើការផ្លាស់ប្ដូរបទពិសោធន៍ និងទំនាក់ទំនងរវាងអង្គភាពរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្រេចឱ្យបាននូវយុទ្ធសាស្ត្រ និងកម្មវិធីរួមបញ្ចូលគ្នាមួយ ដែលមានគោលដៅរួមគឺនិរន្តរភាព។

**អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.** ដែលបច្ចុប្បន្នមានទីតាំងនៅក្នុងក្រសួងបរិស្ថាន មានតួនាទីជំរុញការអភិវឌ្ឍទីប្រជុំជនបៃតងទៅក្នុងអាណត្តិនៃការងាររបស់ស្ថាប័នមួយនេះ។ អគ្គលេខាធិការដ្ឋាន មានគោលបំណងជួយគាំទ្រអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានទូទាំងប្រទេសលើការអភិវឌ្ឍផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីប្រជុំជនបៃតងតាមមូលដ្ឋាន។ ជំនួយគាំទ្រនេះឆ្លើយតបទៅនឹងតួនាទីយ៉ាងសំខាន់ដែលទីក្រុងនិងតំបន់កណ្ដាល នៃទីប្រជុំជនផ្សេងទៀត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសុខុមាលភាពប្រជាជនរបស់ខ្លួនក្នុងប្រទេសកម្ពុជា។

**GGGI** គឺជាអង្គការអន្តរជាតិដែលមានទីតាំងជាមូលដ្ឋាននៅទីក្រុងសេអូល (Seoul) ប្រទេសកូរ៉េ ដែលគាំទ្រដោយដៃគូជាតិ និងពហុភាគីជាច្រើន។ វិទ្យាស្ថាននេះមានអន្តរាគមន៍ជាយុទ្ធសាស្ត្រលើវិស័យចំនួន៤ រួមមានថាមពល ការអភិវឌ្ឍទីក្រុងបៃតង ការប្រើប្រាស់ដីធ្លី និងវិស័យទឹក ហើយប្រទេសកម្ពុជាគឺជាសមាជិកស្ថាបនិកមួយនៃ GGGI។ GGGI ក៏មានការិយាល័យរបស់ខ្លួននៅទីក្រុងភ្នំពេញផងដែរ។

# មូលន័យសង្ខេប

**វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង** ជាការណែនាំជាជំហានៗសម្រាប់មន្ត្រីសាលារាជធានី ស្រុក/ខ័ណ្ឌ និងឃុំ/សង្កាត់ ព្រមទាំងក្រសួងពាក់ព័ន្ធនានាទូទាំងប្រទេសកម្ពុជា ដើម្បីការចាប់ផ្តើមនៃដំណើរការ នៃការកែប្រែទីក្រុងរបស់ពួកគេទៅជាទីក្រុងដែលមានការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាពប្រសើជាងមុន ក្រោមជំនួយគាំទ្រពី ក.ជ.អ.ច. និង GGGI។ វិធីសាស្ត្រនេះត្រូវបានរៀបចំជា ១០ ជំហានសំខាន់ៗ ដូចមានបង្ហាញក្នុងសេចក្តីសង្ខេបខាងក្រោម។ ជំហាននីមួយៗនឹងត្រូវបានបង្ហាញលម្អិតនៅតាមជំពូកនៃរបាយការណ៍នេះ។

## ជំហានទី១៖ ការរៀបចំអភិបាលកិច្ចសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង

ផែនការទីក្រុងបៃតង គឺជាទំនួលខុសត្រូវបឋមរបស់ស្ថាប័នរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ទៅតាមកម្រិតទំហំផ្សេងៗគ្នា។ ស្ថានប័នរដ្ឋាភិបាលទាំងនេះ នឹងធ្វើការអភិវឌ្ឍផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានទាំងអស់ និងដោយមានការគាំទ្រពី ក.ជ.អ.ច. និងអ្នកជំនាញការបច្ចេកទេសទៅតាមតម្រូវការ។ ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង គឺជាសមិទ្ធផលដែលចេញពីដំណើរការពិគ្រោះយោបល់ ដែលត្រូវតែធ្វើឡើងតាំងពីចំណុចចាប់ផ្តើម ហើយបន្តរហូតដល់ជំហានដែលត្រូវបានកំណត់ច្បាស់លាស់។ លេខាធិការដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ ដែលត្រូវបានចាត់តាំងដោយស្ថានប័នរដ្ឋាភិបាល នឹងមានការទទួលខុសត្រូវបង្កើតក្រុមការងារបច្ចេកទេសរៀបចំផែនការទីក្រុងបៃតង។ ក្រុមការងារនេះ នឹងធ្វើការងារលើការសិក្សាស្រាវជ្រាវស្វែងរកពត៌មានជាក់ស្តែង សិក្សាបច្ចេកទេស និងការវិភាគទៅតាមតម្រូវការ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងដែលបង្កើតឡើង នឹងត្រូវយកទៅបង្ហាញ និងស្នើសុំការអនុម័តពីភាគីពាក់ព័ន្ធ និងពីវិស័យសាធារណៈ។

## ជំហានទី២៖ ការវាយតម្លៃជាមូលដ្ឋាននៃបរិបទទីប្រជុំជន ក្នុងស្ថានភាពបច្ចុប្បន្ន

ការវាយតម្លៃនេះ នឹងផ្តល់ជាការត្រួតពិនិត្យពេញលេញនូវស្ថានភាពជាក់ស្តែង នៃទីតាំងទីប្រជុំជនដែលជាគោលដៅ ដែលរួមមាន៖

- កំណើនប្រជាសាស្ត្រនាពេលបច្ចុប្បន្ន និងអនាគត
- ផែនការកំណត់ទីតាំង និងផែនការអភិវឌ្ឍន៍ទីប្រជុំជន
- សកម្មភាពសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ន នៅផ្នែកខាងក្នុង និងជុំវិញមជ្ឈមណ្ឌលទីប្រជុំជន
- ប្រភពធនធានហិរញ្ញវត្ថុនៃរាជធានី និងការផ្តល់ជាកញ្ចប់ថវិកា
- ការវាយតម្លៃលើហានិភ័យធម្មជាតិ និងកត្តាប្រឈមនៅទីប្រជុំជនផ្សេងទៀត
- ការពិនិត្យទៅលើចំហាកអាកាសធាតុនាពេលបច្ចុប្បន្ន និងអនាគត
- ការបំពុលបរិស្ថាន និងផលប៉ះពាល់របស់វាទៅលើសុខភាពសាធារណៈ និងធនធានធម្មជាតិ
- ជនជាតិភាគតិច និងការបញ្ចូលគ្នានៃសង្គមប្រជាជនទៅតាមតំបន់ភូមិសាស្ត្រ និង
- របាយប្រាក់ចំណូល

## ជំហានទី៣៖ ទស្សនវិស័យទីក្រុងបៃតង ទិសដៅ និងគោលដៅអភិវឌ្ឍន៍ទីប្រជុំជន

ការអភិវឌ្ឍបៃតង ផ្តល់នូវយុទ្ធសាស្ត្រដែលធានាការពង្រីកសេដ្ឋកិច្ច ប្រកបដោយចីរភាព ដោយគិតគូលើ

ការការពារបរិស្ថាន និងធានាឱ្យបាននូវការអភិវឌ្ឍន៍ដោយគិតគូពីផលប្រយោជន៍សង្គមគ្រប់ជ្រុងជ្រោយ។ ក្នុងលក្ខខណ្ឌទីប្រជុំជន ការអភិវឌ្ឍបៃតង ត្រូវបានកំណត់គោលដៅជាក់លាក់ទាក់ទង ទៅនឹងភាពធនទៅនឹងការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់ហានិភ័យធម្មជាតិ ប្រសិទ្ធភាពធនធាននិងថាមពល និងទាក់ទងនឹងការសន្សំសំចៃផ្សេងទៀត ភាពប្រសើរឡើងនិងការកើនឡើងសមភាពដែលទទួលបានសេវាកម្មទីប្រជុំជន និងសុខុមាលភាព ការកាត់បន្ថយភាពក្រីក្រនិងទីប្រជុំជនដែលមានការប្រកួតប្រជែង។ គោលដៅទាំងនេះ ចាំបាច់ត្រូវតែបានលើកឡើងពីចំណុចចាប់ផ្តើមនៃដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ដែលមានទំនាក់ទំនងជិតស្និតបំផុតទៅនឹងបរិបទមូលដ្ឋាន។

## ជំហានទី៤៖ ការពិនិត្យទៅលើវិស័យសំខាន់ៗនៃទីប្រជុំជន សម្រាប់ការអភិវឌ្ឍទីប្រជុំជនបៃតង

ផែនការអភិវឌ្ឍន៍ទីក្រុងបៃតង នឹងធ្វើការពិនិត្យទៅលើវិស័យដែលជាការព្រួយបារម្ភចម្បងៗ ចំនួន ៨ សម្រាប់ការអភិវឌ្ឍទីប្រជុំជន និងសុខុមាលភាពប្រជាជន៖ (១) ការរៀបចំផែនការទីប្រជុំជន (២) ភាពងាយរងគ្រោះទីប្រជុំជន (៣) ថាមពល (៤) ការដឹកជញ្ជូន (៥) សំណង់បរិស្ថាន (៦) ផលិតកម្ម (៧) ការគ្រប់គ្រងសំណល់រឹង និង(៨) ទីវាលសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌។ ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង នឹងបង្កើតនូវរបៀបដែលវិស័យនីមួយៗកំពុងតែអនុវត្តនាពេលបច្ចុប្បន្ន និងកំណត់ពីកត្តាដែលខ្វះខាត និងមិនមានដំណើរការល្អ និងការវិភាគចំហាកការព្យាករតាមទម្លាប់ធម្មតាសម្រាប់ថ្ងៃអនាគត (BAU) ដែលវិស័យនីមួយៗកំពុងតែប្រឈម ។

## ជំហានទី៥៖ ការបង្កើតគោលដៅ និងផែនការសកម្មភាព សម្រាប់ការអភិវឌ្ឍបៃតងក្នុងវិស័យសំខាន់ៗក្នុងទីប្រជុំជន

ទស្សនវិស័យដែលបានកំណត់សម្រាប់ទីក្រុងបៃតង (ជំហានទី៣) និងការពិនិត្យវិស័យប្រឈមទាំង៨ ក្នុងទីប្រជុំជន (ជំហានទី៤) នឹងអាចធ្វើឱ្យក្រុមការងាររៀបចំផែនការទីក្រុងបៃតង កំណត់បាននូវគោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងជាក់លាក់សម្រាប់វិស័យនីមួយៗ។ គោលដៅ និងផែនការសកម្មភាពទាំងនេះ នឹងត្រូវបានកំណត់ឡើងតាមរយៈដំណើរការនៃការចូលរួម នឹងជួយបង្កើតលទ្ធផលរំពឹងទុករួម សម្រាប់ការអនុវត្តវិស័យទាំងនោះក្នុងទស្សនវិស័យការអភិវឌ្ឍបៃតងក្នុងពេលអនាគត។ ការកំណត់គោលដៅ និងផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍបៃតងជាក់លាក់មួយចំនួនដែលនឹងកំណត់ឡើងក្នុងតំណាក់កាលនេះ គឺគ្រាន់តែជាការបង្ហាញផ្លូវដ៏សំខាន់មួយដែលធ្វើអោយស្រប និងផ្តល់អាទិភាពទៅលើកត្តាប្រឈមជាក់ស្តែងនៃតំបន់ទីប្រជុំជន។

## ជំហានទី៦៖ ការកំណត់ពីគម្រោងវិនិយោគអភិវឌ្ឍន៍ទីក្រុងបៃតងដែលមានសក្តានុពល

ការកែប្រែតំបន់ប្រជុំជនទៅជាតំបន់ទីប្រជុំជនមួយដែលមានលក្ខណៈបៃតង និងប្រកបដោយចីរភាពក្នុងពេលអនាគត គឺជាការងារដែលត្រូវធ្វើក្នុងរយៈពេលវែង។ តែទោះជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ក្នុងការកំណត់នូវគម្រោងវិនិយោគទីក្រុងបៃតងដែលមានសក្តានុពលខ្ពស់មួយចំនួនជាដំបូង សម្រាប់ការចាប់ផ្តើមនូវដំណើរការកែប្រែតំបន់ទីប្រជុំជនឱ្យមានលក្ខណៈបៃតង។ ដូច្នេះនៅក្នុងជំហាននេះ នឹងមានការរៀបចំជាបញ្ជីគម្រោងវិនិយោគ ដែលសមស្របសម្រាប់កិច្ចអន្តរាគមន៍ ដែលទាក់ទងនឹងការកំណត់នូវគោលដៅអភិវឌ្ឍន៍

បៃតង(ជំហានទី៥) ហើយផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលនឹងទទួលបានមកវិញពីគម្រោងទាំងនោះនឹងត្រូវមានការផ្ទៀងផ្ទាត់។ គម្រោងវិនិយោគទាំងនេះនឹងបែងចែកជា ៣ ក្រុមផ្សេងគ្នារួមមាន៖ (១) សកម្មភាព និងការវិនិយោគក្នុងរយៈពេលខ្លី (២) កំណែទម្រង់លើវិស័យគ្រប់ជ្រុងជ្រោយ និង(៣) ការកសាងសមត្ថភាព ដែលឆ្លើយតបទៅនឹងភាពខ្វះចន្លោះនៃចំណេះដឹង។ តារាងសម្រាប់ធ្វើការពិពណ៌នា និងវិភាគពីគម្រោងវិនិយោគបៃតង នឹងត្រូវបង្ហាញសម្រាប់ជាគំរូប្រើប្រាស់។

## ជំហានទី៧៖ ការកំណត់អាទិភាពគម្រោងវិនិយោគសម្រាប់ការអភិវឌ្ឍទីក្រុងបៃតង

ការរៀបចំជាបញ្ជីគម្រោងវិនិយោគ នឹងតម្រូវទៅតាមដំណើរការនៃការធ្វើចំណាត់ថ្នាក់អាទិភាព និងធ្វើការជ្រើសរើសគម្រោងដែលមានអាទិភាពមួយចំនួនតូច។ ការធ្វើចំណាត់ថ្នាក់អាទិភាព នឹងត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រពហុលក្ខណៈវិនិច្ឆ័យ (MCA) ដើម្បីជ្រើសរើសគម្រោងអាទិភាពដោយផ្អែកទៅលើផលប្រយោជន៍ដែលបានរំពឹងទុក និងសេចក្តីរំពឹងទុករបស់សាធារណៈជន។ លក្ខខណ្ឌវិនិច្ឆ័យ ១០ចំណុច ត្រូវបានស្នើសម្រាប់វិធីសាស្ត្រ MCA នេះ តែវាអាចត្រូវបានកែសម្រួលឱ្យស្របទៅតាមកាលៈទេសៈ និងស្ថានភាពនៅក្នុងតំបន់នោះ។ ក្របខ័ណ្ឌនៃវិធីសាស្ត្រពហុលក្ខណៈវិនិច្ឆ័យ MCA ដែលបានស្នើឡើង គឺរួមបញ្ចូលនូវការពន្យល់ពីអត្ថន័យ (ហេតុផល) នៃលក្ខខណ្ឌវិនិច្ឆ័យនីមួយៗ ជាមួយនឹងសេចក្តីណែនាំពីការដាក់ពិន្ទុ។ ដំណើរការនៃការកំណត់អាទិភាពគម្រោង និងការជ្រើសរើសសម្រាំង គឺមិនត្រូវមានភាពលំអៀង និងត្រូវមានតម្លាភាព និងមានការចូលរួមពីសារធារណៈជនតាមតែអាចធ្វើទៅបាន ហើយសម្ភារៈ និងលទ្ធផល នៃដំណើរការនេះគួរតែអាចទាញយកមកប្រើប្រាស់បានសម្រាប់សារធារណៈជន។

## ជំហានទី៨៖ ការវិភាគចំហាកនៃការអភិវឌ្ឍទីប្រជុំជនបៃតង

ដោយផ្អែកទៅលើជំហានទី ៣ ៤ ៥ និង ៦ ការបង្កើតជាចំហាកសម្រាប់ការអភិវឌ្ឍទីប្រជុំជនបៃតងត្រូវបានស្នើឱ្យមាន តាមរយៈការប្រមើរមើលពីការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងការវិវត្តនៃប្រជាសាស្ត្រ ជាមួយនឹងការវិភាគតាមវិស័យផ្សេងៗគ្នានៃទីប្រជុំជន ការវិភាគគោលដៅ គោលបំណង និងសកម្មភាពអាទិភាពសម្រាប់ការអភិវឌ្ឍបៃតង ព្រមជាមួយនឹងកិច្ចអន្តរាគមន៍នានានៃការអភិវឌ្ឍបៃតង។ នៅក្នុងវិធីសាស្ត្រនេះ ការវិភាគចំហាក ៣ប្រភេទ ត្រូវបានស្នើឱ្យមានដើម្បីបង្ហាញឱ្យឃើញពីលទ្ធភាពទទួលបានផលប្រយោជន៍ ដែលកើតចេញពីកិច្ចអន្តរាគមន៍លើផ្នែកអភិវឌ្ឍន៍បៃតងសកល និងបង្ហាញពីកម្រិតនៃការអនុវត្តរបស់ទីក្រុងនោះ នៅក្នុងអំឡុងពេលធ្វើផែនការរៀបចំក្រុង។ ចំហាកទាំង៣នេះរួមមាន ចំហាកសម្រាប់ការព្យាករតាមទម្លាប់ធម្មតា (BAU) ការអនុវត្តសាកល្បងលើការអភិវឌ្ឍបៃតង និងការបញ្ជ្រាបការអភិវឌ្ឍបៃតង។ ចំហាកទាំងនេះផ្តល់ជាគំនិតជារួមពីលទ្ធភាពរបស់ទីប្រជុំជនក្នុងតំបន់ទីក្រុងតាមរយៈសកម្មភាព និងគុណភាពនៃការរស់នៅ ដែលនាំឱ្យយើងដឹងពីការប្រើប្រាស់ធនធានក្នុងទីប្រជុំជន ទម្រង់នៃការបំពុលបរិយាសកាស ពីបែបផែននៃការរស់នៅទីប្រជុំជន និងធ្វើការសង្ខេបលើចំហាកទាំងនេះនូវអ្វីដែលជាគោលដៅពង្រីកការអភិវឌ្ឍបន្ថែមក្នុងរយៈពេលវែង។

## ជំហានទី៩៖ ការរៀបចំបញ្ជី គម្រោងវិនិយោគទីក្រុងបៃតងដែលជាអាទិភាព

គម្រោងវិនិយោគ ដែលបានសម្រាំងចេញពីការធ្វើចំណាត់ថ្នាក់អាទិភាព (ក្នុងជំហានទី៧) នឹងត្រូវយក

មកធ្វើការវិភាគផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចបន្តទៀត ដើម្បីឱ្យប្រាកដថាគម្រោងវិនិយោគទាំងនោះអាចផ្តល់នូវផលចំណេញត្រឡប់មកវិញប្រកបដោយការពេញចិត្ត។ ការវិភាគផ្នែកហិរញ្ញវត្ថុ នឹងត្រូវបានធ្វើឡើងដោយប្រើប្រាស់ឧបករណ៍វិភាគដូចជា ការវិភាគផលចំណេញធៀបជាមួយការចំណាយ (Cost and Benefit Analysis - CBA) ការវិភាគលើប្រសិទ្ធភាពចំណាយ (Cost Effectiveness Analysis - CEA) និងការវិភាគខ្សែកោង ដែលបង្ហាញពីការវិភាគការចំណាយថយចុះបន្ថែម (Marginal Abatement Cost Curves - MACCs) និងខ្សែកោងបន្សាំតម្លៃ (Adaptation Cost Curves - ACCs) ដោយអាស្រ័យទៅលើគម្រោងតាមវិស័យ និងលទ្ធផលរំពឹងទុកទៅតាមគម្រោងនីមួយៗ។ ចំពោះគម្រោងវិនិយោគណាដែលបានបញ្ជាក់ថាអាចធ្វើទៅរួចក្នុងន័យសេដ្ឋកិច្ច នឹងត្រូវយកទៅអនុវត្តបន្តតាមរយៈការសិក្សាពីសមិទ្ធិលទ្ធភាពអនុវត្តគម្រោងក្នុងស្ថានភាពបច្ចុប្បន្ន (feasibility) ក្នុងនោះរួមមានទាំងការពិពណ៌នាលម្អិតអំពីទិដ្ឋភាពបច្ចេកទេស និងការរៀបចំសម្រាប់ការអនុវត្តប្រកបដោយភាពជោគជ័យ។

## ជំហានទី១០៖ ការរៀបចំការអនុវត្ត ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង

ភាពជឿជាក់ដែលមានក្នុងអំឡុងពេលនៃការរៀបចំផែនការ នឹងត្រូវរក្សាឱ្យបានក្នុងអំឡុងពេលនៃការអនុវត្ត។ ការរៀបចំអភិបាលកិច្ចនឹងដាក់បញ្ចូលទៅក្នុងជំហាននេះ ហើយនឹងត្រូវរក្សាឱ្យមានការចូលរួម និងការពិគ្រោះយោបល់ពីគ្រប់ភាគី។ ប្រភពធនធានដែលអាចនឹងទទួលបាន នឹងត្រូវបានពិនិត្យឡើងវិញ និងពិភាក្សា។ ទំនួលខុសត្រូវសម្រាប់ការអនុវត្តគម្រោងជាក់លាក់ណាមួយ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមអង្គភាពបច្ចេកទេស។ ចំពោះផែនការ នឹងតម្រូវឱ្យមានការត្រួតពិនិត្យជាប្រចាំសម្រាប់អំឡុងពេលអនុវត្តន៍ និងអំឡុងពេលសរសេររបាយការណ៍។ ប្រព័ន្ធទំនាក់ទំនងប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងការយល់ដឹងជាសាធារណៈ នឹងត្រូវរក្សាឱ្យមានដើម្បីផ្តល់នូវព័ត៌មានស្តីពីវឌ្ឍនភាពនៃគម្រោង និងដើម្បីទទួលបានមតិយោបល់ជាធាតុចូលផ្សេងៗ។

## ១. ការរៀបចំអភិបាលកិច្ច សម្រាប់ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង

ការរៀបចំ **ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង** ទាមទារឱ្យមានភាពជាអ្នកដឹកនាំដ៏រឹងមាំមួយក្នុងការរៀបចំផែនការពីស្ថាប័នរដ្ឋាភិបាល និងត្រូវមានភាពសកម្មក្នុងការសម្របសម្រួលឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ។ ការរៀបចំផែនការទីក្រុងបៃតង អាចបញ្ចូលទៅក្នុងក្របខ័ណ្ឌធ្វើផែនការនៃរដ្ឋបាលថ្នាក់មូលដ្ឋានដែលមានស្រាប់។ ទោះជាយ៉ាងណាក៏ដោយ បណ្តាញនៃការរៀបចំផែនការគួរតែមានភាពទូលំទូលាយ ដោយបញ្ចូល និងបន្តការចូលរួមពីស្ថាប័ន និងអ្នកពាក់ព័ន្ធដូចជា ក្រសួងពាក់ព័ន្ធ ស្ថាប័នសាធារណៈថ្នាក់ខេត្ត និងមូលដ្ឋាន សហគមន៍មូលដ្ឋាន វិស័យឯកជន និងម្ចាស់ជំនួយសកម្មនៅក្នុងតំបន់នោះ។ វិសាលភាពនៃសមាជិកគួរតែត្រូវបានពង្រីកឱ្យមានភាពគ្រប់ជ្រុងជ្រោយ ដែល**អង្គភាព ឬក្រុមរៀបចំផែនការទីក្រុងបៃតង** ត្រូវបានបង្ហាញក្នុងរូបខាងក្រោម (**រូបភាព ទី២**)។

*រូបភាពទី ២៖ អង្គភាព ឬក្រុមការងារ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង*




អាជ្ញាធររៀបចំផែនការថ្នាក់មូលដ្ឋានដែលមានស្រាប់ គួរតែទទួលបាននូវសិទ្ធអំណាចពីថ្នាក់ដឹកនាំ (អភិបាល) ថ្នាក់ខេត្ត/ក្រុង ស្រុក ដើម្បីបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង និងអនុវត្តន៍ដំណើរការរៀបចំផែនការទីក្រុងបៃតងប្រកបដោយការសហការ និងទំនាក់ទំនងពេញលេញ ជាមួយស្ថាប័នសាធារណៈ ស្ថាប័នបច្ចេកទេស និងអ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋាន ដូចមានបង្ហាញក្នុង**តារាងទី១** ខាងក្រោម។

ក្រុមការងាររៀបចំផែនការទីក្រុងបៃតង នឹងត្រូវបានគ្រប់គ្រងដោយក្រុមគណៈកម្មការដឹកនាំ ដែលសហការគ្រប់គ្រងដោយអភិបាល និងអ្នកតំណាងពី ក.ជ.អ.ច. ដែលនឹងគាំទ្រទៅលើដំណើរការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង។ លេខាធិការដ្ឋានរៀបចំផែនការគួរតែត្រូវបានតែងតាំងជាមួយនឹងទំនួលខុសត្រូវលើការគ្រប់គ្រង និងសម្របសម្រួលលើប្រតិបត្តិការប្រចាំថ្ងៃ។

***តារាងទី ១៖ សមាជិកនៃក្រុមការងារសម្រាប់រៀបចំផែនការទីក្រុងបៃតង***

| អង្គភាពជំនាញ | ស្ថានប័នសារធារណៈ | អ្នកពាក់ព័ន្ធថ្នាក់មូលដ្ឋាន |
|---|---|---|
| • ការប្រើប្រាស់ដីធ្លី និងការរៀបចំផែនការទីប្រជុំជន<br>• រ៉ែ និងថាមពល<br>• មុខងារសាធារណៈ និងការដឹកជញ្ជូន<br>• បរិស្ថាន<br>• ឧស្សាហកម្ម និងសិប្បកម្ម<br>• អប់រំ យុវជន និងកីឡា<br>• កិច្ចការនារី<br>• អង្គភាពពាក់ព័ន្ធផ្សេងទៀត | • សាលាខេត្ត<br>• សាលាក្រុង<br>• ក្រុមប្រឹក្សាស្រុក<br>• ក្រុមប្រឹក្សាឃុំ<br>• ក្រសួងពាក់ព័ន្ធ<br>• ក.ជ.អ.ច. | • អង្គការក្រៅរដ្ឋាភិបាល<br>• អង្គការសង្គមស៊ីវិល<br>• ក្រុមហ៊ុនវិស័យឯកជន<br>• អង្គការម្ចាស់ជំនួយ<br>• សាកលវិទ្យាល័យ/ស្ថាប័នអប់រំ<br>• អ្នកពាក់ព័ន្ធផ្សេងទៀត |

លេខាធិការដ្ឋានរៀបចំផែនការគួរបញ្ជូនលិខិតអញ្ជើញផ្លូវការទៅសមាជិកនីមួយៗនៃក្រុមការងារ ដែលមានសក្តានុពលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង។ លិខិតអញ្ជើញគួរតែស្នើអង្គភាពនីមួយៗបញ្ជូនមន្ត្រីជំនាញតែម្នាក់ (ឬមន្ត្រីបន្ទាប់) ដើម្បីចូលរួម។ វាមានភាពចាំបាច់ដែលបុគ្គលតែមួយជាតំណាងនៃស្ថាប័ននីមួយៗ ចូលរួមក្នុងដំណើរការរៀបចំផែនការទីក្រុងបៃតងពីដើមដំបូងនិងបន្តបន្ទាប់ ដើម្បីរក្សានិរន្តរភាព និងជំនាញបច្ចេកទេស។

ក្នុងការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង គួរតែប្រើប្រាស់**អ្នកជំនាញការបច្ចេកទេស និងការសម្របសម្រួលរបស់** ក.ជ.អ.ច. ផងដែរ។ លេខាធិការដ្ឋានរៀបចំផែនការគួរបង្កើតទំនាក់ទំនងជាមួយអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.។ អគ្គលេខាធិការដ្ឋាននេះមានធនធានបច្ចេកទេស និងមានចំណេះដឹងទូលំទូលាយលើទិដ្ឋភាពទូទៅនូវគំនិតផ្តួចផ្តើម លើការអភិវឌ្ឍទីក្រុងបៃតងថ្នាក់ក្រោមជាតិ ដែលអាចជួយក្រុមការងាររៀបចំផែនការទីក្រុងបៃតងដំណាក់កាលនៃដំណើរការរៀបចំផែនការ។ អគ្គលេខាធិការដ្ឋានអាចជួយសម្របសម្រួលផងដែរ លើការរៀបចំផែនការទីក្រុងបៃតងរវាងបណ្តាខេត្តជិតខាង និងទីក្រុង។

នៅពេលដែលក្រុមការងាររៀបចំទីក្រុងបៃតងត្រូវបានរៀបចំឡើង លេខាធិការដ្ឋានរៀបចំផែនការគួររៀបចំ និងធ្វើការប្រជុំពិគ្រោះយោបល់លើការរៀបចំផែនការ ដែលមានការចូលរួមពីអ្នកតំណាងទាំងអស់។ ការប្រជុំដែលត្រូវបានស្នើឡើងជាបន្តបន្ទាប់ និងគោរពទៅតាមរបៀបវារៈ ដូចមានបង្ហាញជូនក្នុង**រូបភាពទី៣** ខាងក្រោម។ នេះគ្រាន់តែការបង្ហាញនូវប្រភេទនៃការជួបប្រជុំ និងរបៀបវារៈនៃកិច្ចប្រជុំផ្សេងៗត្រូវបានបង្ហាញនៅក្នុង**រូបភាពទី៣** ខាងក្រោម។ កិច្ចប្រជុំប្រតិបត្តិការគួរតែរៀបចំលើការបន្តកើតមានការព្រួយបារម្ភនានា និងសមត្ថភាពនៃបរិបទការរៀបចំផែនការទីប្រជុំជនមូលដ្ឋាន។

***រូបភាពទី ៣៖ សេចក្តីស្នើឱ្យមាន កិច្ចប្រជុំសម្រាប់រៀបចំផែនការ និងរបៀបវារៈនៃកិច្ចប្រជុំ***

**កិច្ចប្រជុំជាដំបូងសម្រាប់ការចាប់ផ្តើម**

- ធ្វើសេចក្តីសម្រេចលើ កិច្ចព្រមព្រៀងលក្ខខណ្ឌការងារក្នុងការងាររៀបចំផែនការទីក្រុងបៃតង
- លក្ខខណ្ឌការងារត្រូវមានវត្ថុបំណងច្បាស់លាស់ ទិន្នផល សកម្មភាព ទំនួលខុសត្រូវ កាលវិភាគ របាយការណ៍ និងយន្តការសម្របសម្រួល

**ការប្រមូលទិន្នន័យ**

- កិច្ចសហប្រតិបត្តិការណ៍លើការប្រមូលទិន្នន័យ និងការវិភាគ
- ការវិភាគជាមូលដ្ឋាននៃបរិបទទីប្រជុំជន

**ទស្សនវិស័យ និងគោលដៅជាក់លាក់**

- ឯកភាពគ្នាទៅវិញទៅមកលើទស្សនវិស័យនៃការអភិវឌ្ឍទីក្រុងបៃតង
- បង្កើតគោលដៅរយៈខ្លី មធ្យម និងវែង

**ពិនិត្យលើវិស័យសំខាន់ៗ**

- វិស័យដែលត្រូវពិនិត្យរួមមាន ការរៀបចំផែនការទីប្រជុំជន ភាពងាយរងគ្រោះទីប្រជុំជន ថាមពល ការដឹកជញ្ជូន បរិស្ថានសំណង់ ចង្វាក់ផលិតកម្ម ទីវាលសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌ ការគ្រប់គ្រងសំណល់រឹង

**គោលដៅតាមវិស័យ សកម្មភាពអាទិភាព និងគម្រោងវិនិយោគ**

- ការកំណត់ពីគោលដៅតាមវិស័យ និងសកម្មភាព
- ការកំណត់ពីវិនិយោគរយៈពេលខ្លី និងមធ្យមជាច្រើនក្នុងវិស័យទាំងអស់
- ធ្វើការសម្រាំង និងជ្រើសរើសគម្រោងវិនិយោគអាទិភាព
- ការបង្ហាញពីលទ្ធភាពអនុវត្តគម្រោងអាទិភាព

**ការឯកភាពលើផែនការចុងក្រោយ**

- ការឯកភាព និងប្រឹក្សាយោបល់ចុងក្រោយលើផែនការយុទ្ធសាស្ត្រទីក្រុងបៃតង
- ពង្រាងចុងក្រោយនៃផែនការអភិវឌ្ឍន៍ទីប្រជុំជនបៃតង នឹងត្រូវប្រគល់ជូនទៅដល់ស្ថាប័នរដ្ឋ និងក.ជ.អ.ច.

តំណាក់កាលកិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំផែនការនីមួយៗ នឹងនាំឱ្យមានការបញ្ចូលគ្នានូវទស្សនៈជារួម និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមអ្នកចូលរួមដោយផ្ទាល់លើដំណើរការរៀបចំផែនការទីប្រជុំជនបៃតង។ អ្នកចូលរួម ដែលមិនមែនមកពីស្ថាប័នរដ្ឋាភិបាល នឹងមានចំណេះដឹងបន្ថែមលើយន្តការនៃការរៀបចំផែនការសាធារណៈ និងការប្រតិបត្តិការលើវិស័យនានា ខណៈដែលអ្នកតំណាងមកពីស្ថានប័នរដ្ឋាភិបាល នឹងទទួលបានព័ត៌មានជាច្រើនបន្ថែមទៀតទៅលើផ្នត់គំនិត ចំណេះដឹង តម្រូវការ និងបញ្ហាអាទិភាព។ តម្រូវការជាក់លាក់របស់ស្ត្រី និងយុវជនពិតជាមានសារៈសំខាន់សម្រាប់បញ្ចូលទៅក្នុងផែនការនេះ។

សម្រាប់កិច្ចប្រជុំសហប្រតិបត្តិការមួយចំនួន វានឹងមានផលចំនេញច្រើន បើមានការចូលរួមរបស់អ្នកជំនាញការបច្ចេកទេស និងហិរញ្ញវត្ថុដែលអញ្ជើញមកពីក្រុមទីប្រឹក្សាជំនាញ។ ក្រុមទីប្រឹក្សាទាំងនេះមានប្រយោជន៍ច្រើនក្នុងការជួយក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ដូចជាការប្រមូលទិន្នន័យ ការពិនិត្យលើវិស័យសំខាន់ៗ និងការរៀបចំគម្រោង និងសកម្មភាពអាទិភាព។

កាលវិភាគពេលវេលាសម្រាប់អនុវត្តការងារ គួរតែត្រូវបានបង្កើតឡើងសម្រាប់ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងនៅពេលបើកកិច្ចប្រជុំដំបូង។ **តារាងទី ២** ខាងក្រោមបង្ហាញពីកិច្ចប្រជុំសហប្រតិបត្តិការតាមតំណាក់កាលនីមួយៗ ជាមួយនឹងតម្រូវការពេលវេលាដែលសមស្រប ក្នុងការសម្រេចឱ្យបានតាមដំណាក់កាលទាំងនោះ។ ដំណើរការរៀបចំផែនការទីក្រុងបៃតង ត្រូវបានរំពឹងទុកថានឹងបញ្ចប់ក្នុងចន្លោះរយៈពេលពី ៩ ទៅ ១២ ខែ។

***តារាងទី ២៖ តម្រូវការពេលវេលា ក្នុងការសម្រេចលទ្ធផលតាមតំណាក់កាលប្រជុំ***

| កិច្ចប្រជុំ | ចំនួនខែដែលត្រូវការដើម្បីបញ្ចប់របៀបវារៈ |
|---|---|
| កិច្ចប្រជុំដំបូង | ១ |
| ការប្រមូលទិន្នន័យ ដើម្បីវិភាគពីទិន្នន័យមូលដ្ឋាន | ២ - ៣ |
| ទស្សនវិស័យទីក្រុង បេសកកម្ម និងគោលដៅជាក់លាក់ជាក្រុម | ១ |
| ការពិនិត្យទៅលើវិស័យសំខាន់ៗ | ២ - ៣ |
| គោលដៅតាមវិស័យ សកម្មភាពជាអាទិភាព និងគម្រោងវិនិយោគទីក្រុងបៃតងអាទិភាព | ២ - ៣ |
| ការឯកភាពគ្នាលើផែនការចុងក្រោយ | ១ |

## ២. ការវាយតម្លៃលើទិន្នន័យមូលដ្ឋានក្នុងបរិបទទីប្រជុំជន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង នឹងត្រូវផ្តោតលើការរកឃើញលម្អិតនៃបញ្ហាប្រឈមទៅលើកត្តាប្រជាសាស្ត្រ សេដ្ឋកិច្ច អភិបាលកិច្ច សង្គមកិច្ច និងបរិស្ថាន របស់តំបន់ទីក្រុងដែលយើងកំពុងសិក្សា។ កិច្ចការនេះ គឺត្រូវការប្រមូលទិន្នន័យ និងការសិក្សាវាយតម្លៃបញ្ហាពាក់ព័ន្ធដែលនឹងរៀបរាប់ដូចខាងក្រោម។ ក្នុងករណីខ្លះការស្វែងរកទិន្នន័យមានលក្ខណៈងាយស្រួល ហើយសមត្ថភាពរបស់ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងមានគ្រប់គ្រាន់។ ប៉ុន្តែករណីខ្លះទៀត គឺមានការពិបាក ដូចជាទិន្នន័យទាក់ទងនឹងការព្យាករលើបញ្ហាអាកាសធាតុ ការវាយតម្លៃអំពីកម្រិតបំពុល ដែលតម្រូវឱ្យមានជំនួយគាំទ្រផ្នែកបច្ចេកទេសពីអ្នកជំនាញការជាដើម។

### ២.១. កំណើនប្រជាសាស្ត្រ ក្នុងពេលបច្ចុប្បន្ន និងអនាគត

កំណើនប្រជាសាស្ត្របច្ចុប្បន្ន និងអនាគត នឹងមានសារៈសំខាន់ក្នុងការវាស់វែងទំហំនៃចំនួនប្រជាជនតាំងទីលំនៅបច្ចុប្បន្ន និងលក្ខណៈទូទៅរបស់វា ដូចជាភេទ និងអាយុ ទំហំគ្រួសារ ការងារ និងមុខរបរ។ ម្យ៉ាងទៀតចំណេះដឹងនៃការគណនាអត្រាកើត និងស្លាប់ នឹងជួយកំណត់នូវអត្រាកំណើនប្រជាសាស្ត្រ របស់ចំនួនប្រជាជនតាំងទីលំនៅ និងការព្យាករអំពីទំហំកំណើនរបស់វាសម្រាប់ពេលអនាគត។ តួរលេខស្តីអំពីចំនួនប្រជាជនដែលផ្លាស់ប្តូរទីលំនៅពីជនបទមកទីក្រុង និងការផ្លាស់ប្តូរទីលំនៅពីទីប្រជុំជនផ្សេងទៀត នឹងត្រូវបានយកមកគណនាផងដែរ។ ទិន្នន័យប្រជាសាស្ត្រ គឺជាមូលដ្ឋានក្នុងការវាស់វែងអត្រាបច្ចុប្បន្ន នៃនគរូបនីយកម្ម និងសំពាធលើការប្រើប្រាស់ដីធ្លី ដែលមានការពាក់ព័ន្ធ ទៅនឹងកំណើននគរូបនីយកម្មក្រុងសម្រាប់រយៈពេល១០ឆ្នាំខាងមុខទៀត។

### ២.២. ទិន្នន័យមូលដ្ឋានផ្នែកសេដ្ឋកិច្ច និងនិន្នាការពេលអនាគត

ការត្រួតពិនិត្យនូវកត្តាសំខាន់ៗរបស់សកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្ន គឺជួយកំណត់នូវធនធានដែលអាចរកបាន **កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងពេលបច្ចុប្បន្ន** និន្នាការនៃការអភិវឌ្ឍនាពេលអនាគត និងបណ្តាវិស័យពាក់ព័ន្ធ ដែលផ្តោតសំខាន់លើការអភិវឌ្ឍទីក្រុងបៃតង។ ការរំលឹកឡើងវិញរួមជាមួយនឹងការវាយតម្លៃនៃឯកសាររៀបចំផែនការសេដ្ឋកិច្ចបច្ចុប្បន្ន និងទិន្នន័យ (ស្ថិតិលេខ) ដែលអាចរកបាន និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីជាគោលការណ៍ចែករំលែកសម្រាប់គោលដៅកំណើនសេដ្ឋកិច្ច។ ការបង្កើតចំណុចចាប់ផ្តើម គឺបង្ហាញឱ្យឃើញអំពីស្ថានភាពបច្ចុប្បន្ននៅក្នុងទីក្រុង និងដំណើរការអភិវឌ្ឍរបស់វាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ បញ្ហានេះ គួររួមបញ្ចូលនូវចំនួនសូចនាករសេដ្ឋកិច្ចដូចជា៖

- សេដ្ឋកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុង( ឧទាហរណ៍៖ ផលិតផលក្នុងស្រុកសរុប កំណើនផលិតផលក្នុងស្រុកសរុប ការបែងចែកផលិតផលក្នុងស្រុកសរុបតាមវិស័យ និងការផលិតបានតាមវិស័យ)
- ការវិនិយោគក្នុងស្រុក (ប្រភពនៃការវិនិយោគ និងការវិនិយោគតាមវិស័យ)
- ពាណិជ្ជកម្មខាងទំនិញ និងសេវាកម្ម
- ទំហំ និងរចនាសម្ព័ន្ធគ្រប់គ្រងកំលាំងពលកម្ម
- និងអត្រាភាពក្រីក្រ និងសូចនាករសង្គម (ឧទាហរណ៍៖ ការកំណត់ភាពក្រីក្រ អត្រាភាពក្រីក្រ អត្រាខ្វះអាហាររូបត្ថម្ភសម្រាប់កុមារជាដើម)។

ទិន្នន័យកាលពី១០ឆ្នាំមុន គួរតែត្រូវបានប្រមូលដើម្បីកំណត់អត្តសញ្ញាណកម្ម នៃនិន្នាការការអភិវឌ្ឍ។

ទិន្នន័យបែបបរិមាណ គួរតែត្រូវបានបញ្ចូលរួមគ្នាជាមួយទិន្នន័យបែបគុណភាពនៅចំណុចមួយចំនួនដូចជា ការគណនាសកម្មភាពសេដ្ឋកិច្ចក្រៅផ្លូវការ (ដែលជាទូទៅមិនត្រូវបានកំណត់ក្នុងស្ថិតិជាតិនោះទេ)។

## ២.៣. បណ្តុំនៃការរស់នៅរបស់ប្រជាជនក្នុងសង្គម និងជនជាតិ និងរបាយនៃប្រាក់ចំណូល

តំបន់ទីក្រុង និងទីប្រជុំជននៅកម្ពុជា ជាកន្លែងប្រមូលផ្តុំនៃគ្រប់សហគមន៍មកពីតំបន់ផ្សេងៗគ្នាទាំងក្នុងប្រទេស ក៏ដូចជាជនជាតិមកពីក្រៅប្រទេសផងដែរ។ កម្រិតនៃការធ្វើសមាហរណកម្មនៃការរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទីក្រុង គឺមានភាពខុសប្លែកគ្នា។ បញ្ហានេះ នឹងក្លាយជារឿងសំខាន់ក្នុងការកំណត់អត្តសញ្ញាណ និងគូសផែនទីបង្ហាញពីវត្តមានជាជំហានដំបូង ឆ្ពោះទៅរកការធ្វើសមាហរណកម្មកាន់តែប្រសើរ និងការចុះសម្រុងគ្នាកាន់តែច្រើន។ ដូចគ្នាដែរ ការវិភាគអំពីបរិបទ និងទិន្នន័យដើម នឹងបញ្ចូលការពិនិត្យឡើងវិញរបស់ក្រុងនានា ការចូលរួមជាផ្លូវការ និងមិនផ្លូវការក្នុងសេដ្ឋកិច្ចទីក្រុង និងរបាយប្រាក់ចំណូល។ ភាគរយនៃគ្រួសារដែលស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ នឹងក្លាយទៅជាសូចនាករសំខាន់សម្រាប់វាស់វែង។ ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីនៅក្នុងគ្រឹះស្ថានអប់រំក្នុងតំបន់ និងការចូលរួមរបស់ស្ត្រីក្នុងការងារ នឹងក្លាយជាសូចនាករសំខាន់ ដើម្បីសម្រេចឱ្យបានសមភាពយេនឌ័រ។

## ២.៤. អភិបាលកិច្ចសម្រាប់ការអភិវឌ្ឍទីប្រជុំជន និងហិរញ្ញវត្ថុរបស់សាលាក្រុង

អភិបាលកិច្ចទីប្រជុំជន នឹងត្រូវបានកំណត់ដោយការរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលក្នុងតំបន់នាពេលបច្ចុប្បន្ន និងអាណត្តិសម្រាប់ការរៀបចំផែនការ និងការគ្រប់គ្រងទីក្រុង ដូចដែលបានបង្ហាញនៅក្នុង**តារាងទី៣** ខាងក្រោម។ ការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ននៃហិរញ្ញវត្ថុរបស់សាលាក្រុង (រួមមានធនធានដែលមានស្រាប់ និងដំណើរការនៃការបង្កើត និងចំណាត់ថ្នាក់ប្រាក់ចំណូល) គឺជាកត្តាសំខាន់។ កិច្ចការនេះ ពាក់ព័ន្ធនឹងការពិចារណាទាំងដំណើរការហិរញ្ញវត្ថុថ្នាក់ជាតិ និងថ្នាក់ក្រុង។ ការពិនិត្យឡើងវិញ នឹងក្លាយជាការព្រួយបារម្ភដ៏ចម្បងមួយជាមួយនឹងលទ្ធភាពនៃធនធានហិរញ្ញវត្ថុសាធារណៈ និងឯកជន សម្រាប់វិនិយោគនៅក្នុងសកម្មភាពអភិវឌ្ឍន៍ទីក្រុងបៃតង៖

- បង្កើតចំណុចចាប់ផ្តើមនៃហិរញ្ញវត្ថុតាមរយៈការពិនិត្យឡើងវិញនូវថវិការបស់សាលាក្រុងតាមចំនួននៃឆ្នាំ
- រួមបញ្ចូលការវិនិយោគទុន ការចំណាយចរន្តលើហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្ម និងប្រភពចំណូលរបស់សាលាក្រុង
- កំណត់និន្នាការថ្មីៗនៅក្នុងការវិនិយោគ ការបង្កើតចំណូល និងការចំណាយនៅក្នុងទីក្រុង ដើម្បីរកឱ្យឃើញពីឧបសគ្គ និងឱកាសចម្បងៗ ដែលជាបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុរបស់សាលាក្រុង
- ពិនិត្យឡើងវិញការរៀបចំផែនការថវិការបស់សាលាក្រុងនាពេលបច្ចុប្បន្ន រួមបញ្ចូលទាំងការវិនិយោគរំពឹងទុកលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មក្នុងក្រុង និងប្រភពចំណូល និងទុនរំពឹងទុក
- ពិនិត្យឡើងវិញការរៀបចំអង្គភាពហិរញ្ញវត្ថុរបស់សាលាក្រុង រួមមានដំណើរការរៀបចំថវិកា និងការកៀរគរទុនវិនិយោគ ការកំណត់ឱកាស និងឧបសគ្គចម្បងៗសម្រាប់ការផ្គត់ផ្គង់ហិរញ្ញប្បទានសកម្មភាពអភិវឌ្ឍន៍ទីក្រុងបៃតង។

*តារាងទី ៣៖ បញ្ជីឈ្មោះលិខិតបទដ្ឋានគតិយុត្ត លើវិស័យដីធ្លី និងនគរូបនីយកម្មនៅប្រទេសកម្ពុជាពីឆ្នាំ ២០០៨ ដល់ ២០១៥*

| លិខិតបទដ្ឋានគតិយុត្ត លើវិស័យដីធ្លី និងនគរូបនីយកម្មនៅកម្ពុជា | ស្ថាប័ន |
|---|---|
| ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) | ក្រសួងមហាផ្ទៃ |
| អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពី នីតិវិធីរៀបចំផែនការប្រើប្រាស់ដីធ្លីរបស់ឃុំសង្កាត់ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| សារាចរលេខ ០៣ ស្តីពី ការទូទាត់បណ្តោះអាសន្នលើដីធ្លីដែលត្រូវបានកាន់កាប់ដោយខុសច្បាប់នៅតំបន់រាជធានី ក្រុង និងទីប្រជុំជននានា (២០១០) | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| គោលនយោបាយជាតិ ស្តីពី ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៨ ខែមេសាឆ្នាំ ២០១១ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ព្រះរាជក្រឹត្យ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិរៀបចំដែនដី និង នគរូបនីយកម្ម (២០១២) | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| សៀវភៅ ស្តីពី គោលនយោបាយដីធ្លី របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី (សីហា ២០១២) | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| អនុក្រឹត្យលេខ ៧៧ ស្តីពី ការបង្កើតគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្ម នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០១២) | ក្រសួងមហាផ្ទៃ |
| អនុក្រឹត្យលេខ ៦៨ ស្តីពី ដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធាន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងមហាផ្ទៃ (គ.ជ.អ.ប.) |
| អនុក្រឹត្យលេខ១០៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្មជាតិ (២០១៣) | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| អនុក្រឹត្យ ស្តីពី នគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន (២០១៥) | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

## ២.៥. ហានិភ័យធម្មជាតិ និងហានិភ័យអាកាសធាតុមកលើទីក្រុង

ទីក្រុងត្រូវតែមានការបន្ស៊ីគ្នាជាមួយធម្មជាតិ និងកំណើនរបស់វា ហើយការកើនឡើងនូវគ្រោះថ្នាក់ធម្មជាតិ និងហានិភ័យទីក្រុង ពេលខ្លះត្រូវបានមើលរំលង។ ទឹកជំនន់ ភ្លៀងខ្លាំង ព្យុះសមុទ្រ និងព្យុះទីហ្វុង តំណាងឱ្យគ្រោះថ្នាក់ចម្បងៗសម្រាប់បណ្តាទីក្រុង និងទីប្រជុំជននៅប្រទេសកម្ពុជា (**រូបភាពទី៤**)។ ហានិភ័យទីក្រុង អាចរួមបញ្ចូលកត្តាគំរាមកំហែងនៅតាមទីតាំងឧស្សាហកម្មដែលមានការបំពុលខ្លាំង ក៏ដូចជាការទុកដាក់សម្ភារៈឧស្សាហកម្មដែលងាយបង្កគ្រោះថ្នាក់ និងគ្រោះអគ្គីភ័យ។ បញ្ហាទាំងនេះត្រូវតែមានការកំណត់អត្តសញ្ញាណ និងកំណត់តំបន់ឱ្យបានច្បាស់លាស់។ តំបន់ដែលមានភាពក្រីក្រ ជាទូទៅគឺងាយទទួលរងគ្រោះបំផុត និងជាញឹកញាប់ ទៅតាមទីតាំងប្រកពសំខាន់ៗ នៃការប្រឈមរបស់ទីក្រុង។

ការប្រែប្រួលអាកាសធាតុ កំពុងបង្កផលប៉ះពាល់ដល់ពិភពលោក រួមទាំងទីក្រុង និងទីប្រជុំជនរបស់កម្ពុជាផងដែរ។ ការកើនឡើងជាលំដាប់នៃសីតុណ្ហភាពបរិយាកាស ភ្លៀងធ្លាក់ខ្លាំងនិងជាប់ៗគ្នា ភាពរាំងស្ងួតរយៈពេលវែង ការកើនឡើងនូវនីវ៉ូទឹកសមុទ្រ និងបាតុភូតផ្សេងៗទៀត បានបង្ហាញពីវត្តមាននៅតាមទីតាំងផ្សេងៗគ្នា។ ទោះបីជាមានភាពមិនប្រាកដប្រជា នៃវត្តមានរបស់បាតុភូតខាងលើ ប៉ុន្តែការព្យាករអំពីបាតុភូតទាំងនេះ គឺមានសារៈសំខាន់ណាស់ដែលអាចជួយឱ្យយើងដឹងអំពីហានិភ័យ ដែលនឹងអាចកើតឡើងក្នុងទីក្រុងនៅកំឡុងពេល ១០ឆ្នាំខាងមុខ។ បញ្ហានេះ នឹងតម្រូវឱ្យមានការគាំទ្រពីអ្នកជំនាញឯកទេស។

***រូបភាពទី ៤៖ ផែនទីទឹកជំនន់នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល នាខែតុលាឆ្នាំ ២០១៤***



ប្រភព: E-geos

## ២.៦. ស្ថានភាពបច្ចុប្បន្ននៃបរិស្ថានទីក្រុង និងផលប៉ះពាល់ពីការបំពុលបរិស្ថានមកលើសុខភាពសាធារណៈ

សកម្មភាពសេដ្ឋកិច្ច អាចមាន**ផលវិបាកអវិជ្ជមាន**មកលើបរិស្ថាន និងសុខភាពសាធារណៈ តាមរយៈការបំពុល ដែលបង្កដោយប្រព័ន្ធបង្ហូរទឹកលូ និងសំណល់រាវដែលមិនបានសម្អាតត្រឹមត្រូវ សំណល់រឹង ការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាសរបស់រថយន្ត និងការបំភាយឧស្ម័នពីរោងចក្រឧស្សាហកម្ម (**រូបភាពទី៥**)។ ធនធាន

ធម្មជាតិដែលរងផលប៉ះពាល់ (ដី ទឹក និងខ្យល់) អាចបាត់បង់ចេញពីតំបន់ទីក្រុងបាន។ ប្រជាជនតាំងទីលំនៅក្នុងក្រុង នឹងរងផលប៉ះពាល់ពីការកើនឡើងនូវជំងឺ និងកម្រិតស្លាប់ដោយសារជម្ងឺ ដែលអាចប៉ះពាល់ផ្ទាល់ដោយសារការបំពុលបរិស្ថាន។ អ្នកជំនាញអាចជួយនៅក្នុងការសង្គ្រោះ និងផ្សព្វផ្សាយព័ត៌មាននេះ។

***រូបភាពទី ៥៖ ការបំពុលតំបន់ទឹកក្នុងទីក្រុង ពីសំណល់រឹងនៅរាជធានីភ្នំពេញ***



ប្រភព: Phnom Penh Post

## ៣. ទស្សនៈវិស័យរួម នៃទីក្រុងបៃតង និងគោលដៅអភិវឌ្ឍន៍ក្រុង

តំបន់ទីក្រុង និងទីប្រជុំជននៃព្រះរាជាណាចក្រកម្ពុជា គឺកំពុងរីកលូតលាស់យ៉ាងឆាប់រហ័ស តាមរយៈកំណើនប្រជាសាស្ត្រទ្វេរដង និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដែលបានផ្តោតខ្លាំងទៅលើការកើនឡើងនៃការវិនិយោគ និងចំនួនការងារនៅក្នុងតំបន់ក្រុង។ ការរីកលូតលាស់នៃនគរូបនីយកម្ម គឺជាកាលានុវត្តភាពមួយផងដែរសម្រាប់ប្រទេសកម្ពុជា ដែលអាចផ្តល់នូវសុខុមាលភាព និងបង្កើនការទទួលបានសេវាកម្មសំខាន់ៗបន្ថែមលើការវិនិយោគផ្ទាល់ពីបរទេស។

ទោះជាយ៉ាងណាក៏ដោយ វាអាចមានផលអវិជ្ជមានផងដែរទៅលើធនធានធម្មជាតិ (ដី ទឹក និងខ្យល់) និងមកលើសុខភាពសាធារណៈ តាមរយៈការបំពុលដែលបង្កដោយប្រព័ន្ធបង្ហូរទឹកល្អ និងទឹកសំណល់ដែលមិនបានសម្អាតត្រឹមត្រូវ សំណល់រឹង ការបញ្ចេញឧស្ម័នទៅក្នុងបរិយាកាសរបស់រថយន្ត និងការបំភាយឧស្ម័នពីរោងចក្រឧស្សាហកម្ម។ ការប្រើប្រាស់ហួសកម្រិតនៃថាមពលនិងប្រេងឥន្ធនៈនឹងបង្កើនឱ្យមាននូវការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) កាន់តែច្រើនដែលជាមូលហេតុធ្វើឱ្យអាកាសធាតុពផែនដីមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

ការអភិវឌ្ឍបៃតង និងជាពិសេសការអភិវឌ្ឍទីក្រុងបៃតង គឺជាគំរូអភិវឌ្ឍន៍មួយដែលនឹងធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ដោយមិនមានផលប៉ះពាល់អវិជ្ជមាននោះទេ។ តាមរយៈវិធីសាស្ត្រនេះ ការពង្រីកសកម្មភាពសេដ្ឋកិច្ច គឺត្រូវបានធ្វើឡើងក្នុងទិសដៅធានាបាននូវកិច្ចគាំពារបរិស្ថានក្នុងកម្រិតសមស្របសម្រាប់សុខភាពសាធារណៈ ការបញ្ចេញកាបូនទាប និងការអភិវឌ្ឍក្រុងស្របតាមការវិវត្តន៍របស់សង្គម។ បញ្ហាប្រឈម និងឱកាសមួយចំនួននៅក្នុងការអភិវឌ្ឍទីក្រុងបៃតងនៅកម្ពុជា គឺត្រូវបានបង្ហាញនៅក្នុង**រូបភាពទី ៦** ដូចខាងក្រោម។

**រូបភាពទី៦ បញ្ហាប្រឈម និងឱកាសមួយចំនួននៅក្នុងការអភិវឌ្ឍទីក្រុងបៃតងនៅកម្ពុជា**




ប្រភព: GGGI

គោលការណ៍ និងទស្សនៈទានអំពីការអភិវឌ្ឍបៃតង គឺមានការទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលយល់ថាទីក្រុងគឺជាម៉ាស៊ីននៃការផ្លាស់ប្តូរបែបផែននៃការអភិវឌ្ឍសេដ្ឋកិច្ចឱ្យទៅរកការអភិវឌ្ឍដែលមានភាពបៃតង ។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ ២០១៣ ដែលបានបើកផ្លូវឱ្យមានការបង្កើតចេញជាផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតងឆ្នាំ២០១៣-២០៣០ ក្នុងនោះបានបញ្ចូលសកម្មភាពទាក់ទងនឹងការអភិវឌ្ឍទីក្រុងបៃតងដូចខាងក្រោម៖

- ការបង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបៃតងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការរៀបចំផែនការកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍
- ការបង្កើតបរិយាកាសធុរកិច្ចបៃតង តាមរយៈលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានស្រាប់ និងលើកទឹកចិត្តការប្រើប្រាស់ថាមពលកកើតឡើងវិញ បង្កើនប្រសិទ្ធិភាពថាមពល និងការអភិវឌ្ឍឧស្សាហកម្មបៃតង
- ការអភិវឌ្ឍ និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ គ្រប់គ្រងសំណល់រឹងឱ្យមានប្រសិទ្ធិភាព
- ការកែលម្អការប្រើប្រាស់ដីធ្លី និងបរិស្ថានទីក្រុង ដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន
- ការបង្កើតឧស្សាហកម្មបៃតង និងសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ការពង្រឹងវិស័យឯកជន ដើម្បីអនុវត្តន៍អភិបាលកិច្ចលើការអភិវឌ្ឍបៃតង
- ការធ្វើសមាហរណកម្មសមភាពយេនឌ័រ ទៅក្នុងការអភិវឌ្ឍបៃតង។

ការរួមគ្នាឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុថ្នាក់ជាតិនៅកម្ពុជា ត្រូវបានសង្ខេបនៅក្នុងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣។ លើសពីទៅនេះទៀត ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៦-២០១៨ ដែលបានបោះពុម្ពផ្សាយនៅខែ មករា ឆ្នាំ ២០១៦ ដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានកំណត់ ការអភិវឌ្ឍទីក្រុងបៃតង គឺជាសកម្មភាពអាទិភាពមួយ។ ក្នុងចំណោមសកម្មភាពជាអាទិភាពទាំង ១៧ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពនេះ សកម្មភាពទី៧ គឺដើម្បី "ធ្វើការអភិវឌ្ឍ និងសាកល្បងវិធីសាស្ត្រធន់នឹងការបញ្ចេញកាបូនតិច និងជម្រើសនៅក្នុងតំបន់ក្រុង"។ សកម្មភាពនេះគ្របដណ្តប់ការអនុវត្ត នៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ក្រុងដោយបញ្ចេញកាបូនតិច ដូចជាកម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតង ( ដែលគាំទ្រដោយ GGGI ) និងប្រព័ន្ធ ទីក្រុងដែលមានសំណង់អាគារបន្សាំនឹងអាកាសធាតុតាមរយៈការបន្សាំលើផ្អែកប្រព័ន្ធអេកូឡូស៊ី (ដោយមានការគាំទ្រពី UNEP/LCDF)។ នាយកដ្ឋានសេដ្ឋកិច្ចបៃតងជាអ្នកទទួលខុសត្រូវលើការអនុវត្តផែនការសកម្មភាពអាទិភាពទី៧ នេះ។

នៅក្នុងចំណោមឯកសារអន្តរជាតិពាក់ព័ន្ធនានា បានកត់សម្គាល់ថា គោលដៅអភិវឌ្ឍន៍ដោយចីរភាព ត្រូវបានអនុម័តនៅខែកញ្ញា ឆ្នាំ២០១៥ ដោយអង្គការសហប្រជាជាតិ រួមមានគោលដៅទី១១ចែងថា "ធ្វើឱ្យទីក្រុង និងការតាំងទីលំនៅរបស់ប្រជាជនមានសុវត្ថិភាព សក្តានុពល និងមាននិរន្តរភាព»។ នៅក្នុងគោលដៅ ១១.B លើកឡើងថា "ត្រឹមឆ្នាំ២០២០ ការកើនឡើងនូវចំនួនទីក្រុង និងការតាំងទីលំនៅរបស់មនុស្សដ៏ច្រើន ត្រូវសម្របនិងអនុវត្តដោយរួមបញ្ចូលគ្នាជាមួយគោលនយោបាយ និងផែនការ ឆ្ពោះទៅរកការដាក់បញ្ចូលគ្នានូវប្រសិទ្ធភាពធនធាន ការកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការអភិវឌ្ឍ និងអនុវត្តឱ្យស្របជាមួយនិងក្របខ័ណ្ឌ Sendai (Sendai Framework) ដើម្បីការកាត់បន្ថយហានិភ័យរបស់គ្រោះមហន្តរាយពីឆ្នាំ២០១៥-២០៣០ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយនៅគ្រប់កម្រិតទាំងអស់"។

ដោយផ្អែកលើឯកសារជាតិ និងអន្តរជាតិខាងលើ ដែលបានផ្តល់នូវមូលដ្ឋានសម្រាប់រៀបចំចក្ខុវិស័យរួមនៃទីក្រុងសុខុដុមនីយកម្មនាពេលអនាគត ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង គួរបំផុសគំនិត និងផ្សព្វផ្សាយអំពី**គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងសម្រាប់ទីក្រុងនីមួយៗ។ តារាងទី ៤** ផ្តល់នូវបញ្ជីគោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងដែលមានសក្តានុពល។

ទោះជាយ៉ាងណាក៏ដោយ ទីក្រុងនីមួយៗនៅកម្ពុជា គឺមានលក្ខណៈល្អខុសពីគ្នា ជាមួយនឹងការកំណត់អាទិភាពផ្ទាល់ខ្លួន បញ្ហាប្រឈម និងឱកាស។ ទីប្រជុំជនមួយចំនួន មានតម្រង់ទិសឧស្សាហកម្មទេសចរណ៍ច្រើន ឯតំបន់ផ្សេងទៀតអាស្រ័យលើសកម្មភាពកសិកម្មដែលនៅជុំវិញ។ បញ្ហាប្រឈមលើផ្នែកបរិស្ថាន និងនិរន្តរភាពនឹងក្លាយជាលក្ខណៈល្អប្លែកទៅតាមទីតាំងនីមួយៗ។ ដោយអាស្រ័យលើលក្ខខណ្ឌជាក់លាក់នៃមជ្ឈមណ្ឌលទីក្រុងនីមួយៗ គោលដៅទាំងនេះ នឹងមានភាពពាក់ព័ន្ធតិច ឬច្រើន។ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង នឹងមានសារៈសំខាន់ក្នុងការពិនិត្យគោលដៅទាំងនោះ និងការសម្រេចចិត្តមួយតំណាងឱ្យតំបន់អាទិភាពផ្សេងៗទៀត។

**តារាងទី ៤៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងដែលមានសក្តានុពល សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង**

- ការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ដោយកាត់បន្ថយផលប៉ះពាល់បរិស្ថាន
- ការលើកកម្ពស់បរិយាប័ន្នសង្គម ការកាត់បន្ថយភាពក្រីក្រ និងសុខុមាលភាពទីក្រុង
- ការពង្រឹងភាពធន់ទីក្រុង ទៅនឹងហានិភ័យធម្មជាតិ អាកាសធាតុ និងហានិភ័យផ្សេងទៀត
- ការធានាឱ្យបាននូវការប្រកួតប្រជែងទីក្រុង និងការទាក់ទាញដល់អាជីវកម្ម
- ការសន្សំសំចៃពីការប្រើប្រាស់ថាមពល និងធនធានឱ្យមានប្រសិទ្ធិភាព
- ការកាត់បន្ថយការបំភាយឧស្ម័នកាបូន ពីការប្រើប្រាស់ថាមពល ការដឹកជញ្ជូន និងសំណង់អគារបរិស្ថាន
- ការដាក់កម្រិតលើឥន្ធនៈផូស៊ីល ។

## ៤. ការពិនិត្យឡើងវិញលើវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍទីក្រុងបៃតង

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងនេះ នឹងបញ្ចូលការពិនិត្យឡើងវិញលើវិស័យគន្លឹះដែលមានសារៈសំខាន់ដល់សុខុមាលភាព និងមុខងារនៃតំបន់ក្រុង និងជាវិស័យដែលផ្តល់ឱកាសក្នុងការកាត់បន្ថយការបំពុលបរិស្ថាន និងការបំភាយឧស្ម័នកាបូនិចនៅក្នុងបរិយាកាសសម្រាប់បរិយាប័ន្នសង្គម និងការកាត់បន្ថយភាពក្រីក្រក្នុងសង្គមផងដែរ។ វិស័យទាំងនេះមាន៖

- ការរៀបចំផែនការក្រុង
- ភាពងាយរងគ្រោះរបស់តំបន់ទីក្រុង
- ថាមពល
- គមនាគមន៍
- សំណង់បរិស្ថាន
- ផ្នែកផលិតកម្ម (កម្មន្តសាល)
- ការគ្រប់គ្រងសំណល់រឹង
- ទីធ្លាសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌។

វិស័យទាំង ៨ ខាងលើនេះ បានរួមចំណែកដល់ការរៀបចំបង្កើតផែនការយុទ្ធសាស្ត្រទីក្រុងបៃតង ដូចមានបង្ហាញនៅក្នុង**រូបភាពទី៧** ខាងក្រោម។

**រូបភាពទី៧ វិស័យពាក់ព័ន្ធសំខាន់ៗ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង**



សម្រាប់វិស័យនីមួយៗខាងលើ ដំណើរការពិនិត្យលើការចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង នឹងមានពីរជំហានដូចខាងក្រោម៖

- ធ្វើការពិនិត្យលើស្ថានភាពបច្ចុប្បន្ននៃវិស័យនីមួយៗ ដែលអាចឱ្យយើងរៀបចំជាទម្រង់បច្ចុប្បន្នរបស់វិស័យទាំងនោះ និងសម្រាប់ធ្វើជាព័ត៌មានមូលដ្ឋាន ដើម្បីឱ្យមានភាពងាយស្រួលក្នុងការប្រៀបធៀប និងវាស់វែងពីការវិវត្តរបស់វិស័យទាំងនោះនាពេលអនាគត
- ធ្វើការព្យាករពីការវិវត្តរបស់វិស័យនីមួយៗទៅថ្ងៃអនាគត ដោយប្រើប្រាស់ចំហាកការព្យាករតាមទម្លាប់ធម្មតា (Business as Usual - BAU) សម្រាប់ថ្ងៃអនាគតដើម្បីបង្ហាញនូវផលវិបាកអវិជ្ជមានដែលនឹងអាចកើតឡើងក្នុងពេលបច្ចុប្បន្ន ប្រសិនបើគ្មានការកែប្រែបែបផែននៃការអនុវត្ត ឬការអភិវឌ្ឍនៅដដែល។ ការព្យាករនេះ ក៏ដើម្បីបង្ហាញពីបញ្ហានាពេលអនាគតដែលត្រូវជៀសវាងនៅពេលបញ្ហាមិនបានដោះស្រាយឱ្យបានសមស្រប។

ព័ត៌មានលម្អិតលើជំហាននីមួយៗ នៃវិស័យគន្លឹះទាំងប្រាំបី គឺត្រូវបានផ្តល់ជូនដូចខាងក្រោម៖

## ៤.១ ការរៀបចំផែនការក្រុង

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យរៀបចំផែនការក្រុង៖*

- ពិនិត្យឡើងវិញនូវឯកសារនគរូបនីយកម្មដែលមានស្រាប់ នៅកន្លែងទីក្រុងគោលដៅ (ប្រសិនបើមាន)
- វាយតម្លៃសកម្មភាពនគរូបនីយកម្មរបស់ក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ
- វាយតម្លៃការគាំទ្ររបស់គណៈកម្មាធិការជាតិគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម
- រៀបចំផែនទីឯកភាពក្រុងនៅតំបន់ដែលបានសាងសង់រួច ដោយប្រៀបធៀបជាមួយនឹងផែនទីចាស់
- រៀបចំបង្កើតនូវផែនទីនគរូបនីយកម្មរួម ដោយចាត់ថ្នាក់ឱ្យបានត្រឹមត្រូវនូវការប្រើប្រាស់ដីធ្លី (ផ្ទៃទឹក ទីធ្លា និងសួនច្បារសាធារណៈ កសិកម្មនៅតាមតំបន់ទីប្រជុំជន ហេដ្ឋារចនាសម្ព័ន្ធ លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម ការសម្រួលដល់ផ្នែកសុខាភិបាលនិងអប់រំ មជ្ឈមណ្ឌលរដ្ឋបាល បេតិកភ័ណ្ឌវប្បធម៌ និងបដិសណ្ឋារកិច្ច)
- គណនាដង់ស៊ីតេប្រជាជនក្នុងទីក្រុង (នាក់/ហិកតា)
- កំណត់ភាគរយអចលនទ្រព្យ ដែលមានប័ណ្ណកម្មសិទ្ធដីធ្លីឱ្យបានច្បាស់លាស់។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ការរីកសាយភាពនៃតំបន់ក្រុងដោយមិនមានលក្ខណៈត្រឹមត្រូវ ទំនងជានៅតែបន្ត ដោយសារមានការកើនឡើងនៃចំនួនប្រជាជនរស់នៅក្នុងតំបន់ក្រុង ក៏ដូចជាសកម្មភាពក្នុងក្រុង។ ការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ការអនុវត្តផែនការកំណត់តំបន់ក្រុង និងហេដ្ឋារចនាសម្ព័ន្ធក្រុង និងសេវាកម្មផ្សេងៗនៅតាមទីក្រុងនៅមានកម្រិត។

## ៤.២. ភាពងាយរងគ្រោះនៃតំបន់ទីក្រុង

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ននៅក្នុងវិស័យ ភាពងាយរងគ្រោះនៃតំបន់ទីក្រុង៖*

- រៀបចំផែនទីតំបន់ដែលរងផលប៉ះពាល់នៅរដូវទឹកជំនន់ ឬនៅពេលធ្លាក់ភ្លៀងខ្លាំង
- រៀបចំផែនទីតំបន់បៃតងនិងតំបន់ខៀវ និងប្រព័ន្ធតាមដានជលសាស្ត្រធម្មជាតិ( ស្ទឹង បឹង ដីសើម )
- វិភាគកំណើននៃការប្រែប្រួលធាតុអាកាសញឹកញាប់ខ្លាំង និងការធ្វើឱ្យខូចខាតលក្ខខណ្ឌរស់នៅរបស់មនុស្ស និងខូចខាតទ្រព្យសម្បត្តិ និងអាជីវកម្ម
- ពណ៌នាអំពីហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ សម្រាប់បង្ហូរទឹក និងទប់ស្កាត់ទឹកជំនន់
- រៀបចំសារពើភ័ណ្ឌនៃចំនួនគ្រួសារនៅតាមបណ្ដោយលូទឹកស្អុយ ឬលទ្ធភាពប្រើប្រាស់បង្គន់អនាម័យ និងអាងផ្ទុកទឹកសំណល់
- វិភាគវិធីសាស្ត្របន្សាំជាមួយទឹកជំនន់ក្នុងតំបន់ វិភាគការត្រៀមខ្លួនគ្រប់គ្រង ការឆ្លើយតប និងការដោះស្រាយបញ្ហាគ្រោះមហន្តរាយ។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ភាពដែលអាចនាំឱ្យមានការកើនឡើងនៃការបំពុលបរិស្ថាន បញ្ហាសុខភាព បញ្ហាសុវត្ថិភាពសាធារណៈ និងការខូចខាតទ្រព្យសម្បត្តិ ដែលជាលទ្ធផលពីបែបផែននៃការអភិវឌ្ឍនាពេលបច្ចុប្បន្ន។

## ៤.៣. ថាមពល

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យថាមពល៖*

- ធ្វើសវនកម្មប្រភពថាមពល៖ %បណ្ដាញអគ្គិសនី %ម៉ាស៊ូត %ប្រេងឥន្ធនៈ %ធ្យូង %ជីវម៉ាស់ %ថាមពលពន្លឺព្រះអាទិត្យ
- ធ្វើសវនកម្មការប្រើប្រាស់ថាមពល៖ %លំនៅដ្ឋាន %ពាណិជ្ជកម្ម %ឧស្សាហកម្ម %ការដឹកជញ្ជូន % សេវាសាធារណៈ
- កត់ត្រាប្រេកង់កំហាតថាមពល (ការខ្វះខាត ថាមពល) និងអស្ថេរភាពតង់ស្យុង (វ៉ុលតា មិនស្មើរថេរ)
- រៀបចំបញ្ជីសារពើភ័ណ្ឌអគារលំនៅដ្ឋាន និងអគារពាណិជ្ជកម្ម ដែលមានបំពាក់ម៉ាស៊ីនភ្លើង
- ស្រាវជ្រាវពីលទ្ធភាពទទួលបាន នូវការប្រើប្រាស់អំពូលភ្លើងដែលមានប្រសិទ្ធភាពថាមពល និងឧបករណ៍ប្រើប្រាស់ដែលសន្សំសំចៃថាមពល។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ភាពដែលអាចនាំឱ្យមានការកើនឡើងនូវតម្រូវការអគ្គិសនីច្រើនជាងមុន បើធៀបទៅនឹងលទ្ធភាពផ្គត់ផ្គង់ថាមពលដែលចេញពីប្រភពថាមពលលក្ខណៈបុរាណ។ វានឹងមានការកើនឡើងនូវកំហាតថាមពល (ការដាច់ចរន្តអគ្គិសនី) និងការកើនឡើងតម្លៃថាមពលអគ្គិសនី ដែលជាលទ្ធផលពីការពឹងផ្អែកលើការប្រើប្រាស់ថាមពលចេញពីប្រភពឥន្ធនៈ។

### ៤.៤. គមនាគមន៍ (ដឹកជញ្ជូន)

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យគមនាគមន៍៖*

- ផ្នែកដឹកជញ្ជូនចម្រុះ (%ប្រើប្រាស់រថយន្ត រ៉ឺម៉កកង់បី ម៉ូតូឌុប ម៉ូតូឯកជន និងកាណូត/សាឡាងចម្លងសាធារណៈ)
- ចំនួនរថយន្តនិងម៉ូតូដែលបានចុះបញ្ជី និងអត្រាកំណើនប្រចាំឆ្នាំ
- លក្ខណៈនៃប្រព័ន្ធដឹកជញ្ជូនសាធារណៈ (រថយន្តក្រុងខ្នាតតូច រថយន្តក្រុងខ្នាតធំ និងផ្លូវរត់របស់វា)
- ចំនួនករណីគ្រោះថ្នាក់ចរាចរណ៍ប្រចាំឆ្នាំ និងអត្រាអ្នកបាត់បង់ជីវិតក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ
- ផែនទីចំណុចកកស្ទះចរាចរណ៍សំខាន់ៗ (ផ្នែកផ្លូវគោក)
- ចំនួននៃកន្លែងចតរថយន្ត និងទីផ្លាកណ្ដាលទីក្រុង
- គំនូសសម្រាប់អ្នកដំណើរឆ្លងកាត់ផ្លូវក្នុងទីក្រុង និងស្ថានភាពនៃចញ្ចើមផ្លូវសម្រាប់ថ្មើរជើង
- ស្ថានភាពនៃច្បាប់ចរាចរណ៍ និងការអនុវត្តច្បាប់
- កម្រិតនៃការបំពុលខ្យល់ (NOx, SOx, COx, ចំហេះ...) ក្នុងតំបន់កកស្ទះចរាចរណ៍ និងផលប៉ះពាល់ដែលនាំឱ្យមានជម្ងឺផ្លូវដង្ហើម។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ភាពដែលអាចមានការកើនឡើងនូវការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរណ៍ និងខាតពេលវេលាក្នុងការធ្វើដំណើរទៅមក ទាំងនេះគឺជាលទ្ធផលនៃការពឹងផ្អែកលើការប្រើប្រាស់រថយន្តឯកជន និងម៉ូតូផ្ទាល់ខ្លួនច្រើនពេក។

### ៤.៥. សំណង់បរិស្ថាន

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យសំណង់បរិស្ថាន៖*

- ធ្វើសារពើភ័ណ្ឌនៃប្រភេទអគារដូចជា៖ ផ្ទះលក់ដូរ វីឡាទោល អគារសម័យអាណានិគម ផ្ទះប្រពៃណីខ្មែរ ភូមិបណ្ដែតទឹក និងសំណង់អនាធិបតេយ្យ
- ភាពអាចរកបាននៃលំនៅដ្ឋានដែលមានតម្លៃទាប
- ស្ថិតិអគារ/លំនៅដ្ឋានខូចខាត ដោយសារភ្លើងឆេះ និងអាកាសធាតុ
- ចំនួនអ្នកស្លាប់ និងអ្នកជំងឺ ដោយសារតែសំណង់អគារគ្មានខ្យល់ចេញចូល (ស្ត្រេស និងក្ដៅ)
- ភាពអាចរកបាននៃដីសម្រាប់លំនៅដ្ឋាន និងការអភិវឌ្ឍលំនៅដ្ឋានផ្សេងទៀត។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ភាពដែលអាចនាំឱ្យមានកង្វះបច្ចេកទេសក្នុងការសាងសង់លំនៅដ្ឋាន ភាពអាចរកបាននូវលំនៅដ្ឋាន និងលំនៅដ្ឋានដែលមានតម្លៃសមរម្យនិងមានផាសុខភាព ជាលទ្ធផលពីរបៀបសាងសង់ និងម៉ូតរបស់អាគារក្នុងក្រុងបច្ចុប្បន្ន។

### ៤.៦. ផ្នែកផលិតកម្ម (កម្មន្តសាល)

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យផលិតកម្ម (កម្មន្តសាល)៖*

- ប្រភេទឧស្សាហកម្មតាមវិស័យ
- ទីតាំងនៅក្នុង ឬនៅជិតតំបន់ក្រុង
- វត្ថុធាតុដើម៖ ប្រភព និងចំនួន
- វិធីសាស្ត្រផលិត - ប្រភេទ និងអាយុនៃឧបករណ៍
- ចំនួនដែលផលិតបាន
- ការប្រើប្រាស់ថាមពល និងការប្រើប្រាស់ទឹក
- ការបង្កើត និងបែងចែកសំណល់
- អតិថិជន ឬអ្នកទិញទំនិញ (តំបន់ ជាតិ អន្តរជាតិ...)។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ភាពដែលអាចកើនឡើងនូវការបំពុលបរិស្ថាន ការបង្កើតសំណល់ និងការប្រើប្រាស់ថាមពល ជាលទ្ធផលបានមកពីការបន្តដំណើរការចង្វាក់ផលិតកម្មក្នុងលក្ខណៈបច្ចុប្បន្ន។

### ៤.៧ ការគ្រប់គ្រងសំណល់រឹង (សំរាម)

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យការគ្រប់គ្រងសំណល់រឹង៖*

- ភាគរយនៃតំបន់ក្រុងដែលមានប្រព័ន្ធប្រមូលសំរាម
- អង្គភាព និងការគ្រប់គ្រងសេវាកម្មប្រមូលសំរាម
- ពិត៌ណ៌នាអំពីបញ្ហាសំរាម និងបណ្ដឹងរបស់ប្រជាជន រួមមានតំបន់ដែលមិនបានប្រមូលសំរាម និងការដឹកជញ្ជូនសំរាមមិនទាន់ និងផលប៉ះពាល់ទៅលើប្រភពទឹកធម្មជាតិ
- សមាសភាព និងបរិមាណនៃសំណល់ផ្ទះបាយ - %សំណល់អាហារ ប្លាស្ទិច ក្រដាស កញ្ចក់ ដែកកំណាត់ អេឡិចត្រូនិច
- ភាគរយ នៃសំណល់ចេញពីគ្រួសារ គ្រឹះស្ថានពាណិជ្ជកម្ម និងគ្រឿងផលិតឧស្សាហកម្ម
- កម្រៃ នៃសេវាប្រមូល និងសំអាតសំរាម (បើមាន)
- ឆន្ទៈរបស់គ្រួសារនីមួយៗ ក្នុងការបង់កម្រៃបន្ថែម ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាប្រមូលសំរាម
- ពិពណ៌នាអំពី ការប្រមូល និងការកែច្នៃសំណល់ក្រៅផ្លូវការ
- ប្រភេទនៃការបោះចោលសំរាមចុងក្រោយ (យកទៅចាក់ចោល ឬរៀបចំឱ្យមានកន្លែងចោលសំរាមដែលមានអនាម័យត្រឹមត្រូវ)។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- ភាពដែលនាំឱ្យមានការគំរាមកំហែងដល់សុខភាពសាធារណៈ និងបរិស្ថាន ប្រសិនបើប្រព័ន្ធគ្រប់គ្រងសំណល់មិនត្រូវបានកែលម្អទេនោះ។

## ៤.៨. ទីធ្លាសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌

*ទម្រង់សណ្ឋាននៃស្ថានភាពបច្ចុប្បន្ន នៅក្នុងវិស័យ ទីធ្លាសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌៖*

- ភាគរយនៃតំបន់ទីធ្លា/សួនច្បារសាធារណៈ និងកន្លែងកំសាន្ត និងរបាយទីធ្លាទាំងអស់នៅក្នុងទីក្រុង
- សារពើភ័ណ្ឌនៃជីវចម្រុះទីក្រុង រួមមានប្រភេទសត្វនិងរុក្ខជាតិក្នុងស្រុក តំបន់ដីសើមធម្មជាតិ បឹង ស្រះ និងប្រឡាយ
- សារពើភ័ណ្ឌ នៃអគារ និងតំបន់បេតិកភ័ណ្ឌវប្បធម៌ រួមមានអគាររដ្ឋបាល និងអគារសាសនាដែលជាកម្មសិទ្ធិរបស់រដ្ឋ និងរបស់ឯកជន
- វិសាលភាពនៃវិស័យកសិកម្មក្នុងទីក្រុង និងរបាយរបស់វានៅក្នុងទីក្រុង។

*ការព្យាករតាមទម្លាប់ធម្មតា (BAU) សម្រាប់ថ្ងៃអនាគត*

- កង្វះខាតនៃតំបន់បៃតង និងទីធ្លាសាធារណៈដែលមានលក្ខណៈបៃតង ដែលជាលទ្ធផលនៃការបន្តការពង្រីកទីក្រុងតាមទម្រង់បច្ចុប្បន្ន។ ការបាត់បង់នៃអគារបេតិកភ័ណ្ឌវប្បធម៌ គឺដោយសារការទុកចោល និងការវាយកំទេចធ្វើសំណង់អគារថ្មី។

## ៥. ការកំណត់គោលដៅអភិវឌ្ឍន៍បៃតង និងសកម្មភាពអាទិភាព សម្រាប់វិស័យនគរូបនីយកម្មសំខាន់ៗ

ការពិនិត្យឡើងវិញនូវវិស័យនគរូបនីយកម្មសំខាន់ៗ នឹងផ្តល់ឱ្យក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង កែតម្រូវឡើងវិញនូវគោលដៅអភិវឌ្ឍន៍ទីក្រុងបៃតង (ដូចបានពិភាក្សានៅក្នុង**ផ្នែកទី៣**) ដើម្បីកំណត់**គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងជាក់លាក់និងសកម្មភាពអាទិភាព**។ ការបង្ហាញជូនខាងក្រោម គឺជាបញ្ជីគោលដៅអភិវឌ្ឍន៍ទីក្រុងបៃតង ដែលបានស្នើឡើង ហើយដែលនឹងត្រូវយកមកកែសម្រួល និងកំណត់ឱ្យបានប្រសើរជាងមុន តាមរយៈក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង ដោយយោងទៅលើបញ្ហាប្រឈមជាក់ស្តែងនៃទីតាំងក្រុងនីមួយៗ។

### សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យនគរូបនីយកម្ម

- ការពង្រីកតំបន់ទីប្រជុំជនក្រុង ត្រូវធ្វើឱ្យឆ្ងាយពីតំបន់ដែលងាយទទួលរងគ្រោះថ្នាក់ធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះទឹកជំនន់ ឬតំបន់ឆ្នេរដែលមានការសិករិចរឹល
- ធ្វើផែនការសម្រាប់រៀបចំតំបន់ទីក្រុងមួយដែលមានលក្ខណៈតូច ប៉ុន្តែមានការបញ្ចេញឧស្ម័នកាបូនតិច សម្រាប់តំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលសមស្រប
- កាត់បន្ថយអប្បបរមានូវការបំពុលរបស់សកម្មភាពទីក្រុងទៅលើតំបន់កសិកម្មជុំវិញ
- បញ្ចៀសឱ្យបាននូវការជាប់ក្នុងស្ថានភាពមួយដែលការប្រើប្រាស់ថាមពលមានតម្លៃថ្លៃ ថាមពលដែលមិនមានប្រសិទ្ធភាព និងប្រព័ន្ធនៃការបំពុលក្នុងទីក្រុង។

### សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យ ភាពងាយរងគ្រោះរបស់ទីក្រុង

- កំណត់តំបន់សម្រាប់រក្សាជាទីធ្លាសាធារណៈលក្ខណៈបៃតង និងតំបន់មានប្រព័ន្ធទឹកធម្មជាតិ
- ចំនួនគ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅចេញពីតំបន់រងគ្រោះដោយសារទឹកជំនន់
- កាត់បន្ថយការស្លាប់មនុស្ស ខូចខាតទ្រព្យសម្បត្តិ និងខាតបង់មុខជំនួញដោយសារទឹកជំនន់
- បង្កើនលទ្ធភាពទទួលបានការរក្សាអនាម័យ នៅតាមផ្ទះគ្រួសារនីមួយៗ។

### សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យថាមពល

- មានប្រភពថាមពលដែលអាចទុកចិត្តបាន សម្រាប់យកមកប្រើប្រាស់បានពេញមួយឆ្នាំ
- ការកើនឡើងនូវភាគរយក្នុងការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ សម្រាប់ដាំទឹក កង្ហារ និងបំលែងជាអគ្គីសនីប្រើប្រាស់
- ការថយចុះភាគរយក្នុងអាំងតង់ស៊ីតេប្រើប្រាស់ថាមពលនៅតាមលំនៅដ្ឋាន មជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម និងសេវាកម្មសាធារណៈ
- ការកើនឡើងភាគរយ នៃប្រសិទ្ធភាពថាមពលនៅតាមលំនៅដ្ឋាន វិស័យពាណិជ្ជកម្ម និងសេវាកម្ម
- បង្កើនផលិតកម្មអគ្គីសនីតាមតំបន់ និងកាត់បន្ថយការពឹងផ្អែកលើម៉ាស៊ីនភ្លើង

### សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យដឹកជញ្ជូន

- ការកាត់បន្ថយចំនួនភាគរយ នៃការស្លាប់ និងពិការដោយសារគ្រោះថ្នាក់ចរាចរណ៍
- ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

- កាត់បន្ថយការបំពុលខ្យល់នៅតំបន់កកស្ទះចរាចរណ៍ ឬអនុវត្តស្តង់ដារគុណភាពខ្យល់ជាតិ ឬអន្តរជាតិ
- ការកើនឡើងនូវភាគរយក្នុងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- លុបបំបាត់ការចតរថយន្តនៅតាមផ្លូវដើរ ឬចំណីផ្លូវ
- អនុវត្តច្បាប់ ឬផាកពិន័យដល់អ្នកចតរថយន្តនៅតាមផ្លូវ
- បង្កើនភាពទទួលបានក្នុងការធ្វើដំណើរសម្រាប់ប្រជាជនក្រីក្រ និងជនពិការ
- បង្កើនផ្លូវសម្រាប់ថ្មើរជើង
- បង្កើនតំបន់ជិះរថយន្តក្រុងដោយឥតគិតថ្លៃ។

## សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យសំណង់បរិស្ថាន

- មានអគារ/លំនៅដ្ឋានដែលមានការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព និងធន់ទៅនឹងគ្រោះធម្មជាតិកាន់តែច្រើន
- ធ្វើឱ្យប្រសើរឡើង ឬការលប់បំបាត់តំបន់អនាធិបតេយ្យតែម្តង ដោយផ្តល់ជូនលំនៅដ្ឋានមានតំលៃសមរម្យ
- បង្កើននូវផាសុខភាព និងភាពដែលអាចរស់នៅបាន តាមរយៈការរចនាម៉ូដអាគារឱ្យកាន់តែមានភាពប្រសើរឡើង។

## សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យផលិតកម្ម (កម្មន្តសាល)

- ការផ្លាស់ប្តូរខ្សែចង្វាក់ផលិតកម្ម ទៅជាការផលិតតាមបែបបៃតងទំនើប
- កាត់បន្ថយអាំងតង់ស៊ីតេ នៃការប្រើប្រាស់ថាមពល (ទៅតាមប្រភេទឧស្សាហកម្ម)
- កាត់បន្ថយនូវការបង្កើតសំណល់ សារជាតុពុល និងសំណល់ដែលមានសារជាតុគ្រោះថ្នាក់
- បង្កើននូវលក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារសម្រាប់កម្មករ កាត់បន្ថយហានិភ័យពីការធ្វើការងារ និងលក្ខខណ្ឌសុខភាពដែលទាក់ទងនឹងការងារ។

## សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យគ្រប់គ្រងសំណល់រឹង (សំរាម)

- ពង្រីកវិសាលភាពប្រមូលសំរាមឱ្យបាន ១០០% នៃតំបន់ទីក្រុង
- បង្កើនភាគរយនៃការប្រមូល និងការកែច្នៃសំណល់នៅត្រឹមឆ្នាំ២០២០ និង២០៣០
- បង្កើនភាគរយ នៃការកាត់បន្ថយសំរាម តាមរយៈការកំណត់ពីប្រភពនាំឱ្យមានសំរាម
- មានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដែលបង្កលក្ខណៈងាយស្រួលនៅតាមផ្ទះគ្រួសារនីមួយៗនៅក្នុងការបែងចែក និងកែច្នៃសំណល់ និងការប្រើប្រាស់ឡើងវិញ
- ផ្តល់លក្ខខណ្ឌ និងប្រតិបត្តិការអនាម័យ នៅទីតាំងចោលសំរាមចុងក្រោយ
- ប្តេជ្ញាចិត្តក្នុងការបំលែងសំណល់ទៅជាថាមពល
- ដាក់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច តាមរយៈការគ្រប់គ្រងសំណល់រឹង។

## សំណើ៖ គោលដៅអភិវឌ្ឍន៍ទីក្រុងបៃតងនៅក្នុងវិស័យទីធ្លាសាធារណៈ និងបេតិកភ័ណ្ឌវប្បធម៌

- បង្កើនភាគរយសម្រាប់តំបន់ទីធ្លាសាធារណៈ សួនច្បារ និងកន្លែងកំសាន្ត សាធារណៈ
- អភិរក្សជីវចម្រុះ និងការប្រើប្រាស់ដីចម្រុះ ទៅតាមច្រករបៀងបៃតង និងខៀវ

- អភិរក្សទីតាំង និងអាគារបេតិកភ័ណ្ឌវប្បធម៌
- អភិរក្ស ឬរក្សាតំបន់ក្រុងដែលមានលក្ខណៈកសិកម្ម

**សកម្មភាពជាអាទិភាព៖** តាមរយៈការស្នើឱ្យមានការកំណត់គោលដៅទៅតាមវិស័យសំខាន់ៗនៃតំបន់ក្រុងដែលបានរៀបរាប់ខាងលើ ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង អាចកំណត់ចេញបានជាផែនការសកម្មភាពជាអាទិភាព ដែលនឹងនាំឱ្យសម្រេចបាននូវគោលដៅដែលបានស្នើឡើងតាមវិស័យនីមួយៗ។ សកម្មភាពជាអាទិភាព គួរតែត្រូវបានបែងចែកជាប្រភេទសកម្មភាពសម្រាប់រយៈពេលខ្លី សម្រាប់រយៈពេលមធ្យម និងសម្រាប់រយៈពេលវែង ដែលអាចសម្រេចបានតាមរយៈការធ្វើចំណាត់ថ្នាក់អាទិភាព និងការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ទីក្រុងបៃតង។

## ៦. ការកំណត់នូវគម្រោងវិនិយោគអភិវឌ្ឍន៍ទីក្រុងបៃតង

ក្រោមក្របខ័ណ្ឌនៃទិសដៅ គោលដៅ និងគោលបំណងនៃការអភិវឌ្ឍបៃតង ដែលបានកំណត់ និងបង្កើតឡើងរួមគ្នា ក្រុមការងារសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង **នឹងធ្វើការកំណត់នូវគម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍ទីក្រុងបៃតង** ណាដែលអាចសម្រេចនូវគោលដៅទាំងនោះបាន ព្រមទាំងអាចអនុវត្តន៍នូវផែនការសកម្មភាពក្នុងការឆ្លើយតបទៅនឹងភាពខ្វះខាត និងកត្តាប្រឈមទៅតាមវិស័យនីមួយៗ។

ការប៉ាន់ស្មានមួយបានឱ្យដឹងថា ការបំលែងពីតំបន់ជាយក្រុងទៅជាទីក្រុងប្រកបដោយនិរន្តរភាព និងបៃតងមួយ គឺជាដំណើរការដ៏វែងឆ្ងាយមួយ។ ដូច្នេះ ការធ្វើឱ្យតំបន់ជាយក្រុងមានលក្ខណៈបៃតង នឹងចាប់ផ្តើមពីគម្រោងបង្ហាញសាកល្បង ដើម្បីធ្វើតេស្តនូវវិធីសាស្ត្រថ្មីៗប្រកបដោយភាពច្នៃប្រឌិត និងបញ្ជាក់ពីលទ្ធភាពដែលអាចធ្វើទៅបាន ព្រមទាំងផលប្រយោជន៍នៃការអភិវឌ្ឍបៃតងនៅជាយក្រុងនោះផងដែរ។ ទាំងនេះអាចកំណត់បានថាគឺជា ***ការវិនិយោគ និងសកម្មភាពរយៈពេលខ្លី*** និងត្រូវបានចាត់ថ្នាក់ជា '**គម្រោងប្រភេទ ក**'។

គម្រោងទាំងនេះ នឹងបើកផ្លូវសម្រាប់ ***ការកែទម្រង់ស៊ីជម្រៅ*** ដ៏មានមហិច្ឆតា។ គម្រោងទាំងនេះ គឺត្រូវការពេលវេលា ដើម្បីធ្វើការរៀបចំ ទទួលបានការអនុញ្ញាត និងដើម្បីគេយកទៅអនុវត្ត ប៉ុន្តែវានឹងអាចផ្តល់ឱ្យទីក្រុងនូវក្របខ័ណ្ឌប្រកបដោយនិរន្តរភាពមួយ សម្រាប់ការគ្រប់គ្រងតំបន់ជាយក្រុងលើវិស័យ ដែលបានស្នើឡើង។ គម្រោងទាំងនេះ ត្រូវបានចាត់ថ្នាក់ជា '**គម្រោងប្រភេទ ខ**'។

ការរៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រទីក្រុងបៃតង គឺដើម្បីកំណត់ពីការកង្វះខាតនូវការយល់ដឹងមួយចំនួន ឧទាហរណ៍តំបន់ដែលការប្រមូលទិន្នន័យបន្ថែម និងការវិភាគ ត្រូវការធ្វើឡើងដើម្បីធ្វើផែនការ និងធ្វើគោលនយោបាយដោយយោងលើភស្តុតាងព័ត៌មាន។ ***លទ្ធផលជាចំណេះដឹង*** *(Knowledge products)* ត្រូវបានចាត់ថ្នាក់ជា '**គម្រោងប្រភេទ គ**'។

ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង នឹងកំណត់នូវគម្រោងវិនិយោគតាមវិស័យនីមួយៗ ដោយឆ្លើយតបទៅនឹងការស្នើសុំ និងអាទិភាព ដែលមានការចូលរួមយោបល់ពីអ្នកពាក់ព័ន្ធនៅក្នុងដំណើរការ។ នៅជំហាននេះ វាមានសារៈសំខាន់ណាស់ក្នុងការរួមបញ្ចូលនូវគ្រប់សមាសធាតុទាំងអស់តាមដែលអាចធ្វើបានព្រោះវាជា**ឱកាសដ៏ល្អសម្រាប់ការវិភាគគ្រប់ជ្រុងជ្រោយក្នុងដំណើរការកែប្រែតំបន់ក្រុង** ជាមួយនិងការបង្កើតនូវបញ្ជីគម្រោងវិនិយោគសម្រាប់ការអភិវឌ្ឍទីក្រុងបៃតង។ បញ្ជីគម្រោងវិនិយោគនេះ នឹងយកទៅធ្វើការពិនិត្យ និងធ្វើការកំណត់នូវអាទិភាពនៅជំហានក្រោយទៀត (**ផ្នែកទី ៧**)។

មានការលើកឡើងថា ការកំណត់គម្រោងវិនិយោគនៅជំហាននេះ (**ជំហានទី ៦**) គួរតែអនុវត្តនូវនិតិវិធីសាមញ្ញក្នុងការបរិយាយពីខ្លឹមសារគម្រោង **ដោយប្រើប្រាស់ទម្រង់ស្តង់ដារមួយ** (ដូចត្រូវបានបង្ហាញនៅក្នុង **តារាងទី ៥** ខាងក្រោម)។ ការណែនាំស្តីពីព័ត៌មានជាមូលដ្ឋានដែលត្រូវការសម្រាប់សរសេរនូវក្នុងតារាងទៅតាមចំណុចនីមួយៗ ក៏ត្រូវបានផ្តល់ជូននៅក្នុងតារាងផងដែរ។

***តារាងទី ៥៖ ទម្រង់ក្នុងការកំណត់គម្រោងវិនិយោគអភិវឌ្ឍន៍ទីក្រុងបៃតង***

| វិស័យ:<br>*សំដៅទៅលើវិស័យមួយក្នុងចំណោមវិស័យទីប្រជុំជនទាំង ៨* | ប្រភេទគម្រោង:<br>*ក, ខ ឬ គ ដូចនៅខាងលើ* |
|---|---|
| ឈ្មោះគម្រោង៖ *កំណត់ឈ្មោះគម្រោងវិនិយោគឱ្យបានច្បាស់ និងជាក់លាក់* | |
| គោលដៅទីប្រជុំជនបៃតងដែលចង់បាន៖ *សំដៅទៅលើគោលដៅបៃតងតាមវិស័យ ដូចដែលបានកំណត់ពីមុន* | |
| ការពិពណ៌នាពីគម្រោងបឋម៖ ២-៣ កថាខណ្ឌពិពណ៌នាពីមាតិកានៃគម្រោង | |
| ផលប្រយោជន៍បៃតងដែលរំពឹងទុកសម្រាប់ទីប្រជុំជន៖ *កំណត់នូវលទ្ធផលវិជ្ជមាននៃការអនុវត្តគម្រោង* | |
| *ទំនាក់ទំនងជាមួយនឹងវិស័យទីប្រជុំជនដ៏ទៃទៀត៖* ពិពណ៌នាពីផលប៉ះពាល់នៃវិស័យទីប្រជុំជនដទៃ ព្រមទាំងតើផលវិស័យទាំងនោះប៉ះពាល់ដោយរបៀបណា | |
| ទំនាក់ទំនងទៅនឹងគោលនយោបាយ និងផែនការសកម្មភាព៖ *សំដៅទៅលើគោលនយោបាយ និងកម្មវិធីជាតិ និងមូលដ្ឋាន* | |
| ទីតាំងដែលបានស្នើឡើង (ប្រសិនបើមាន)៖ *ឈ្មោះឃុំ ឬស្រុក* | |
| ដៃគូអនុវត្តន៍ដែលគ្រោងទុក៖ *អង្គការណាដែលចង់ចូលរួម* | |
| ប្រភពមូលនិធិដែលមាន៖ *សំដៅទៅលើប្រភពធនធានហិរញ្ញវត្ថុ* | |
| ឧបសគ្គដល់ការអនុវត្ត៖ *កំណត់នូវប្រភពនៃការរារាំងនៅមូលដ្ឋានមកលើគម្រោង* | |

នៅក្នុងផ្នែកបន្តបន្ទាប់ខាងក្រោម គឺជាឧទាហរណ៍នៃគម្រោងអាទិភាពលើវិស័យគន្លឹះទាំង៨ ជាមួយនឹងផលប្រយោជន៍ដែលបានរំពឹងទុក ព្រមទាំងប្រភពនៃព័ត៌មានបន្ថែម។

## ៦.១ ឧទាហរណ៍នៃការធ្វើផែនការទីប្រជុំជនគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក

ធ្វើការរៀបចំ ឬធ្វើបច្ចុប្បន្នភាពផែនការមេឱ្យបានទូលំទូលាយសម្រាប់តំបន់ទីក្រុងទាំងមូល រួមមានសង្កាត់ ឬខណ្ឌ ដែលសុទ្ធសឹងជាផ្នែកនៃសេដ្ឋកិច្ចរបស់តំបន់ក្រុងដូចគ្នា(ដូចមានបង្ហាញនៅក្នុង**រូបភាព ៨** ខាងក្រោម)

→ **ធ្វើឱ្យប្រសើរឡើងនូវកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើផែនការទីប្រជុំជន ព្រមទាំងផ្តល់ជូននូវការធ្វើផែនការប្រើប្រាស់ដីចម្រុះ**

កំណត់តំបន់ការពារដោយមិនឱ្យមាននូវសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬអាគារផ្សេងៗនោះឡើយ (តំបន់ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ធនធានធម្មជាតិដែលត្រូវការពារ តំបន់ទីធ្លាសាធារណៈ តំបន់បេតិកភ័ណ្ឌ និងបូជនីស្ថានវប្បធម៌)

→ **បញ្ចៀសនូវហានិភ័យផ្សេងៗកើតចេញពីការរំលោភបំពាន និងទប់ស្កាត់នូវរាល់សកម្មភាពអភិវឌ្ឍន៍ខុសច្បាប់**

រួមបញ្ចូលនូវសកម្មភាពអភិវឌ្ឍន៍បៃតងនៅក្នុងវិស័យទីប្រជុំជន ដោយយល់ពីស្ថានភាពទាំងមូល (ភាពងាយរងគ្រោះ ថាមពល សំណង់បរិស្ថាន កម្មន្តសាល សំណល់រឹង ទីធ្លាសាធារណៈ និងតំបន់បេតិកភ័ណ្ឌវប្បធម៌)

→ **អនុញ្ញាតឱ្យមានការធ្វើកាន់តែប្រសើរឡើងនូវផែនការបៃតងតាមវិស័យនៅគ្រប់កម្រិតតំបន់ជាយក្រុង**

បង្កើតផែនការកំណត់តំបន់ ដើម្បីអនុវត្តការប្រើប្រាស់ដីធ្លីចម្រុះ និងដង់ស៊ីតេប្រជាជនដោយយោងលើមុខងាររបស់ទីប្រជុំជន ស្របជាមួយនឹងការអនុញ្ញាត និងការអនុវត្តបទបញ្ញត្តិនានា។

→ **តម្រង់ទិសដៅនៃការអភិវឌ្ឍក្នុងតំបន់នាពេលអនាគត និងការតម្រង់ទិសឱ្យត្រូវនឹងទម្រង់ទីប្រជុំជន ឱ្យស្របជាមួយផែនការមេ**

*រូបភាពទី ៨៖ ផែនការមេនៃការប្រើប្រាស់ដីក្នុងទីក្រុងបាត់ដំបង ២០៣០*



*ប្រភព: របាយការណ៍ថ្នាក់បច្ចេកទេសស្តីពីផែនការមេនៃការប្រើប្រាស់ដីក្នុងក្រុងបាត់ដំបង ២០១៥*

*ប្រភពព័ត៌មានបន្ថែម*

- http://www.greengrowthknowledge.org/learning/green-city-development-toolkit.
- http://www.undp.org/content/undp/en/home/librarypage/environment-energy/toolkit-inclusive-green-growth.html
- http://gggi.org/report-urban-green-growth-strategies-for-indian-cities
- http://www.oecd.org/regional/green-growth-in-cities.htm.
- http://www.unicef.org/cambodia/PIN_URBAN_POOR_FA.PDF

## ៦.២ ឧទាហរណ៍នាពេលអនាគតរបស់ទីប្រជុំជនបៃតង និងផលប្រយោជន៍ដែលរំពឹងទុក

រួមបញ្ចូលនូវប្រព័ន្ធប្រឡាយទឹកបៃតង និងវិធីសាស្ត្រប្រព្រឹត្តកម្មសំណល់រាវ (ដូចជាការសាងសង់តំបន់ដីសើម ឬការប្រើប្រាស់តំបន់ដីសើមដែលមានស្រាប់) **(រូបភាព ៩)**

→ **កាត់បន្ថយទឹកជំនន់ និងការបំពុលបរិស្ថាន**

ថែរក្សា និងពង្រីកតំបន់បៃតង (ព្រំប្រទល់ទីប្រជុំជនបៃតង) សម្រាប់ពង្រឹងការគ្រប់គ្រងទឹកភ្លៀង និងផាសុខភាពរបស់ទីប្រជុំជន

→ **កាត់បន្ថយទឹកជំនន់ និងការបញ្ចេញកាបូន**

ស្តារឡើងវិញនូវប្រព័ន្ធជាវសាស្ត្រធម្មជាតិ (បឹង អូរ ព្រែក) ដើម្បីបង្កើតច្រករបៀងក្រុងខៀវ

→ **កាត់បន្ថយទឹកជំនន់ និងជួយឱ្យមានតុល្យភាពក្នុងការផ្គត់ផ្គង់ទឹកនៅគ្រប់រដូវ**

ពិនិត្យលើលទ្ធផលក្នុងការបង្កើតប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវតាមបែបវិមជ្ឈការ

→ **កាត់បន្ថយការបំពុលនៅអំឡុងពេលមានទឹកជំនន់**

ជំរុញការប្រើប្រាស់ប្រព័ន្ធអនាម័យតាមគ្រួសារ (household sanitation systems) **(រូបភាព ៩)**

→ **កាត់បន្ថយការបំពុលនៅអំឡុងពេលមានទឹកជំនន់**

អង្កេតលើការប្រើប្រាស់បង្គន់សាធារណៈដីសើម (public wetland toilets) ដូចជាការធ្វើបង្គន់អនាម័យសាធារណៈនៅទីក្រុងភ្នំពេញ

→ **កាត់បន្ថយការបំពុល និងរួមចំណែកដល់ការរីកចម្រើនរបស់តំបន់បៃតង**

រូបភាពទី ៩៖ បង្គន់ដីសើម និងបង្គន់អនាម័យបរិស្ថាន (eco-sanitary toilets)




http://b1b2.org/EcoSan/biotoilets2.htm

*ប្រភពព័ត៌មានបន្ថែម*

- www.epa.gov/owow/wetlands/pdf/ConstructedW.pdf
- water.epa.gov/type/wetlands/restore/upload/constructed-wetlands-design-manual.pdf
- water.epa.gov/type/wetlands/restore/upload/sub.pdf
- www.wetlands.org/PortalsZ0/publications/Book/Contructed_Wetlands-PDF.pdf
- www.wetlandworks.com
- www.wagga.nsw.gov.au/ data/assets/pdf_file/0018/4635/Lloyd_Study_Area2.pdf
- www.dews.qld.gov.au/ data/assets/pdf_file/0008/78128/qudm2013-provisional.pdf
- pacewater.com/services/stormwater-management/river-restoration/mountain-housemaster-drainage-plan-creek-restoration/
- www.water.wa.gov.au/PublicationStore/first/89891.pdf

## ៦.៣ ឧទាហរណ៍ លើវិស័យថាមពល នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក

រួមបញ្ចូលនូវលក្ខខណ្ឌសម្រាប់ឧបករណ៍ និងសម្ភារៈដែលមានប្រសិទ្ធភាពថាមពលនៅក្នុងការអនុញ្ញាតក្នុងការសាងសង់ថ្មី

**→ កាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញកាបូន**

ប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ ដូចជា ថាមពលពន្លឺព្រះអាទិត្យ ជីវម៉ាស និងការបំលែងថាមពលចេញពីសំណល់

**→ កាត់បន្ថយការចំណាយរយៈពេលវែង និងការបញ្ចេញឧស្ម័នកាបូន**

បង្កើតការផ្សព្វផ្សាយសាធារណៈ ស្តីពីវិធីសាស្ត្រ សម្ភារៈ និងប្រដាប់ប្រើប្រាស់ (ចង្ក្រាន ម៉ាស៊ីនទឹកក្តៅ ទឹកត្រជាក់ និងអំពូល)ក្នុងការកាត់បន្ថយការប្រើប្រាស់ថាមពលជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម

**→ កាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញកាបូន**

ផ្តល់នូវគោលការណ៍ណែនាំស្តីពីការបំពាក់ឧបករណ៍ក្នុងផ្ទះ និងអាគារពាណិជ្ជកម្ម ជាមួយនឹងបែបបទប្រសិទ្ធភាព និងវិធានការក្នុងការសន្ទនាគ្នា (**រូបភាព ១០**)

**→ កាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញកាបូន**

*រូបភាពទី ១០៖ បន្ទះថាមពលពន្លឺព្រះអាទិត្យដែលដាក់នៅលើដំបូល*



*ប្រភពព័ត៌មានបន្ថែម*

- www.star8.com.au/contact-us/
- www.worldbank.org/en/news/feature/2014/02/18/energizing-green-cities-solutions-to-meet-demand-and-spark-economic-growth
- www.kamworks.com/

## ៦.៤ ឧទាហរណ៍លើវិស័យគមនាគមន៍ នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក

បង្កើតនូវចំណតរថយន្តបង់ថ្លៃ និងការអនុវត្តការយកកម្រៃលើចំណតតាមដងផ្លូវដោយគិតតាមប្រវែង

→ **កាត់បន្ថយការស្ទះចរាចរណ៍ និងបង្កើនប្រាក់ចំណេញដល់រាជធានី**

អនុវត្តន៍បទបញ្ញត្តិចរាចរណ៍ និងអនុវត្តផ្លាកសញ្ញាចរាចរណ៍

→ **កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការស្លាប់ ការកកស្ទះ ការបំពុលខ្យល់ និងការបញ្ចេញកាបូន**

ការអនុវត្តផ្លូវធ្វើដំណើរសម្រាប់រថយន្តក្រុងល្បឿនលឿនសម្រាប់ការធ្វើដំណើររបស់សាធារណៈ ផ្លូវដាច់ដោយឡែកសម្រាប់ម៉ូតូ និងរថយន្ត

→ **ជំរុញការប្រើប្រាស់សេវាកម្មដឹកជញ្ជូនសាធារណៈ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងការបំពុលខ្យល់**

ការសាកល្បងម៉ូតូកង់បី និងរថយន្តក្រុងសាធារណៈដើរដោយថាមពលពន្លឺព្រះអាទិត្យឱ្យបានច្រើនតាមដែលអាចធ្វើបាន នៅទូទាំងទីក្រុង

→ **កាត់បន្ថយការពឹងអាស្រ័យលើប្រេងឥន្ទនៈ ការបំពុលខ្យល់**

ផ្តល់នូវឧបករណ៍ធ្វើដំណើរដោយមិនប្រើម៉ាស៊ីនដូចជា កង់ និងការដើរថ្មើរជើង

→ **កាត់បន្ថយនូវការកស្ទះចរាចរណ៍ ការបំពុលខ្យល់ និងការបញ្ចេញកាបូន**

អនុវត្តនូវតំបន់ប្រើប្រាស់រថយន្តដោយសេរីនៅតំបន់ដែលកកស្ទះសំខាន់ៗ និងតំបន់ពាណិជ្ជកម្ម

→ **កាត់បន្ថយការបញ្ចេញកាបូន និងការបំពុល ដើម្បីបង្កើនការធ្វើដំណើរដោយថ្មើរជើង**

ផ្តល់នូវការលើកទឹកចិត្តសម្រាប់រថយន្តបៃតង ដូចជា រថយន្តហាយព្រីត ឬរថយន្តដើរដោយអគ្គីសនី

→ **កាត់បន្ថយការបំពុលខ្យល់ ការបញ្ចេញកាបូន និងកម្រិតរំខាន**

***រូបភាពទី ១១៖ ម៉ូតូរ៉ឺម៉កកង់បី ដើរដោយថាមពលពន្លឺព្រះអាទិត្យ***



*ប្រភព: www.star8.com.au*

*ប្រភពព័ត៌មានបន្ថែម*

- www.star8.com.au/contact-us/
- sustainabledevelopment.un.org/topics/transport/publications
- www.worldbank.org/en/topic/transport/brief/low-emission-transport
- www.newcitiesfoundation.org/smart-travel-sustainable-mobility-green-transport-cities/
- www.unep.org/resourceefficiency/Policy/ResourceEfficientCities/FocusAreas/SustainableTr ansportandAirPollution/tabid/101667/Default.aspx

## ៦.៥ ឧទាហរណ៍លើវិស័យសំណង់បរិស្ថាននៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍ដែលរំពឹងទុក

ត្រួតពិនិត្យ និងអនុវត្តច្បាប់ថ្មីស្តីពីការពង្រីកទីប្រជុំជន ដែលសង្កត់ធ្ងន់លើភាគរយនៃតំបន់សាងសង់ដោយយោងទៅតាមផ្ទៃដីសរុបរបស់តំបន់។

**→ ធ្វើឱ្យប្រាកដថាតំបន់ទំនេរខ្លះ គឺសម្រាប់ការធ្វើជាតំបន់បៃតង និងសម្រាប់ចាប់យកទឹកភ្លៀង**

ផ្តល់នូវគោលការណ៍ណែនាំបច្ចេកទេស សម្រាប់សាងសង់ផ្ទះ និងអាគារពាណិជ្ជកម្ម ដើម្បីបង្កើនប្រសិទ្ធភាពថាមពល បង្កើនខ្យល់ធម្មជាតិ ចាប់យកទឹកភ្លៀង និងបង្កើនភាពធន់នឹងគ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ (**មើលរូបភាព ១២**)។

**→ កាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញកាបូន ដោយបង្កើននូវភាពធន់ទៅនឹងទឹកជំនន់**

លិខិតបញ្ជាក់សាកល្បងលើអាគារ ដែលស្ថិតក្រោមកម្មាធិការបញ្ជាក់លើភាពឈានមុខគេលើការរចនាគិតគូរពីថាមពល និងបរិស្ថាន (LEED) ដូចជាគម្រោងបង្ហាញមួយសម្រាប់ធ្វើជាគំរូក្នុងការសាងសង់ផ្សេងទៀត។

**→ កាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញកាបូន**

នៅជុំវិញតំបន់ទីប្រជុំជន លើកកម្ពស់ការធ្វើឱ្យតំបន់អនាធិបតេយ្យឱ្យកាន់តែប្រសើរឡើង ការប្រើប្រាស់ប្រភេទសំណង់ប្រពៃណីដោយប្រើសម្ភារៈដែលមានក្នុងស្រុក កន្លែងរស់នៅខ្ពស់ៗ ប្រកខ្យល់ធម្មជាតិ និងគោលការណ៍ *feng shui* ។

**→ កាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញកាបូន ព្រមទាំងកាន់តែធន់ទៅនឹងទឹកជំនន់**

*រូបភាពទី ១២៖ អគារបៃតងនៅទីក្រុងភ្នំពេញ*



Source: *http://inhabitat.com/cambodias-new-stock-exchange-tower-has-dragon-scales/*

*ប្រភពព័ត៌មានបន្ថែម*

- www.star8.com.au/contact-us/
- www.tu-cottbus.de/projekte/de/megacity-hcmc/
- www.gdrc.org/uem/water/rainwater/introduction.html
- www.watercache.com/education/rainwater/
- www.akvopedia.org/wiki/Rooftop_rainwater_harvesting
- water.epa.gov/infrastructure/greeninfrastructure/gi_what.cfm#rainwaterharvesting

## ៦.៦ ឧទាហរណ៍លើវិស័យផលិតកម្ម (កម្មន្តសាល) នៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍រំពឹងទុក

រៀបចំឱ្យការកាត់បន្ថយសំណល់ឱ្យបានជាអតិបរមា ផលិតកម្មកាន់តែស្អាត ប្រសិទ្ធភាពថាមពល និងសុខភាពក្នុងការងារ (occupational health) ព្រមទាំងការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាពដោយមានការជួយជ្រុំជ្រែងពីការិយាល័យផលិតកម្មស្អាតជាតិ (National Cleaner Production Office) ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងដល់រោងចក្រនៅកម្ពុជា ឬសមាគមន៍រោងចក្រកាត់ដេរកម្ពុជា។

**→ កាត់បន្ថយការបំពុលបរិស្ថាន និងការបញ្ចេញកាបូនតិច ដើម្បីធ្វើឱ្យកាន់តែមានសុវត្ថិភាពលើលក្ខខណ្ឌការងារ និងជំងឺផ្សេងៗដែលកើតពីមុខងារមួយចំនួនតូច**

កំណត់នូវឱកាសក្នុងការដោះដូរសំណល់តាមដែលអាចធ្វើបាន ឧទាហរណ៍សំណល់ពីវិស័យឧស្សាហកម្មមួយអាចប្រើប្រាស់ជាធាតុចូលនៅក្នុងវិស័យផ្សេងទៀត (**មើលរូបភាព ១៣**)។

**→ កាត់បន្ថយការសាយភាយនៃការពង្រាយ សំណល់ទៅក្នុងបរិស្ថាន កាត់បន្ថយការប្រើប្រាស់វត្ថុធាតុដើម**

កំណត់មូលនិធិដែលអាចមានសម្រាប់ប្រសិទ្ធភាពថាមពល កាត់បន្ថយឱ្យបានជាអតិបរមានូវសំណល់ និងផលិតកម្មស្អាត តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការទំនួលខុសត្រូវសង្គមរបស់អតិថិជន និងអ្នកទិញផលិតផល។

**→ ឈ្មោះម៉ាកផលិតផល ត្រូវបានទទួលថាជាផលិតផលបៃតង និងមានមេត្រីភាពបរិស្ថាន**

*រូបភាពទី ១៣៖ វិធីសាស្ត្រដើម្បីដំណើរការផលិតកម្មស្អាត*




មើលលើដំណើរការដើម្បីកំណត់នូវបេក្ខជនដែលមានសក្តានុពល ប្រើចំហាយទឹកដើម្បីផលិតផលរួមគ្នា

*ប្រភព៖ UNIDO.org*

*ប្រភពព័ត៌មានបន្ថែម*

- www.unido.org/fileadmin/user_media/Services/Research_and_Statistics/WP152011_Ebook .pdf
- www.worldbank.org/en/news/feature/2013/11/19/energy-efficiency-the-fuel-for-low-carbon-urban-development
- www.cambodian-cpc.org/index.php/en/
- www.unep.org/gpwm/Portals/24123/images/Working%20group%20meeting/Waste%20Min imization.pdf

## ៦.៧ ឧទាហរណ៍លើវិស័យគ្រប់គ្រងសំណល់រឹងនៃគម្រោងទីក្រុងបៃតង និងផលប្រយោជន៍រំពឹងទុក

អនុវត្តគោលការណ៍ ៣Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ)

**→ កាត់បន្ថយសំណល់បញ្ចូលទៅទីលានចាក់សំរាម កាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិ និងការបញ្ចេញជាតិកាបូន**

ទាមទារឱ្យផ្ទះនីមួយៗធ្វើការបែងចែកសំណល់ជាមួយនឹងការប្ដេជ្ញាចិត្តក្នុងការប្រើប្រាស់ឡើងវិញ និងការចែកច្នៃដែលបានកំណត់រួចហើយ

**→ សន្សំសំចៃទូទៅ និងការពារបរិស្ថាន**

ជំរុញការកាត់បន្ថយសំណល់តាមរយៈការហាមលើការប្រើប្រាស់ថង់ប្លាស្ទិច និងការផ្ដល់នូវជម្រើសប្រើប្រាស់ថង់ដែលអាចប្រើប្រាស់បានច្រើនដង

**→ ការពារធនធានធម្មជាតិ និងជីវិតសត្វ**

បង្កើតនូវឧស្សាហកម្មផ្លូវការសម្រាប់កែច្នៃឡើងវិញ ដែលត្រូវការកម្លាំងពលកម្មពីវិស័យកែច្នៃសំណល់មិនផ្លូវការ (**មើលរូបភាព ១៤**)

**→ បង្កើនភាពមានការងារធ្វើ និងពង្រឹងសុខភាព និងសុវត្ថិភាពរបស់កម្មករ**

អនុវត្តការបំលែងសំណល់ទៅជាថាមពល

**→ កាត់បន្ថយការបញ្ចេញសំណល់ទៅទីលានចាក់សំរាម បង្កើនការផ្គត់ផ្គង់ថាមពល កាត់បន្ថយការបញ្ចេញកាបូន**

ជំរុញការវិនិយោគពីវិស័យឯកជនក្នុងការគ្រប់គ្រងសំណល់

**→ បង្កើនប្រសិទ្ធភាព និងការគ្របដណ្ដប់សេវាកម្មប្រមូលសំណល់**

ណែនាំនូវយុទ្ធសាស្ត្រពីពង្រីកការទទួលខុសត្រូវរបស់អ្នកផលិត

**→ បង្កើនការប្រើប្រាស់សំណល់ឡើងវិញ និងការកែច្នៃសំណល់ ព្រមទាំងកាត់បន្ថយការបង្កើតសំណល់**

***រូបភាព ១៤: អ្នកធ្វើការកែច្នៃសំណល់ឡើងវិញមិនផ្លូវការ***



*Source: www.robertharding.com*

*ប្រភពព័ត៌មានបន្ថែម*

- www.epa.gov/waste/nonhaz/municipal/wte/
- www.brightknowledge.org/knowledge-bank/geography-and-environment/features-and-resources/ waste-to-energy-pros-and-cons
- www.sita.co.im/energy-recovery/benefits-of-energy-from-waste
- www.epa.gov/waste/nonhaz/municipal/hierarchy.htm
- www2.epa.gov/recycle/recycling-basics

## ៦.៨ ឧទាហរណ៍លើទីធ្លាសាធារណៈ បេតិកភ័ណ្ឌវប្បធម៌ នៃគម្រោងទីក្រុងបៃតង និង ផលប្រយោជន៍រំពឹងទុក

បង្កើត និងអនុវត្តទៅតាមច្បាប់សម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌ (**មើលរូបភាព ១៥**)
**→ ថែរក្សាភាពចម្រុះ និងអត្តសញ្ញាណវប្បធម៌នៅក្នុងមូលដ្ឋាន បង្កើនប្រាក់ចំណេញពីទេសចរណ៍**

ណែនាំ ឬថែរក្សាច្រករបៀងរបស់ជីវចម្រុះ ដោយច្រករបៀងបៃតង និងខៀវ (**មើលរូបភាព ១៥**)
**→ កាត់បន្ថយផលកម្តៅនៅតាមទីប្រជុំជន ការបំពុលខ្យល់ និងការបញ្ចេញកាបូន ព្រមទាំងបង្កើនសោភ័ណ្ឌភាពរបស់សហគមន៍**

ណែនាំ ឬថែរក្សាសួនច្បារឯកជន និងកន្លែងធ្វើកសិកម្មនៅតាមទីប្រជុំជន
**→ កាត់បន្ថយផលប៉ះពាល់ពីកម្តៅមកលើទីប្រជុំជន និងលើកកម្ពស់សន្តិសុខស្បៀង**

### *រូបភាព ១៥: យុទ្ធសាស្ត្របណ្ដាញតភ្ជាប់បៃតង បាត់ដំបង ២០២០ អាគារការិយាល័យប្រៃសណីយ៍ នៅកណ្ដាលរាជធានីភ្នំពេញ*



*ប្រភព: ICEM GMS Report Series and Space for Architecture Cambodia*

## ប្រភពព័ត៌មានបន្ថែម

- www.depi.vic.gov.au/ data/assets/pdf_file/0003/300693/Guidance-Note-Feb-2015.pdf
- nac.unl.edu/buffers/docs/conservation_buffers.pdf
- https://www.coe.int/t/dg4/cultureheritage/cooperation/Kosovo/Publications/Guidelines-ENG.pdf
- www.gdrc.org/uem/water/rainwater/introduction.html
- www.watercache.com/education/rainwater/
- water.epa.gov/infrastructure/greeninfrastructure/gi_what.cfm#rainwaterharvesting

## ៧. កំណត់អាទិភាពគម្រោងអភិវឌ្ឍន៍ទីក្រុងបៃតង

តាមរយៈនេះ មិនមែនគម្រោងទាំងអស់ អាចត្រូវបានយកមកអនុវត្តន៍បានភ្លាមៗនោះទេ បញ្ជីគម្រោងវិនិយោគអភិវឌ្ឍន៍ទីក្រុងបៃតងទាំងអស់ ដែលបានមកពីជំហានទី៦ នឹងក្លាយជាប្រធានបទក្នុង**ដំណើរការកំណត់អាទិភាព និងការជម្រុះគម្រោងមួយចំនួន**។ ផ្នែកនេះ ផ្តល់នូវដំណើរការសំខាន់ៗ ដែលធ្វើឡើងដោយក្រុមអ្នកធ្វើផែនការទីក្រុងបៃតង ដើម្បីកំណត់សកម្មភាពអភិវឌ្ឍន៍បៃតងអាទិភាពសម្រាប់ការអនុវត្ត។

ក្របខ័ណ្ឌនេះ យកទៅអនុវត្តលើគម្រោង និងសកម្មភាពវិនិយោគរយៈពេលខ្លី (**គម្រោងប្រភេទ ក**)។ គម្រោងដែលជាប់ពាក់ព័ន្ធកំណែទម្រង់លើវិស័យផ្សេងៗ និងការអភិវឌ្ឍលទ្ធផលនៃចំណេះដឹង (**គម្រោងប្រភេទ ខ និងគ**) គឺមិនត្រូវបានដាក់ចូលក្នុងការកំណត់អាទិភាពនេះទេ ដោយសារគម្រោងទាំងនេះមិនត្រូវនឹងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសដូចនឹងគម្រោងវិនិយោគរយៈពេលខ្លីទេ។ គម្រោងប្រភេទ ខ និង គ ជាធម្មតាចំណាយតិចជាងគម្រោងវិនិយោគ ដោយបង្ហាញពីការកែទម្រង់លើគោលនយោបាយ ឬការសិក្សាស្រាវជ្រាវ ដែលទាមទារនូវការកំណត់អាទិភាពមួយ ព្រមទាំងមិនត្រូវការនូវលក្ខខណ្ឌដូចគ្នា ឬអាចនាំទៅរកផលប៉ះពាល់ដោយផ្ទាល់នោះទេ។

លក្ខណៈវិនិច្ឆ័យក្នុងការពិនិត្យជ្រើសរើស ត្រូវបំពេញនូវគោលបំណងដូចខាងក្រោម៖

- ទាក់ទងនឹងគោលបំណងសេដ្ឋកិច្ច បរិស្ថាន និងសង្គមរបស់ទីក្រុង
- កំណត់នូវសកម្មភាពអាទិភាព ដែលអាចអនុវត្តបាននៅក្នុងរយៈពេលខ្លី
- មានការងាយស្រួលក្នុងការយកទៅអនុវត្តដោយអ្នកមិនមានជំនាញជាមួយនិងព័ត៌មានមិនគ្រប់គ្រាន់លើគម្រោងជាក់លាក់ (អ្វីដែលនៅក្នុងជំហាននេះអាចត្រូវបានលម្អិត) និង
- មានតម្លាភាព មានគោលដៅ និងមានភាពរឹងមាំ។

លក្ខណៈវិនិច្ឆ័យក្នុងការពិនិត្យជ្រើសរើសដែលបានលើកឡើងសម្រាប់កម្មវិធីអភិវឌ្ឍន៍ទីប្រជុំជនបៃតងនៅកម្ពុជា គឺត្រូវបានបង្ហាញនៅ**តារាងទី ៦** ខាងក្រោម។

***តារាងទី ៦៖ លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃគម្រោងដែលបានស្នើឡើង***

| |
|---|
| ១. តម្រូវការ ឬការទាមទារ ឬអាទិភាពខ្ពស់ |
| ២. ការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រភពខាងក្រៅដែលអាចមាន (ភ្នាក់ងារអ្នកផ្តល់ជំនួយ និងក្រុមហ៊ុនឯកជន) |
| ៣. ផលប្រយោជន៍ក្នុងការសន្សំសំចៃការចំណាយ |
| ៤. គោលនយោបាយ និងបរិយាកាសស្ថាប័នគាំទ្រសម្រាប់ការអនុវត្តគម្រោង |
| ៥. បច្ចេកវិទ្យាសាកល្បង និង/ឬ គំរូការធ្វើជំនួញ និង/ឬវិធីសាស្ត្រគម្រោង |
| ៦. អ្នកដំណើរការ ឬអ្នកផ្គត់ផ្គង់អាចមានក្នុងស្រុកសម្រាប់ការអនុវត្តគម្រោង |
| ៧. ឥទ្ធិពលខ្ពស់ពីលើការបង្ហាញពី ការអភិវឌ្ឍបៃតង |
| ៨. ការកាត់បន្ថយភាពក្រីក្រ ឬការផ្តល់ផលប្រយោជន៍ដល់សង្គមទាំងមូល |
| ៩. ការផ្តល់ផលប្រយោជន៍ដោយបង្កើតជាការងារបៃតង |
| ១០. ការផ្តល់ផលប្រយោជន៍លើបរិស្ថាន |

ការសម្រេចចិត្តលើការកំណត់អាទិភាព ទាមទារនូវការប្រើប្រាស់ឧបករណ៍ជំនួយដល់ការធ្វើសេចក្ដីសម្រេចចិត្ត ដែលអាចគ្រប់ដណ្ដប់លើគោលបំណងជាច្រើនទាំងនេះបាន។ ការប្រើប្រាស់ឧបករណ៍សម្រាប់វិភាគពហុលក្ខណៈវិនិច្ឆ័យ (Multi-Criteria Analysis) បង្ហាញពីក្របខ័ណ្ឌមួយ សម្រាប់ធ្វើការណែនាំដល់ការធ្វើសេចក្ដីសម្រេចចិត្ត ហើយដែលអាចឆ្លើយតបទៅនឹងបញ្ហាផ្សេងៗ ដូចមានបង្ហាញក្នុង**តារាង៧**។

ការដាក់ពិន្ទុធ្វើឡើងដោយយោងលើព័ត៌មាន ដែលបង្ហាញនៅក្នុងឯកសារគម្រោងសម្រាប់គម្រោងស្នើសុំនីមួយៗ (**មើលតារាង៥**)។ ពិន្ទុគឺពីចន្លោះ០ ដល់ ៣ និងត្រូវផ្ដល់ទៅឱ្យគម្រោងនីមួយៗទៅតាមលក្ខណៈវិនិច្ឆ័យរៀងៗខ្លួនដែលមានពិន្ទុសរុប ៣០។ នៅក្នុងករណីដែលមិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីដាក់ពិន្ទុ ឬក៏ពិន្ទុប្រហាក់ប្រហែលលើគម្រោងមួយជាមួយនឹងលក្ខណៈវិនិច្ឆ័យនោះ គម្រោងមួយនោះគួរដាក់ពិន្ទុ ០ ដោយសារកង្វះព័ត៌មានដែលនាំឱ្យកើតមានហានិភ័យដល់ការអនុវត្តគម្រោង។ **តារាង៧** ផ្ដល់នូវលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃគម្រោង ដូចខាងក្រោម:

- **លក្ខណៈវិនិច្ឆ័យ** - ដាក់ឈ្មោះ ឬការពិពណ៌នាខ្លីពីលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃ
- **មូលហេតុ** - ពិពណ៌នាពីមូលហេតុក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យ អ្វីដែលជាបំណងរបស់លក្ខណៈវិនិច្ឆ័យ គឺដើម្បីធ្វើការវាយតម្លៃ និងវាស់វែងលើសូចនាករណាមួយ ដែលត្រូវបានប្រើប្រាស់ដើម្បីថ្លឹងថ្លែងពីដំណើរការរបស់គម្រោងជាមួយនឹងលក្ខណៈវិនិច្ឆ័យ
- **ការដាក់ពិន្ទុ** - ផ្ដល់នូវគោលការណ៍ណែនាំក្នុងការដាក់ពិន្ទុដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដើម្បីធ្វើឱ្យប្រសើរនូវការអនុវត្តជាប្រព័ន្ធ ក៏ដូចជាផ្ដល់នូវគោលការណ៍ណែនាំពីការដាក់ពិន្ទុក្នុងការវាស់វែងនូវសូចនាករណាមួយដែលទាក់ទង

ដើម្បីធ្វើការដាក់ពិន្ទុ និងការកំណត់គម្រោងអាទិភាព ការវិនិច្ឆ័យទាមទារធ្វើឡើងដោយយោងលើដំណើរការរបស់គម្រោង។ ការរចនា និងការបង្កើតដំណើរការ MCA អាចត្រូវការជាលក្ខណៈបច្ចេកទេស និងជាញឹកញាប់ទាមទារនូវធាតុចូលពីអ្នកជំនាញបច្ចេកទេស។

***តារាង៧. លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃដំណើរការ មូលហេតុ និងគោលការណ៍ណែនាំក្នុងការដាក់ពិន្ទុ***

| លក្ខណៈវិនិច្ឆ័យ | មូលហេតុ | ការដាក់ពិន្ទុ |
|---|---|---|
| ការកំណត់អាទិភាពពីអ្នកពាក់ព័ន្ធ | | |
| **១. តម្រូវការ ឬ អាទិភាព** | វិស័យខ្លះសម្រាប់ការវិនិយោគគម្រោងបង្ហាញជាតម្រូវការដ៏ចាំបាច់នៅក្នុងទីក្រុងជាជាងកន្លែងផ្សេងទៀត។ វិស័យដែលមានតម្រូវការខ្ពស់ជាង គឺទទួលបានអាទិភាពខ្ពស់។ ការវាយតម្លៃលើវិស័យអាទិភាព គឺធ្វើឡើងយោងទៅតាមការវាយតម្លៃបែបបរិមាណវិស័យនៃការកំណត់អាទិភាពពីអ្នកពាក់ព័ន្ធ។ | ០- គម្រោងជួយក្នុងវិស័យមួយ ដែលមិនមែនជាវិស័យអាទិភាពមួយ។<br>១- គម្រោងជួយវិស័យមួយ ដែលជាវិស័យអាទិភាពមធ្យមសម្រាប់អ្នកពាក់ព័ន្ធ<br>២- គម្រោងជួយក្នុងវិស័យមួយ ដែលជាវិស័យអាទិភាពខ្ពស់ក្នុងចំណោមអ្នកពាក់ព័ន្ធ |

| លក្ខណៈវិនិច្ឆ័យ | មូលហេតុ | ការដាក់ពិន្ទុ |
|---|---|---|
| | | ៣- គម្រោងនិយាយពីពហុវិស័យ យ៉ាងហោចណាស់ក៏មានវិស័យមួយដែលមានអាទិភាពខ្ពស់ដល់អ្នកពាក់ព័ន្ធ។ |
| លទ្ធភាពហិរញ្ញវត្ថុ | | |
| **២. ការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រភពខាងក្រៅដែលអាចមាន ( ភ្នាក់ងារអ្នកផ្តល់ជំនួយ និងក្រុមហ៊ុនឯកជន )** | តំបន់ទីប្រជុំជននៅកម្ពុជា ប្រឈមនឹងបញ្ហាហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ ទាក់ទងទៅនឹងតម្រូវការក្នុងការវិនិយោគ។ គម្រោង ដែលអាចទាក់ទាញថវិកាបានច្រើនពីប្រភពផ្សេងទៅឱ្យរដ្ឋាភិបាល ដូច្នេះគួរមានអាទិភាពខ្ពស់។ គម្រោងដែលមានពិន្ទុខ្ពស់ជាងគេ គឺជាគម្រោងដែលទាក់ទាញដល់វិស័យឯកជន។ ការវាយតម្លៃលើការគាំទ្របន្ថែមរបស់គម្រោងទៅលើជីវភាពរស់នៅប្រជាជន ផ្អែកលើការវាយតម្លៃបរិមាណវិស័យអំពីការបង្ហាញចំណាប់អារម្មណ៍លើគម្រោងស្រដៀងគ្នា។ | ០- គ្មានម្ចាស់ជំនួយ ឬវិស័យឯកជនណាដែលស្គាល់ ចាប់អារម្មណ៍ក្នុងការអភិវឌ្ឍគម្រោង<br>១- ចំណាប់អារម្មណ៍ខ្លះក្នុងវិស័យ ប៉ុន្តែគ្មានការអភិវឌ្ឍគម្រោងមិនផ្លូវការណាមួយកើតឡើងនោះឡើយ។<br>២- ចំណាប់អារម្មណ៍ខ្លះ ជាមួយនឹងសំណើគម្រោងខ្លះដែលបង្កើតឡើងដោយម្ចាស់ជំនួយ។<br>៣- ចំណាប់អារម្មណ៍លើគម្រោងដោយវិស័យឯកជន (និងចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយ)។ |
| **៣. ផលប្រយោជន៍ក្នុងការសន្សំសំចៃការចំណាយ** | គម្រោងខ្លះ នឹងត្រូវការសន្សំសំចៃលើការចំណាយ។ លក្ខណៈវិនិច្ឆ័យនេះ ផ្តល់នូវពិន្ទុខ្ពស់ដល់គម្រោងដែលមានសក្តានុពលក្នុងការសន្សំសំចៃលើការចំណាយច្រើន។ គម្រោងដែលមានដំណើរការមិនល្អ នឹងមិនមានការសន្សំសំចៃ។ គម្រោងដែលមានដំណើរការល្អប្រសើរ ផ្តល់ការសន្សំសំចៃដោយផ្តល់នូវជម្រើសក្នុងការវិនិយោគ (ក្នុងក្របខ័ណ្ឌនៅការចំណាយលើការវិនិយោគ និង/ឬ ការដំណើរការ និងការចំណាយលើការថែទាំ) ប៉ុន្តែនៅមិនមានការផ្តល់ផ្នែកហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពនៅឡើយ។ គម្រោងដែលមានដំណើរការល្អជាងគេ នឹងផ្តល់នូវការសន្សំសំចៃវិជ្ជមាន ឬ ប្រាក់ចំណូលចូល ដើម្បីទទួលបាននូវនិរន្តរភាពផ្នែកហិរញ្ញវត្ថុ នៅទីណាដែលអាចទទួល | ០- គម្រោងផ្តល់នូវការសន្សំសំចៃលើការចំណាយមធ្យម ឬអវិជ្ជមាន។<br>១- គម្រោងផ្តល់នូវការសន្សំសំចៃលើការចំណាយមានកម្រិត ឬផ្តល់ការសន្សំសំចៃលើការចំណាយពាក់ព័ន្ធគម្រោងជម្រើសផ្សេងៗ។<br>២- គម្រោងផ្តល់នូវការសន្សំសំចៃលើការចំណាយមធ្យម (រយៈពេលសងនៅចន្លោះពី៥ ទៅ១០ឆ្នាំ ឬការវាយតម្លៃបែបបរិមាណវិស័យលើការសន្សំសំចៃក្នុងការចំណាយ)។<br>៣- ការសន្សំសំចៃ (រយៈពេលសង < ៥ឆ្នាំ ឬការវាយតម្លៃបែបបរិមាណវិស័យនៃការរៀបចំស្ថាប័នលើការសន្សំសំចៃក្នុងការចំណាយ |

| លក្ខណៈវិនិច្ឆ័យ | មូលហេតុ | ការដាក់ពិន្ទុ |
|---|---|---|
| | បានព័ត៌មាន ដែលនេះត្រូវបានបង្ហាញដោយការវាយតម្លៃនៅពេល ប្រមូលទុនដុលបានវិញ។ | |
| **សមិទ្ធលទ្ធភាព/ការសង្គ្រោះដែលដាក់ឱ្យដំណើរការ និងបច្ចេកទេស** | | |
| **៤. គោលនយោបាយ និងបរិយាកាសស្ថាប័នក្នុងការគាំទ្រដល់ការអនុវត្តគម្រោង** | បរិយាកាសស្ថាប័នក្នុងការគាំទ្រមួយ គឺសំខាន់ដើម្បីឱ្យប្រាកដថាជោគជ័យនៃគម្រោងវិនិយោគមួយ។ លក្ខណៈវិនិច្ឆ័យនេះវាយតម្លៃពីទំហំនៃគោលនយោបាយ និងបរិយាកាសក្នុងស្ថាប័នសម្រាប់គម្រោង គឺអាចនឹងនាំទៅរកហានិភ័យដើម្បីសម្រេចគម្រោងប្រកបដោយជោគជ័យ។ វាទាមទារនូវការវាយតម្លៃបែបបរិមាណវិស័យលើគោលនយោបាយដែលពាក់ព័ន្ធ និងបរិយាកាសស្ថាប័ន។ | ០- ខ្វះការគាំទ្រពីគោលនយោបាយចាំបាច់ និងបរិយាកាសស្ថាប័នមិនគ្រប់គ្រាន់។<br>១- ការគាំទ្រពីគោលនយោបាយចាំបាច់ និងការរៀបចំស្ថាប័នសម្រាប់ដំណើរការប្រកបដោយប្រសិទ្ធភាព គឺនៅមានកង្វះខាត ឬមិនត្រូវបានអនុវត្ត ព្រមទាំងដើម្បីកាត់បន្ថយភាពដែលអាចសម្រេចបានរបស់គម្រោង។<br>២- ការគាំទ្រផ្នែកគោលនយោបាយដោយពេញចិត្ត និងការរៀបចំស្ថាប័នដើម្បីអាចដំណើរការប្រភេទគម្រោងនេះ ទោះបីជាមិនទាន់ច្បាស់នៅឡើយ ប៉ុន្តែពួកវាគឺសមល្មមដើម្បីអាចសម្រេចគម្រោងបាន។<br>៣- មានការកំណត់ដ៏ត្រឹមត្រូវ និងរឹងមាំ ព្រមទាំងបទបញ្ញត្តិដែលអាចអនុវត្តបាន ការគាំទ្រផ្នែកគោលនយោបាយច្បាស់លាស់ ការរៀបចំស្ថាប័នច្បាស់លាស់ និងសមត្ថភាពដាក់ស្តែងសម្រាប់អនុវត្តគម្រោងដែលបង្កើនលទ្ធភាពក្នុងការសម្រេចបានរបស់គម្រោង។ |
| **៥. បច្ចេកវិទ្យាសាកល្បង និង/ឬ គំរូការធ្វើជំនួញ និង/ឬ** | ដំណោះស្រាយបៃតងជាញឹកញាប់ពាក់ព័ន្ធទៅការអនុវត្តនូវជម្រើស បច្ចេកវិទ្យាដែលមិនធម្មតា គំរូនៃការធ្វើជំនួញដែលមានការកែច្នៃ និងវិធីសាស្ត្រនៃការអនុវត្តគម្រោង។ ការណែនាំនូវបច្ចេកវិទ្យា គំរូនៃការធ្វើជំនួញ និងវិធីសាស្ត្រនូវការអនុវត្តគម្រោងថ្មីធ្វើឱ្យ | ០- មិនមានបទពិសោធន៍ដែលត្រូវបានគេស្គាល់ណាមួយនោះទេពីបច្ចេកវិទ្យា/គំរូនៃការធ្វើជំនួញ/វិធីសាស្ត្រក្នុងការអនុវត្តគម្រោង នៅប្រទេសកម្ពុជា ឬបរិបទស្រដៀងគ្នា (ឧ. នៅក្នុងប្រទេសដែល |

| លក្ខណៈវិនិច្ឆ័យ | មូលហេតុ | ការដាក់ពិន្ទុ |
| --- | --- | --- |
| **វិធីសាស្ត្រគម្រោង** | គម្រោងជួបនូវហានិភ័យដោយជៀសមិនរួច។ ការវាយតម្លៃ គឺធ្វើឡើងដោយផ្អែកទៅលើការពិនិត្យឡើងវិញបែបបរិមាណវិស័យនៅក្នុងការអនុវត្តនូវបច្ចេកវិទ្យា គំរូនៃការធ្វើជំនួញ និងវិធីសាស្ត្រនៃការអនុវត្តគម្រោងស្រដៀងគ្នា។ | មានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប)។<br>១- បទពិសោធន៍អន្តរជាតិលើបច្ចេកវិទ្យា/គំរូនៃការធ្វើជំនួញ/វិធីសាស្ត្រក្នុងការអនុវត្តគម្រោង ដែលមានស្រាប់ ប៉ុន្តែមិនមានបទពិសោធន៍ដែលត្រូវបានគេដឹងណាមួយសម្រាប់ប្រភេទនេះគម្រោងនៅប្រទេសកម្ពុជា។<br>២- បទពិសោធន៍របស់កម្ពុជានៅមានកម្រិត ទោះបីជាបច្ចេកវិទ្យា/គំរូនៃការធ្វើជំនួញ/វិធីសាស្ត្រក្នុងការអនុវត្តគម្រោងត្រូវបានបង្ហាញនៅទីកន្លែងផ្សេងនៅស្ថានភាពស្រដៀងគ្នានោះដែរ។<br>៣- ការបង្ហាញពីបទពិសោធន៍សំខាន់របស់កម្ពុជាទៅលើបច្ចេកវិទ្យា/គំរូនៃការធ្វើជំនួញ/វិធីសាស្ត្រក្នុងការអនុវត្តគម្រោង។ |
| **៦. អ្នកដំណើរការ ឬអ្នកផ្គត់ផ្គង់ដែលអាចមានក្នុងស្រុកសម្រាប់ការអនុវត្តគម្រោង** | អ្នកដំណើរការ/អ្នកផ្តល់គម្រោងដែលមានសមត្ថភាពផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ គឺចាំបាច់សម្រាប់គម្រោងដើម្បីបន្តប្រកបដោយប្រសិទ្ធភាព។ ការវាយតម្លៃគឺធ្វើឡើងដោយយោងលើការវាយតម្លៃបែបបរិមាណនៃអ្នកដំណើរការ ឬវិស័យឯកជនដែលមានបទពិសោធន៍។ | ០- ក្នុងចំណោមអ្នកដំណើរការ ឬអ្នកផ្គត់ផ្គង់សំខាន់ មានសមត្ថភាព/បទពិសោធន៍ជាក់ស្តែង ដើម្បីយកគម្រោង។<br>១ - មានអ្នកផ្គត់ផ្គង់ក្នុងតំបន់ប្រកបដោយបទពិសោធន៍ជាក់ស្តែង ទោះបីជាមិនមានអ្នកដំណើរការ ឬអ្នកផ្គត់ផ្គង់ក្នុងស្រុកក៏ដោយ។<br>២- មានអ្នកដំណើរការ ឬអ្នកផ្គត់ផ្គង់ប្រកបដោយបទពិសោធន៍ខ្លះនៅកម្ពុជា។<br>៣- អ្នកដំណើការ ឬអ្នកផ្គត់ផ្គង់ដែលមានបទពិសោធន៍ត្រូវបានបណ្តុះបណ្តាលយ៉ាងល្អនៅកម្ពុជា។ |
| **ផលប៉ះពាល់នៃគម្រោង** | | |
| **៧. ឥទ្ធពលខ្ពស់ពីការផ្សព្វផ្សាយ** | គម្រោងវិនិយោគបៃតងជាច្រើន នឹងបង្ហាញពីវិធីថ្មីៗក្នុងការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទីប្រជុំជន ឬទំនិញផ្សេងទៀត។ | ០- មិនមានសក្តានុពលណាមួយច្បាស់លាស់ឡើយសម្រាប់ការអនុវត្តបច្ចេក |

| លក្ខណៈ វិនិច្ឆ័យ | មូលហេតុ | ការដាក់ពិន្ទុ |
|---|---|---|
| **លើការអភិវឌ្ឍបៃតង** | ដូចជា ពួកគេអាចផ្តល់ជាឧទាហរណ៍សាកល្បងនៃបច្ចេកវិទ្យា វិធីសាស្ត្រ ឬគំរូមុខជំនួញដែលអាចត្រូវបានបង្កើតឡើងទូទាំងប្រទេស។ គម្រោងដែលមានសក្តានុពលខ្លាំងសម្រាប់ការអនុវត្តទូលំទូលាយ គួរក្លាយជាអាទិភាពចំបង។ ការវាយតម្លៃ គឺយោងទៅលើការវាយតម្លៃបែបបរិមាណនៃការចង់បានសំខាន់ៗសម្រាប់គម្រោងដែលស្រដៀងគ្នា និង/ឬមានទំហំនៃយន្តការអនុវត្តដែលចេញទៅ | វិទ្យា/គំរូមុខជំនួញ/វិធីសាស្ត្រអនុវត្តគម្រោងថ្នាក់ជាតិនោះទេ។<br>១- បច្ចេកវិទ្យា/គំរូមុខជំនួញ/វិធីសាស្ត្រអនុវត្តគម្រោងមានកម្រិតខ្លាំងលើសក្តានុពលភាពក្នុងការយកទៅអនុវត្តនៅកន្លែងផ្សេងទៀតនៅកម្ពុជា។<br>២- បច្ចេកវិទ្យា/គំរូមុខជំនួញ/វិធីសាស្ត្រអនុវត្តគម្រោងមានសក្តានុពលភាពមធ្យមសម្រាប់ការយកទៅអនុវត្តនៅស្ថានភាពស្រដៀងគ្នានៅកម្ពុជា។<br>៣- បច្ចេកវិទ្យា / គំរូមុខជំនួញ / វិធីសាស្ត្រអនុវត្តគម្រោងមានសក្តានុពលភាពច្បាស់លាស់ដើម្បីអនុវត្តនៅពាសពេញប្រទេស។ |
| **៨. ការកាត់បន្ថយភាពក្រីក្រ ឬការផ្តល់ផលប្រយោជន៍ដល់សង្គមទាំងមូល** | ការកាត់បន្ថយភាពក្រីក្រ និងការរួមបញ្ចូលនូវផលប្រយោជន៍សង្គម គឺជាទស្សនទានដ៏សំខាន់សម្រាប់ការអភិវឌ្ឍបៃតង។ ផលប្រយោជន៍ក្នុងការកាត់បន្ថយ ឬផលប្រយោជន៍ សង្គមទាំងមូល ដែលរំពឹងទុកកាត់តែធំ ( ឧ. ការប្រជុំពីតម្រូវការរបស់ក្រុមដែលមិនត្រូវបានគិតបញ្ចូល ដូចជា ស្ត្រី ក្រុមជនជាតិដើមភាគតិច និងជនបាត់បង់សមត្ថភាព ) នោះចំណាត់ថ្នាក់របស់គម្រោងកាន់តែខ្ពស់។ យោងតាមការវាយតម្លៃបែបបរិមាណវិស័យមួយនៃការកាត់បន្ថយភាពក្រីក្រ/ផលប្រយោជន៍សង្គមទាំងមូល។ | ០- គម្រោងមិនចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ឬផ្តល់ផលប្រយោជន៍រួម។<br>១- គម្រោងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ឬផលប្រយោជន៍ដល់សង្គមទាំងមូលដោយប្រយោលខ្លះ។<br>២- គម្រោងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ឬផលប្រយោជន៍ដល់សង្គមទាំងមូល( ដោយផ្ទាល់ និងប្រយោល )ខ្លះ<br>៣- គម្រោងចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ឬផលប្រយោជន៍ដល់សង្គមទាំងមូល( ដោយផ្ទាល់ និងប្រយោល ) ច្រើន។ |
| **៩. ការផ្តល់ផលប្រយោជន៍ដោយបង្កើតជាការងារបៃតង** | ការបង្កើតការងារ គឺជាផ្នែកគន្លឹះមួយនៃការអភិវឌ្ឍបៃតង។ ផលប្រយោជន៍នៃការបង្កើតការងារ គឺត្រូវបានវាយតម្លៃដោយយោងលើការវាយតម្លៃបែបបរិមាណ នៃការបង្កើតការងារទាំងបរិមាណ និងគុណភាពក្នុងអំឡុងវដ្តនៃគម្រោង។ | ០- គម្រោងផ្តល់ផលប្រយោជន៍ក្នុងការបង្កើតការងារ។<br>១- គម្រោងនឹងផ្តល់ចំនួនការងារក្នុងកម្រិតមួយនៅក្នុងដំណាក់កាលដំបូងនៃគម្រោង។ |

| លក្ខណៈវិនិច្ឆ័យ | មូលហេតុ | ការដាក់ពិន្ទុ |
|---|---|---|
| | | ២- គម្រោងនឹងផ្តល់ចំនួនការងារក្នុងកម្រិតមួយនៅក្នុងពេលអនុវត្តគម្រោង ឬចំនួនការងារដ៏ច្រើននៅក្នុងដំណាក់កាលដំបូងនៃគម្រោង។<br>៣- គម្រោងនឹងផ្តល់ចំនួនការងារដ៏ច្រើននៅដំណាក់កាលគម្រោង |
| **១០. ការផ្តល់ផលប្រយោជន៍លើបរិស្ថាន** | គម្រោងបៃតង ផ្តោតលើផលប្រយោជន៍ដល់បរិស្ថានដ៏ច្រើន។ ចំនួន និងទំហំនៃផលប្រយោជន៍ដល់បរិស្ថានកាន់តែធំ គម្រោងគួរតែទទួលបានអាទិភាពកាន់តែខ្ពស់។ ផលប្រយោជន៍ផ្នែកបរិស្ថានដែលត្រូវបានគិតគូរនៅក្រោមលក្ខណៈវិនិច្ឆ័យ បញ្ចូលនូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកាត់បន្ថយការបំពុលខ្យល់នៅមូលដ្ឋាន ការកាត់បន្ថយការបំពុលទឹក ការកាត់បន្ថយសំណល់រឹង ការកាត់បន្ថយភាពងាយរងគ្រោះ និងពង្រឹងជីវៈចម្រុះ។ ផលប្រយោជន៍បរិស្ថាន គឺត្រូវបានវាយតម្លៃបែបបរិមាណវិស័យ។ | ០- គម្រោងមិនមានផលប្រយោជន៍ដល់បរិស្ថាន។<br>១- គម្រោងមានផលប្រយោជន៍បរិស្ថានក្នុងកម្រិតមួយ សម្រាប់សូចនាករតែមួយគត់ក្នុងដំណើរការរបស់បរិស្ថាន ។<br>២- គម្រោងមានផលប្រយោជន៍បរិស្ថានច្រើន យ៉ាងហោចណាស់សម្រាប់សូចនាករក្នុងដំណើរការរបស់បរិស្ថាន។<br>៣- គម្រោងមានផលប្រយោជន៍បរិស្ថានច្រើន សម្រាប់ចំនួនសូចនាករច្រើនក្នុងដំណើរការរបស់បរិស្ថាន។ |

វានឹងក្លាយជាកត្តាសំខាន់ណាស់សម្រាប់ការកំណត់អាទិភាព និងការជ្រើសរើសជម្រុះគម្រោងដំបូងលើគម្រោងអភិវឌ្ឍន៍ទីក្រុងបៃតង ផ្អែកទៅលើគោលការណ៍ដែលមានគោលបំណងច្បាស់លាស់ មានការចូលរួម និងតម្លាភាព ដោយមានការចូលរួមពីគណៈកម្មាការដឹកនាំការរៀបចំផែនការទីក្រុងបៃតង ដើម្បីធានាពីភាពត្រឹមត្រូវរបស់ដំណើរការ។ ព័ត៌មានស្តីពីបញ្ជីគម្រោង ស្តីពីលក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើការជម្រុះគម្រោងដំបូង និងស្តីពីលទ្ធផលនៃការជ្រើសរើស គួរត្រូវបានធ្វើឡើងជាសាធារណៈតាមដែរអាចធ្វើបានតាមរយៈវិធីសាស្ត្រទំនាក់ទំនងរបស់ក្រុមការងារធ្វើផែនការទីក្រុងបៃតង។

**ដំណើរការកំណត់អាទិភាពគម្រោង គឺការកំណត់ឱ្យបានជាបញ្ជីគម្រោងជម្រុះលើកដំបូងមួយ** (short list of projects) (នៅចន្លោះពី៨ ទៅ១៦ គម្រោង) ដែលត្រូវបានពិចារណាថា មានអាទិភាពខ្ពស់ជាងគេសម្រាប់ការអនុវត្ត។ វានឹងអាស្រ័យលើក្រុមការងារធ្វើផែនការទីក្រុងបៃតង ដោយមានការអនុម័តពីគណៈកម្មការដឹកនាំ ដើម្បីសម្រេចថាតើបញ្ជីសម្រាំងនឹងត្រូវបញ្ចូលតែការវិនិយោគដែលមានសកម្មភាពរយៈពេលខ្លី ឬក៏នឹងត្រូវបញ្ចូលទាំងផលិតផលចំណេះដឹង (គម្រោងប្រភេទ គ)។ វាត្រូវបានផ្តល់យោបល់ថា គម្រោងបានចែកចេញជាការ កែទម្រង់លើវិស័យដែលមានភាពស្មុគស្មាញ (គម្រោងប្រភេទ ខ) ដែលត្រូវបានរក្សាទុកសម្រាប់ជំហានក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងបៃតង។

# ៨. ចំហាកនៃការអភិវឌ្ឍបៃតងនៅទីប្រជុំជន

គោលបំណងនៃការបង្កើតចំហាកសម្រាប់វិភាគ គឺដើម្បីជួយដល់អ្នកធ្វើផែនការឱ្យយល់ពីវិធានការដែលអាចអនុវត្តន៍បានចំពោះការអភិវឌ្ឍបៃតងក្នុងបរិបទផ្សេងៗគ្នានៃការវិនិយោគ។ ការវិភាគតាមចំហាកទាំងនេះ វានឹងជួយឱ្យយើងកំណត់ និងប៉ាន់ប្រមាណបានពីលទ្ធផលរំពឹងទុកនៅថ្ងៃអនាគតរយៈពេលវែងនៃការសម្រេចចិត្តអនុវត្តន៍លើវិធានការណាមួយនៃការអភិវឌ្ឍបៃតងនៅក្នុងទីក្រុង។ ចំហាកទាំងនេះ អាចឱ្យយើងផ្តោតការយកចិត្តទុកដាក់ និងវិភាគជាលក្ខណៈយុទ្ធសាស្ត្រទៅលើលទ្ធផលរួមរយៈពេលវែងរបស់គម្រោងវិនិយោគសម្រាប់ការអភិវឌ្ឍទីប្រជុំជន ជាជាងការផ្តោតការវិភាគទៅលើលទ្ធផលរយៈពេលខ្លី ឬភ្លាមៗរបស់គម្រោងវិនិយោគ។

យោងតាមការវិភាគលើ**ផ្នែកទី៣ ៤ និង៦** ការបង្កើតចំហាកការអភិវឌ្ឍបៃតងនៅទីប្រជុំជន គឺដើម្បីបង្កើតនូវការវិភាគព័ត៌មានមួយ ជាលក្ខណៈរៀបរាប់អំពីភាពប្រទាក់ក្រឡាគ្នានៃកត្តានីមួយៗ ពោលគឺរៀបរាប់ថាតើការអភិវឌ្ឍនាពេលបច្ចុប្បន្នមានការប្រែប្រួលនិងវិវត្តន៍បែបណាទៅថ្ងៃមុខ និងអំពីគោលនយោបាយ និងការវិនិយោគដែលអាចមានឥទ្ធិពលទៅលើការសម្រេចឱ្យបាននូវលទ្ធផលនៃការអភិវឌ្ឍបៃតងនៅក្នុងក្របខ័ណ្ឌចំហាកទាំងនោះដោយមានការវាស់វែងច្បាស់លាស់។

ដោយសារមានការខ្វះខាតនូវប្រព័ន្ធទិន្នន័យជាតួរលេខពាក់ព័ន្ធទៅនឹងសូចនាករបរិស្ថាននៅក្នុងបរិបទប្រទេសកម្ពុជា និងដោយមានការលំបាកក្នុងការបង្កើតតួរលេខឱ្យបានគ្រប់ជ្រុងជ្រោយសម្រាប់វិភាគព្យាករពីលទ្ធផលអនាគត ការវិភាគបែបចំហាក គឺភាគច្រើនជាលក្ខណៈគុណភាពវិស័យ និងបរិយាយជាជាងប្រើប្រាស់តួលេខ។ នៅទីណាមានតួលេខដែលអាចទទួលយកបាន ឬគួរឱ្យទុកចិត្ត តួលេខទាំងនេះអាចត្រូវបានបញ្ចូលទៅក្នុងការវិភាគចំហាក បើទោះជាការវិភាគចំហាកផ្តោតសំខាន់ក្នុងការបង្កើតនូវរូបភាពប្រទាក់ក្រឡានៃកត្តា ឬសូចនាករបរិស្ថានសំខាន់ៗ នៃដំណើរការឆ្ពោះទៅរកការអភិវឌ្ឍដោយប្រាកដប្រជា។

## ៨.១ ប៉ារ៉ាម៉ែត្រសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្រសម្រាប់ការបង្កើតចំហាក

**ផ្នែកទី២** កំណត់ពីការរំពឹងទុកលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងប្រជាសាស្ត្រសម្រាប់ទីក្រុង។ ការកំណត់នេះ គឺជាទូទៅយោងទៅលើការធ្វើផែនការ និងការព្យាករ ដែលបានទទួលស្គាល់ជាផ្លូវការសម្រាប់ទីក្រុងរួមមាន៖

- ប្រជាសាស្ត្រ (ឧ. ចំនួនប្រជាជន ទំហំគ្រួសារ និងសមាសភាព)
- សេដ្ឋកិច្ច (ឧ. ផ.ស.ស នៅក្នុងទីប្រជុំជន សមាសភាពតាមវិស័យ ការវិនិយោគ និងការធ្វើជំនួញ) និង
- សេដ្ឋកិច្ចសង្គម (ឧ.ផ.ស.ស. សម្រាប់ម្នាក់ៗ កម្រិតចំណូល អត្រាភាពក្រីក្រ។

កត្តាទាំងនេះ គឺត្រូវបានចាត់ទុកជាប៉ារ៉ាម៉ែត្រ ដោយសារតែកត្តាផ្សេងៗទៀត មិនត្រូវបានគិតថាអាចមានឥទ្ធិពលលើការប្រែប្រួលការវិភាគចំហាកបាន ឬថាកត្តាទាំងនោះមិនមានតួលេខនៅក្នុងអំឡុងពេលនៃការវិភាគលើចំហាក។ ម្យ៉ាងទៀត កត្តាដូចជា កំណើនប្រជាជន កំណើនសេដ្ឋកិច្ច និងកំណើនប្រាក់ចំណូល នៅតែបានប្រើប្រាស់ដូចគ្នាជុំវិញការវិភាគបែបចំហាកទាំងអស់។ មូលហេតុចម្បងបីសំខាន់ៗដើម្បីបង្កើតប៉ារ៉ាម៉ែត្រទាំងអស់នេះ រួមមាន៖

- គម្រោង គឺត្រូវបានបង្កើតជាផ្លូវការ ហើយមូលហេតុចម្បងមួយ គឺថាគម្រោងមានការទទួលយកបានជាលក្ខណៈនយោបាយ
- ដោយមានការសន្មត់ថា តួលេខនៃប៉ារ៉ាម៉ែត្រទាំងនេះ នឹងត្រូវបានប្រើប្រាស់ឱ្យដូចគ្នាជាមួយនឹងការវិភាគចំហាកនានា វានឹងធ្វើឱ្យមានភាពល្អប្រសើរក្នុងការផ្តោតទៅលើការស្ថានភាពអនុវត្ត និងដំណើរការអភិវឌ្ឍបរិស្ថាន និងថាតើកិច្ចអន្តរាគមន៍មួយណាដែលគួរឱ្យទុកចិត្តបាន អាចជួយធ្វើឱ្យមានភាពប្រសើរឡើងនៃស្ថានភាពអនុវត្ត និងដំណើរការអភិវឌ្ឍន៍បរិស្ថានដែរឬទេ ដោយមិនធ្វើឱ្យប៉ះពាល់ដល់គោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច
- នៅក្នុងបង្កើតការវិភាគចំហាករយៈពេលវែង ដំណើរការ ឬវិធានក្នុងការអភិវឌ្ឍអាចត្រូវបានគេបង្កើតឡើងដើម្បីធ្វើការញែកចេញនូវផលប៉ះពាល់មកលើសង្គម និងបរិស្ថានក្នុងរយៈពេលវែងដោយពិចារណាលើដំណើរឆ្ពោះទៅរកការអភិវឌ្ឍដោយចាប់ផ្តើមធ្វើការផ្តល់យោបល់ត្រឡប់ទៅក្នុងសូចនាករដំណើរការសេដ្ឋកិច្ច និងសង្គមកិច្ច។ ប៉ុន្តែនៅក្នុងរយៈពេលមួយ (ជាធម្មតា ១០ ឆ្នាំ) កិច្ចអន្តរាគមន៍លើការអភិវឌ្ឍបៃតងនៅត្រឹមកម្រិតថ្នាក់ក្រុង គឺហាក់ដូចជាមិនមានឥទ្ធិពលណាមួយគួរឱ្យកត់សម្គាល់នៅក្នុងដំណើរការផ្លាស់ប្តូររចនាសម្ព័ន្ធទ្រង់ទ្រាយធំនោះទេ

## ៨.២ ការកំណត់និយមន័យលើ ការវិភាគចំហាក

ការវិភាគចំហាក ៣ប្រភេទ ត្រូវបានកំណត់ឡើងដោយបង្ហាញពីលទ្ធភាពជាក់ស្តែងនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍បៃតងក្នុងអំឡុងពេលធ្វើផែនការ។ ការវិភាគចំហាក ទាំង ៣ប្រភេទ រួមមាន៖

- **ការព្យាករតាមទម្លាប់ធម្មតា** (BAU) ចំហាកនេះ បង្ហាញពីការបន្តនៃនិន្នាការបច្ចុប្បន្ន។ ក្នុងន័យម៉្យាងទៀត គឺការវិភាគដោយគិតថាមិនមានការកែទម្រង់គោលនយោបាយ និងស្ថាប័នសាធារណៈ មិនមានការអនុវត្តលើផែនការនៅក្នុងទីប្រជុំជន និងមិនមានកិច្ចអន្តរាគមន៍លើការអភិវឌ្ឍបៃតងផ្សេងទៀតជាជាងអ្វីដែលអាចនឹងធ្វើដំណើរការទៅមុខ។
- **ការធ្វើគម្រោងសាកល្បងលើការអភិវឌ្ឍបៃតង** ចំហាកនេះ បង្ហាញពីការអនុវត្តការធ្វើកំណែទម្រង់ផែនការ និងគោលនយោបាយ ដែលបានបង្កើតនាពេលបច្ចុប្បន្ន ក៏ដូចជាការអនុវត្តនូវគម្រោងវិនិយោគរយៈពេលខ្លីដែលបានកំណត់នៅក្នុង**ផ្នែកទី៧**។ ក្នុងន័យម៉្យាងទៀត ការបោះជំហានដ៏សំខាន់ ធ្វើឡើងនៅក្នុងលក្ខខណ្ឌបញ្ញត្តិនៃសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងវិធីសាស្ត្រអភិវឌ្ឍន៍បៃតង ត្រូវបានយកទៅធ្វើជាគម្រោងសាកល្បងនៅទីកន្លែងដែលបានជ្រើសរើសរួច។
- **ការបញ្ជ្រាបការអភិវឌ្ឍបៃតង** ចំហាកនេះ បង្ហាញពីការអនុវត្តការអភិវឌ្ឍបៃតងនៅទូទាំងទីក្រុង ដោយរួមបញ្ចូលទាំងការបង្កើតផែនការ និងគោលនយោបាយបច្ចុប្បន្ន ដែលស្របតាមគោលដៅនៃការអភិវឌ្ឍបៃតង ការបង្កើតកំណែទម្រង់គោលនយោបាយ និងស្ថាប័នសំខាន់ៗជុំវិញវិស័យទីប្រជុំជន ជាពិសេសការអភិវឌ្ឍបៃតង និងការពង្រីកទីក្រុងចេញពីវិធីសាស្ត្រនៃការអភិវឌ្ឍបៃតង ដែលត្រូវបានកំណត់នៅក្នុង**ផ្នែកទី៧**។

មុននឹងបង្កើតការវិភាគតាមបែបចំហាកទាំងនេះឡើង ចំហាកនីមួយៗ គួរតែផ្តល់នូវនិយមន័យឱ្យបានច្បាស់លាស់ពីអ្វីដែលបានសន្មត់ទុកជាមុន តាមរយៈការបង្កើតឡើងដោយគោលនយោបាយតាមវិស័យ ការរៀបចំស្ថាប័ន ការរៀបចំផែនការ និងគម្រោងវិនិយោគដែលនឹងត្រូវកំណត់ឡើង។

*ការបង្កើតចំហាក*

ចំហាកទាំងនេះ នឹងបរិយាយពីភាពប្រទាក់ក្រឡាគ្នា ដោយធ្វើការបង្ហាញលម្អិតនៃលទ្ធផលរំពឹងទុកសម្រាប់ការអនុវត្ត និងដំណើរឆ្ពោះទៅរកការអភិវឌ្ឍ សម្រាប់យកទៅវាស់វែងពីដំណើរការនៃការអភិវឌ្ឍបៃតង។ ការពិភាក្សាលើចំហាក គឺត្រូវបានធ្វើឡើងដូចខាងក្រោម៖

**១. ការប្រើប្រាស់ធនធាន៖** ការពិនិត្យលើការប្រើប្រាស់ធនធាន ដោយរួមបញ្ចូលទាំងការពិនិត្យឡើងវិញពីនិន្នាការក្នុងការប្រើប្រាស់ធនធាននៅទីប្រជុំជន ដោយផ្ដោតទៅលើវិស័យថាមពល និងទឹក។ លំហូរនៃសម្ភារៈផ្សេងទៀត គឺមិនត្រូវបានគិតបញ្ចូលទេ ដោយព័ត៌មានមិនមានគ្រប់គ្រាន់ ហើយការប្រើប្រាស់ថាមពល និងទឹក តំណាងឱ្យក្ដីកង្វល់ដ៏ធំមួយ នៅក្នុងបរិបទប្រទេសកម្ពុជា។

- ក. ថាមពល៖ បង្កើតចេញជានិន្នាការក្នុងការប្រើប្រាស់ថាមពល ដែលបង្ហាញពីភាពអាចប្រែប្រួលលើការផ្គត់ផ្គង់ និងការប្រើប្រាស់ថាមពល។ ផ្នែកនេះ ក៏គួរពិចារណាលើថាមពលដែលមានទាក់ទងនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- ខ. ទឹក៖ បង្កើតចេញជានិន្នាការក្នុងការប្រើប្រាស់ទឹក គិតទាំងការពិចារណាក្នុងការផ្គត់ផ្គង់ និងការផ្លាស់ប្ដូរក្នុងលំនាំនៃការប្រើប្រាស់ ព្រមទាំងកត្តាជំរុញ។

**២. ការបំពុល៖** ផ្ដោតទៅលើផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន ដែលកើតចេញពីសកម្មភាពនៃការអភិវឌ្ឍនៅទីប្រជុំជន។

- **ក. ការបំពុលខ្យល់នៅតាមតំបន់៖** ផលប៉ះពាល់កើនឡើងជាលំដាប់ពីសកម្មភាពនៅទីប្រជុំជន ទៅលើសមាសភាព និងបរិមាណនៃការបំភាយជាតិពុលក្នុងខ្យល់ ផលវិបាកទៅលើគុណភាពខ្យល់ និងផលវិបាកលើបរិស្ថានទីប្រជុំជន និងសុខភាពសាធារណៈ។
- **ខ. ការបំពុលនៅក្នុងទឹក៖** ផលប៉ះពាល់ជារួមដែលកើតចេញពីសកម្មភាពនៃការអភិវឌ្ឍទីប្រជុំជន ដូចជាសារជាតុពុល និងបរិមាណនៃការបញ្ចេញសំណល់ពីប្រភពវិស័យឧស្សាហកម្ម ដែលនាំឱ្យមានផលវិបាកទៅលើគុណភាពទឹក និងលទ្ធភាពនៃទឹក ហើយទាំងនេះនឹងនាំឱ្យមានផលប៉ះពាល់ទៅលើបរិស្ថានទីប្រជុំជន និងសុខភាពរបស់មនុស្ស (ជាពិសេសផ្ដោតទៅលើផលវិបាកទៅលើផ្ទៃទឹកនៅក្នុងទីក្រុង)។
- **គ. សំណល់រឹង៖** ផលប៉ះពាល់ជារួមដែលកើតចេញពីសកម្មភាពនៃការអភិវឌ្ឍទីប្រជុំជន ដូចជាសារជាតុពុល និងបរិមាណនៃការបញ្ចេញសំណល់រឹង និងសំណល់ដែលមានសារជាតុគ្រោះថ្នាក់ ព្រមទាំងផលវិបាកទៅលើកគុណភាពទឹក បរិស្ថានទីប្រជុំជន និងសុខភាពសាធារណៈ។

**៣. ទម្រង់ និងមុខងារទីប្រជុំជន៖** ផ្នែកនេះមើលទៅលើអន្តរកម្មរវាងនិន្នាការនៃការអភិវឌ្ឍ និងមុខងារទីប្រជុំជនជាមួយនឹងដំណើរការអភិវឌ្ឍបរិស្ថាន និងការគំរាមកំហែងលើបរិស្ថាន (ដូចជាទឹកជំនន់ និងការប្រែប្រួលនៃសីតុណ្ហភាព)។ នៅក្នុងផ្នែកនេះ អាចធ្វើទៅបានតាមរយៈការកំណត់ពីតំបន់ក្នុងទីក្រុង ដែលលំនាំ នៃការអភិវឌ្ឍនៅក្នុងតំបន់ទីក្រុងទាំងនោះមានលក្ខណៈខុសៗគ្នា និងពិនិត្យថាតើសកម្មភាពសេដ្ឋកិច្ចនានា ដែលកើតឡើងនៅក្នុងតំបន់ទាំងនោះមានផលប៉ះពាល់ទៅលើបរិស្ថាន និងមុខងាររបស់ទីប្រជុំជនដែរឬទេ។ ជាធម្មតា ការវិភាគនេះ នឹងបែងចែកទីក្រុងទៅជាតំបន់ ដែលមានទម្រង់ និងមុខងារខុសៗគ្នាមួយ ដូចជាតំបន់ស្នូលនៃប្រជុំជនក្នុងទីក្រុង និងតំបន់នៅជុំវិញតំបន់ទីប្រជុំជន។

**៤. ភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម** - ផ្នែកនេះមើលទៅលើនិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ការគិតគូពីបញ្ហាសង្គមគ្រប់ជ្រុងជ្រោយ និងការកាត់បន្ថយភាពក្រីក្រនៅក្នុងទីក្រុង។ ផ្នែកនេះ គឺផ្តោតការយកចិត្តទុកដាក់ទៅលើលទ្ធភាពទទួលបាន ផ្ទះសម្បែងដែលមានតម្លៃសមរម្យ ការថែរក្សាអនាម័យ ការប្រមូលកាកសំណល់រឹង (សំរាម) និងថាមពលនិរន្តរភាព។ គួរលេខពាក់ព័ន្ធទៅនឹងសមភាពយេនឌ័រ និងការព្យាករពីការវិវត្តន៍គួរតែត្រូវបានយកមកប្រើប្រាស់ក្នុងការវិភាគពីលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបាននូវសេវាកម្មសង្គមទាំងនោះ។ នៅក្នុងផ្នែកនេះផងដែរ ក៏នឹងមានការវិភាគពីលទ្ធផលដែលអាចទទួលបានពីការអភិវឌ្ឍបៃតងសម្រាប់ក្រុមប្រជាជនដែលមានប្រាក់ចំណូលទាប។

**៥. សេចក្តីសង្ខេប** - ផ្នែកនេះបង្ហាញពីសេចក្តីសង្ខេបខ្លីមួយនៃការវិភាគចំហាក និងផលវិបាករបស់វា ក្នុងការគិតពិចារណា ឬក៏ការវិភាគពីការអភិវឌ្ឍសេដ្ឋកិច្ចឱ្យកាន់តែធំទូលាយជាងមុនទាក់ទងនឹងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍនៅរយៈពេលយូរ។

## ៨.៣ ប្រភពព័ត៌មានបន្ថែម

- www.greengrowthknowledge.org/sites/default/files/downloads/resource/Green-Growth-in-Practice-GGBP_0.pdf
- www.greengrowthknowledge.org/sites/default/files/downloads/resource/GGKP%20Moving%20towards%20a%20Common%20Approach%20on%20Green%20Growth%20Indicators.pdf
- www.unescap.org/resources/green-growth-indicators-practical-approach-asia-and-pacific
- sustainabledevelopment.un.org/content/documents/916guidebook4.pdf
- openknowledge.worldbank.org/handle/10986/6058
- cdkn.org/wp-content/uploads/2011/07/CDKN-Guide-to-Green-Growth.pdf

# ៩. ការរៀបចំគម្រោងវិនិយោគអាទិភាពទីក្រុងបៃតង

គម្រោងវិនិយោគ ដែលឆ្លងកាត់ការជម្រុះតាមរយៈដំណើរការកំណត់អាទិភាព នឹងយកទៅធ្វើការវិភាគបន្ត អំពីស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដើម្បីឱ្យប្រាកដថា ការវិនិយោគដែលបានជ្រើសរើសជាអាទិភាព នឹងផ្តល់នូវលទ្ធផលជាទីគាប់ចិត្ត និងផលទទួលបានផ្នែកសេដ្ឋកិច្ចដ៏សមស្របមួយ។ ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង នឹងបន្តការវិភាគលើកត្តាទាំងនេះ ជាមួយនឹងសមត្ថភាពក្នុងការវាយតម្លៃផ្នែកសេដ្ឋកិច្ចរបស់ខ្លួនដែលមានស្រាប់ ឬដោយមានការជួយពីក្រុមទីប្រឹក្សាជំនាញ (អាចរកបានតាមរយៈ ក.ជ.អ.ច. ឬម្ចាស់ជំនួយ ដើម្បីផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស)។

## ៩.១ ការវិភាគពីស្ថានភាពហិរញ្ញវត្ថុ

គម្រោងវិនិយោគសម្រាប់ការអភិវឌ្ឍទាំងអស់ ជាធម្មតា គឺជាប្រធានបទដើម្បីធ្វើការវិភាគពីស្ថានភាពហិរញ្ញវត្ថុ។ ផ្នែកនេះពាក់ព័ន្ធទៅនឹងការប៉ាន់ប្រមាណ និងវាយតម្លៃពីការចំណាយផ្នែកហិរញ្ញវត្ថុ និងប្រាក់ចំណូលដែលទទួលបានពីគម្រោងវិនិយោគ សម្រាប់អ្នកវិនិយោគ។ ជាជំហានតំបូងនៃគម្រោង ការវិភាគពីស្ថានភាពហិរញ្ញវត្ថុ (ចំណូល និងចំណាយ) របស់គម្រោងវិនិយោគ មិនអាចបញ្ចូលនូវកត្តាបរិស្ថាន ឬសង្គមទៅក្នុងការពិចារណាទេ ក្រៅពីប្រភពនៃការចំណាយ ឬចំណូលសំខាន់ៗ (ឧ. ឧស្ម័នដែលបានកាត់បន្ថយពីការបញ្ចេញទៅក្នុងបរិយាកាស អាចត្រូវបានលក់តាមរយៈទីផ្សារកាបូន ដើម្បីបានជាប្រាក់ចំណូល)។ ដូច្នេះ វាមិនត្រូវបានគេប្រើដើម្បីបង្ហាញថា តើគម្រោងជាក់លាក់មួយ ដែលដាក់នូវតម្លៃខាតបង់បរិស្ថាន និងសង្គមខាងក្រៅ គឺជាការប្រើប្រាស់ធនធានដ៏ល្អមួយទេពីបទដ្ឋានសុខុមាលភាពទូទៅ។

យ៉ាងណាក៏ដោយ ការវិភាគពីស្ថានភាពហិរញ្ញវត្ថុដោយគិតគូរពីរយៈពេលនៃការប្រមូលទុនបានវិញ ឬទំហំទុនដែលបានរំពឹងទុកលើការវិនិយោគ គឺជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់គម្រោងវិនិយោគសាធារណៈ ដែលអាចនឹងក្លាយជាគម្រោងស្វ័យទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ ឬទាក់ទាញការចាប់អារម្មណ៍ពីអ្នកវិនិយោគវិស័យឯកជន (ហើយដូច្នេះ "គម្រោងអាចទទួលបានប្រាក់កម្ចីពីធនាគារ ")។

## ៩.២ ការវិភាគពីការចំណាយ និងចំណូល (Cost-Benefit Analysis - CBA )

CBA គឺជាមធ្យោបាយមួយក្នុងការឱ្យតម្លៃទៅលើលទ្ធផលរំពឹងទុករបស់គម្រោងវិនិយោគជាលក្ខណៈហិរញ្ញវត្ថុដើម្បីងាយស្រួលក្នុងការប្រៀបធៀប។ ជាគោលការណ៍ការវិភាគ CBA គឺគិតបញ្ចូលនូវរាល់លំហូរតម្លៃ (ការចំណាយ) បែបសេដ្ឋកិច្ចទាំងអស់ ដែលអាចកើតមាននៅក្នុងគម្រោងមួយ។ ជាពិសេស CBA គឺអាចឱ្យយើងគិតគូរ និងអាចបញ្ចូលនូវការធ្វើរូបិយវត្ថុនីយកម្មលើផលប៉ះពាល់បរិស្ថាន និងសង្គមទាំងអស់។ មានបច្ចេកទេសជាច្រើនក្នុងការវាយតម្លៃឬការធ្វើរូបិយវត្ថុនីយកម្មដែលបានបង្កើត ដែលត្រូវបានរចនាឡើងដើម្បីអនុវត្តរូបិយវត្ថុនីយកម្ម ដោយគិតទាំងការវាយតម្លៃជារូបិយវត្ថុទៅលើ ឆន្ទៈនៃការបង់កម្រៃសេវា គំរូក្នុងការផ្តល់តម្លៃដោយពេញចិត្ត និងផ្ទេរតម្លៃ។ គុណសម្បត្តិដ៏ធំរបស់ CBA គឺភាពប្រាកដប្រជារបស់វាអាចឱ្យធ្វើការប្រៀបធៀបនូវគម្រោងប្រភេទខុសៗគ្នាជាមួយនឹងផលប៉ះពាល់ និងលទ្ធផលផ្សេងៗក្នុងលក្ខខណ្ឌដែលអាចប្រៀបធៀបបាន (ជាធម្មតាតួលេខមួយ ដែលបានផ្តល់ឱ្យនូវតម្លៃបច្ចុប្បន្នសរុប [NPV] នៃគម្រោង និង/ឬអត្រានៃលទ្ធផលខាងក្នុង [IRR] របស់គម្រោងមួយ) ដែលងាយស្រួលឱ្យអ្នកបង្កើតគោលនយោបាយ។

ប៉ុន្តែនៅក្នុងការអនុវត្តផ្ទាល់ ពេលវេលា និងធនធានដែលត្រូវការសម្រាប់ការវិភាគ និងវាយតម្លៃនេះ គឺជាញឹកញាប់មិនមានគ្រប់គ្រាន់។ CBA ក៏មានទំនោរពឹងផ្អែកលើទិន្នន័យច្រើន ហើយការប្រើប្រាស់ទិន្នន័យតាម

រយៈវិធីសាស្ត្រនេះ គឺមិនសូវមានប្រសិទ្ធភាពនៅក្នុងស្ថានភាពខ្វះទិន្នន័យ។ ការវិភាគពី CBA ក៏នៅមានបញ្ហាមួយចំនួនទៀតពាក់ព័ន្ធទៅនឹងការរួមបញ្ចូលនៃផលប៉ះពាល់សង្គមទៅក្នុង CBA ផងដែរ ដែលហាក់ដូចជាមិនចាប់អារម្មណ៍ពីផលវិបាកផ្សេងៗដែលកើតចេញពីការអនុវត្តគម្រោង។ ចុងក្រោយ នៅក្នុងបរិបទនៃគម្រោងវិនិយោគអភិវឌ្ឍន៍បៃតង នៅខណៈការកំណត់តម្លៃកាបូនដែលត្រូវបានបង្កើតឡើង គឺអាចធ្វើការវាយតម្លៃពីផលប្រយោជន៍ ដែលបន្ថែមទៅលើគម្រោងថាមពល និងការបញ្ចេញឧស្ម័នដោយផ្តោតទៅលើភាពធន់ និងការជៀសវាងផលខូចខាតនាពេលអនាគតមានភាពលំបាកយ៉ាងខ្លាំងក្នុងការវិភាគពីចំណាយ។

## ៩.៣ ការវិភាគពីប្រសិទ្ធភាពចំណាយ (Cost-Effectiveness Analysis - CEA)

CEA ជាធម្មតាត្រូវបានគេប្រើប្រាស់ដើម្បី ធ្វើការវាយតម្លៃគម្រោងវិនិយោគ ដែលមានជម្រើសច្រើនដើម្បីសម្រេចនូវគោលបំណងជាក់លាក់មួយ ប៉ុន្តែគោលបំណងជាក់លាក់នោះ គឺមិនអាចបំលែងជាតម្លៃនោះទេ។ ជាឧទាហរណ៍ ច្បាប់ឬលក្ខខណ្ឌនៃការសាងសង់ស្ពាន គឺទាមទារឱ្យស្ពានអាចទប់ទល់នឹងទឹកជំនន់ដ៏ធំដែលអាចកើតមានរៀងរាល់ ១០០ ឆ្នាំ ម្តង។ ការកំណត់បែបនេះ មិនមែនជាជម្រើសផ្នែកសេដ្ឋកិច្ចដ៏ល្អមួយទេសម្រាប់គម្រោងវិនិយោគស្ពានដែលធន់នឹងគ្រោះធម្មជាតិ ប៉ុន្តែនេះជាអ្វីដែលតម្រូវដោយច្បាប់។ CEA អាចឱ្យធ្វើការប្រៀបធៀបវាងតម្លៃនៃដំណោះស្រាយបែបវិស្វកម្មសម្រាប់ជំនួស ឱ្យត្រូវនឹងលក្ខខណ្ឌទាមទារទាំងនេះ។ តម្លៃផ្សេងទៀត ដូចជា តម្លៃបរិស្ថាន អាចត្រូវបានគេគិតបញ្ចូលទៅក្នុងការវិភាគ។ ប៉ុន្តែ CEA គឺការប្រើប្រាស់នៅមានកម្រិត នៅពេលដែលចង់ធ្វើការប្រៀបធៀបគម្រោងជាមួយនឹងគោលបំណងខុសៗគ្នា ឬនៅក្នុងករណីគម្រោងដែលរួមចំណែកក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង គោលបំណងគឺមានលក្ខណៈធំ (ឧ.ការកាត់បន្ថយការបញ្ចេញឧស្ម័ន) ឬគោលបំណងមានច្រើន។

## ៩.៤ ខ្សែកោងតម្លៃ ដែលបង្ហាញពីការវិភាគជាតិការមូនតិច (MACCS)

MACCs បង្ហាញពីព័ត៌មានស្តីពីឱកាសខុសៗគ្នាសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ឬការបញ្ចេញឧស្ម័នដ៏ទៃទៀត) ក្នុងន័យទាក់ទងនឹងតម្លៃក្នុងមួយឯកតានៃការកាត់បន្ថយការបញ្ចេញឧស្ម័ន និងចំនួននៃការកាត់បន្ថយការបញ្ចេញឧស្ម័នបានជោគជ័យ។ ជាពិសេស វាគឺជាការប្រៀបធៀបដែលអាចមើលឃើញពីការខ្វះខាតរបស់ការវិភាគបែប CEA និងភាពដែលអាចពង្រីកនូវជម្រើសផ្សេងៗ។ ទាំងនេះជាធម្មតា ត្រូវបានកំណត់ដោយឱកាសតម្លៃដ៏តិចតួចបំផុតនៅខាងឆ្វេងដៃនៃបន្ទាត់ក្រឹត ទៅនឹងឱកាសតម្លៃខ្ពស់បំផុតនៅខាងស្តាំដៃនៃបន្ទាត់ក្រឹត។ **រូបភាព១៧** បង្ហាញពី MACC នៅទីក្រុងដាណាង (ប្រទេសវៀតណាម) ដែលអនុវត្តន៍នូវបច្ចេកវិទ្យាការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងកម្រិតសមស្រប។ MACCs អាចបញ្ចូលនូវការវាស់វែងជាច្រើនដោយរួមបញ្ចូលនូវបច្ចេកវិទ្យា និងបញ្ញត្តិ/គោលនយោបាយអនុវត្តការកាត់បន្ថយការបញ្ចេញឧស្ម័ន។

MACCs មានគុណវិបត្តិជាពិសេសទាក់ទងនឹងការសន្មត់ ដែលបង្កប់នូវការគណនានូវឯកតាតម្លៃក្នុងការកាត់បន្ថយ បានមកពីបច្ចេកវិទ្យាខុសៗគ្នា។ ការសន្មត់ទាក់ទងនឹងតម្លៃថាមពល អត្រាបញ្ចុះតម្លៃ និងទំហំនៃតម្លៃខាងក្រៅទាំងវិជ្ជមាន និងអវិជ្ជមានត្រូវបានគិតបញ្ចូលទៅក្នុងតម្លៃនៃជម្រើសជាក់លាក់ គឺត្រូវបានធ្វើឡើងឱ្យបានច្បាស់លាស់ព្រមទាំងអាចប្រែក្លាយនូវលទ្ធផលនៃការវិភាគជាច្រើនទៀត។ ជាក់ស្តែង វាអាចពាក់ព័ន្ធគ្នា នៅពេលធ្វើការពិចារណាពីតម្លៃវិជ្ជមានខាងក្រៅទៅលើការរីកសាយភាយនៃបច្ចេកវិទ្យាថ្មីៗ នៅបរិបទដើម្បីធ្វើការកាត់បន្ថយការចំណាយនៅពេលវេលាដែលសល់។ យ៉ាងណាក៏ដោយ ប្រសិនបើក្នុងការប្រើប្រាស់ និងការថែទាំពួកវាគឺជាឧបករណ៍ដ៏មានប្រយោជន៍សម្រាប់ការបង្ហាញពីជម្រើសក្នុងកម្រិតមួយ និងងាយស្រួលយល់ពីអ្នកធ្វើសេចក្តីសម្រេចចិត្ត។

រូបភាព ១៦. MACC នៃបច្ចេកវិទ្យាថាមពល និងការបញ្ចេញឧស្ម័ននៅទីក្រុងដាណាង ២០១៤




ប្រភព: ICEM 2014

## ៩.៥ ខ្សែកោងតម្លៃនៃការបន្សាំ

វិធីសាស្ត្រស្រដៀងទៅនឹង MACCs ត្រូវបានបង្កើតឡើងដើម្បីគិតគូរដល់ជម្រើសក្នុងការបន្សាំ។ ប៉ុន្តែដោយហេតុតែ CEA សម្រាប់ជម្រើសក្នុងការកាត់បន្ថយ អាចឱ្យជម្រើសទាំងអស់ត្រូវបានបង្ហាញនៅក្នុងឯកតារួម (ការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងតម្លៃឯកតា និងសក្តានុពលក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន) មិនដូចជាករណីបន្សាំ។ គោលបំណងនៃការបន្សាំខុសគ្នាពីវិស័យមួយទៅវិស័យមួយ ហើយដូច្នេះការប្រៀបធៀបមួយមិនអាចធ្វើបានលើគម្រោងផ្សេងៗនៅក្នុងវិស័យខុសគ្នានោះទេ។ ស្រដៀងគ្នានេះដែរ ជម្រើសក្នុងការវិនិយោគមិនអាចត្រូវបានកំណត់ដោយប្រភេទបច្ចេកវិទ្យា ឬគោលនយោបាយទូទៅដូចនឹងការកាត់បន្ថយការបញ្ចេញឧស្ម័ននោះទេ ប៉ុន្តែគឺជាញឹកញាប់ផ្តោតជាពិសេសទៅលើទីតាំង (ឧ. ការវាស់វែងការកាត់បន្ថយទឹកជំនន់) ព្រមទាំងមាននូវលក្ខណៈនៃប្រសិទ្ធភាពតម្លៃជាក់លាក់ ដែលយោងលើលក្ខណៈភូមិសាស្ត្រនៃតំបន់ជាក់លាក់។

វិធីសាស្ត្រមួយដើម្បីជៀសវាងពីផលលំបាកនេះ គឺបង្ហាញពីជម្រើសក្នុងវិនិយោគក្នុងក្របខ័ណ្ឌលទ្ធផលរបស់ CBA ជាមួយនឹងផលធៀបចំណេញខាតគិតជាប្រាក់ពេញលេញមួយ (ឬ IRR) ដែលបង្ហាញនៅលើបន្ទាត់ y និងផលចំណេញទូទៅសំខាន់ៗ (ឬ NPV) បង្ហាញនៅលើបន្ទាត់ x។ ប៉ុន្តែវិធីសាស្ត្រប្រភេទនេះ នឹងអាចទាមទារនូវ CBA ដ៏ជឿនលឿនសមស្រប ដើម្បីគិតគូរពីការចំណាយដែលត្រូវជៀសវាងនៅពេលអនាគតមិនច្បាស់លាស់។ យ៉ាងណាក៏ដោយ សម្រាប់កិច្ចអន្តរាគមន៍នៅក្នុងវិស័យមួយ ម៉ាទ្រីក CEA សាកសម ដែលនឹងអាចឱ្យធ្វើការប្រៀបធៀបមួយរវាងគម្រោង គឺអាចធ្វើទៅបាន។

## ៩.៦ និយមន័យលទ្ធភាពអាចអនុវត្តបាននៃគម្រោងអាទិភាព

គម្រោងដែលត្រូវបានជ្រើសរើសចេញពីការជម្រុះ ត្រូវបានផ្តល់សុពលភាពដោយការវិភាគលើស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដែលបានពិពណ៌នាខាងលើ ហើយនឹងក្លាយជាប្រធានបទបន្ត ដើម្បី**លម្អិតបន្ថែមពីកម្រិតនៃការរៀបចំដែលអាចកំណត់ជាលទ្ធផលក្នុងការអនុវត្តគម្រោង។** ចាប់ពីទំព័រទី១នៃឯកសារគម្រោង ការពិពណ៌នាពីគម្រោងនឹងក្លាយទៅជាឯកសារទូលំទូលាយ ដោយបញ្ចូលនូវលទ្ធផលនៃការវាយតម្លៃពីស្ថានភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ហើយថែមទាំងការវាយតម្លៃ និងឯកសារយោងបែបបច្ចេកទេស ព្រមទាំងព័ត៌មានបន្ថែមស្តីពីចំហាកក្នុងការអនុវត្តដែលបានស្នើឡើង។

នេះក៏នឹងទាមទារដែរថា **ការពិគ្រោះយោបល់ស៊ីជម្រៅបន្ថែមទៀត ត្រូវធ្វើឡើងជាមួយនឹងភាគីជាច្រើនដែលនឹងពាក់ព័ន្ធនឹងគម្រោងជាក់លាក់។** ភាគីទាំងនេះ រួមមានអ្នកពាក់ព័ន្ធ ដែលកំពុងបង្ហាញពីតម្រូវការគម្រោង តំណាងនៃការគាំទ្រផ្នែកហិរញ្ញវត្ថុ អង្គភាពនៃវិស័យសាធារណៈ ដែលនឹងទទួលខុសត្រូវលើការអនុវត្ត ការថែទាំ និងការដំណើរការគម្រោង ព្រមទាំងអ្នកផ្តល់នូវបច្ចេកវិទ្យា និងសេវាកម្មប្រឹក្សាដែលត្រូវការ។ **តារាងទី ៨** បង្ហាញអំពីគំរូតារាងទូទៅមួយដែលអាចយកមកបរិយាយលំអិតអំពីគម្រោងវិនិយោគមួយ។

តាមរយៈដំណើរការនៃការកំណត់សមិទ្ធិលទ្ធភាព វាក៏នឹងអាច**កំណត់នូវភាគី ដែលនឹងដើរតួជាអ្នកតាមដានគម្រោង** និងបានត្រៀមខ្លួនរួចរាល់ព្រមទាំងមានឆន្ទៈដើម្បីជំរុញគម្រោងឆ្លងកាត់ដំណាក់កាលលំបាកដែលជៀសវាងមិនរួច និងភាពស្មុគស្មាញក្នុងការអនុវត្ត។ ក្នុងការបង្កើតនូវការគាំទ្រលើគម្រោង វាគឺសំខាន់ដើម្បីឱ្យប្រាកដថាកត្តាយេនឌ័ និងយុវជន ត្រូវបានយកមកគិតគូរ។ ការផ្តល់សុពលភាពដោយក្រុមអ្នកធ្វើផែនការទីក្រុងបៃតងលើគម្រោងទាំងអស់នៅក្នុងដំណាក់កាលដំបូងរបស់ពួកគេ នឹងក្លាយជាជំហានចុងក្រោយក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង។

*តារាងទី ៨៖ ទម្រង់តារាងរៀបរាប់ពីគម្រោងវិនិយោគទីក្រុងបៃតងអាទិភាព*

| **ទម្រង់សម្រាប់ពិពណ៌នាពីគម្រោង** | |
|---|---|
| **ផ្នែក កៈ សេចក្តីសង្ខេបពីគម្រោង** | |
| **ឈ្មោះគម្រោង៖** | [សម្រាប់បង្ហាញពីឈ្មោះនៃគម្រោង] |
| **លេខរៀងគម្រោង៖** | [លេខសំគាល់គម្រោង] |
| **បរិយាយពីគម្រោង៖** | បង្ហាញដោយសង្ខេបពីព័ត៌មានជាមូលដ្ឋានគម្រោង |
| **ប្រវត្តិនៃការបង្កើតគម្រោង៖** | ប្រវត្តិនៃការបង្កើតគម្រោង រួមមាន បុគ្គល ឬស្ថាប័នដែលស្នើឱ្យមានគម្រោង ស្នើឡើងនៅពេលណា តើវាកើតឡើងដោយរបៀបណា **ប្រសិនជាមានព័ត៌មានទាំងនេះ។** អ្វីដែលសំខាន់នោះ គឺផ្នែកនេះក៏នឹងសង្ខេបពីឧបសគ្គដែលបានរកឃើញនៅពេលបង្កើតគម្រោងនៅក្នុងតំណាក់កាលតំបូងនៃការធ្វើផែនការវិនិយោគ។ |
| **ទំនិញ ឬសេវាកម្ម ដែលនឹងត្រូវធ្វើ៖** | ផ្នែកនេះគឺរៀបរាប់អំពីទំនិញ ឬសេវាកម្មដែលនឹងត្រូវធ្វើ និងទីផ្សារគោលដៅ |
| **បុព្វហេតុនៃការអភិវឌ្ឍបៃតង៖** | ផ្នែកនេះគឺរៀបរាប់អំពីផលប្រយោជន៍ដែលទទួលបានសម្រាប់ការអភិវឌ្ឍបៃតងនៃគម្រោង |
| **វិស័យ៖** | ផ្នែកនេះបង្ហាញពីការផ្សារភ្ជាប់គ្នានៃគម្រោង ទៅនឹងវិស័យអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង |

| | |
|---|---|
| **អ្នកចូលរួមនៅក្នុងគម្រោង និងតួនាទី៖** | ផ្នែកនេះបរិយាយអំពីស្ថាប័នដែលពាក់ព័ន្ធដោយផ្ទាល់ទៅនិងការអនុវត្តគម្រោង ក្នុងនាមជាដៃគូអភិវឌ្ឍន៍។ ផ្នែកនេះក៏បង្ហាញពីស្ថាប័នដ៏ទៃទៀតដែលអាចជាអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងដំណើរការអនុវត្តគម្រោងផងដែរ ដូចជាអ្នកដែលមិនយល់ស្របនឹងគម្រោង នៅក្នុងស្ថាប័នរដ្ឋ ឬឯកជន។ |
| **ប្រភេទគម្រោង៖** | ផ្នែកនេះបរិយាយអំពីប្រភេទហិរញ្ញប្បទានដែលអាចយកអនុវត្តគម្រោង អាចជាហិរញ្ញប្បទានសាធារណៈ ហិរញ្ញប្បទានដែលជាម្ចាស់ជំនួយ ហិរញ្ញប្បទានរួមគ្នា ហិរញ្ញប្បទានតាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន ឬហិរញ្ញប្បទានចេញពីវិស័យឯកជន។ ប្រសិនជាអាច ផ្នែកនេះក៏នឹងរៀបរាប់លម្អិតអំពីរចនាសម្ព័ន្ធនៃការធ្វើហិរញ្ញប្បទាន (ឧ. BOO, BOT, កុងត្រាជួល, កុងត្រាគ្រប់គ្រង, ។ល។ |
| **ទំហំនៃគម្រោង៖** | ផ្នែកនេះបរិយាយអំពីទំហំនៃទុនវិនិយោគដែលប៉ាន់ប្រមាណសម្រាប់ការអនុវត្តគម្រោង។ គួរកត់សំគាល់ថា ភាពខុសគ្នានៃទំហំគម្រោង ក៏នាំឱ្យមានដំណើរការខុសគ្នាដែរក្នុងការស្នើរសុំការអនុម័ត ទៅតាមកម្រិតនៃឋានានុក្រមស្ថាប័នរដ្ឋ។ |
| **រយៈពេលនៃការអនុវត្តគម្រោង៖** | ផ្នែកនេះបរិយាយអំពីពេលវេលាដែលសមស្របអាចអនុវត្តន៍គម្រោងបាន និងរយៈពេលនៃការអនុវត្ត |
| **ទីតាំងគម្រោង និងការគិតពិចារណាពីទីតាំងដី និងការផ្លាស់ប្តូរទីតាំងរបស់ប្រជាជន៖** | ផ្នែកនេះបរិយាយអំពីទីតាំងជាក់ស្តែងរបស់គម្រោង (បើអាចដឹង)។ វាក៏បង្ហាញពីតម្រូវការទំហំដីដែលត្រូវការ និងទីតាំងដែលអាចរកបាន។ បើការកំណត់ទីតាំងដីដែលត្រូវការហើយ ផ្នែកនេះ ក៏នឹងបង្ហាញពីតម្រូវការនៃការផ្លាស់ប្តូរទីតាំងរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅលើទីតាំងដីនោះ។ |
| **ច្បាប់ និង គោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ ដែលពាក់ព័ន្ធ និងគាំទ្រដល់គម្រោង៖** | ផ្នែកនេះបរិយាយអំពី ច្បាប់ គោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នានារបស់រដ្ឋ ពាក់ព័ន្ធទៅនឹងគម្រោង ដែលជាគុទាំងនេះអាចជួយគាំទ្រដល់ការអនុវត្តគម្រោងទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបង្កើតទីផ្សារសមស្របសម្រាប់គម្រោង។ ផ្នែកនេះ រាប់បញ្ចូលទាំងច្បាប់ គោលនយោបាយ និងកម្មវិធីនានាដែលកំពុងស្ថិតនៅក្នុងពង្រៀង ប៉ុន្តែនឹងត្រូវអនុម័ត។ |
| **ដំណើរការនៃការអនុម័ត និងផ្តល់អជ្ញាប័ណ្ណ៖** | ផ្នែកនេះបរិយាយអំពីអជ្ញាប័ណ្ណ ឬការអនុម័តដែលត្រូវការសម្រាប់អនុវត្តន៍គម្រោង ហើយតើត្រូវទទួលបាលពីស្ថាប័នណាខ្លះ។ ផ្នែកនេះក៏នឹងបញ្ជាក់ផងដែរថាតើ គម្រោងបានទទួលនូវអជ្ញាប័ណ្ណ ឬការអនុម័តយល់ព្រមហើយឬនៅ។ |
| **ហានិភ័យដែលអាច កើតមាន៖** | ផ្នែកនេះបរិយាយអំពីហានិភ័យនៃគម្រោងដែលអាចកើតមានដល់ភាគីពាក់ព័ន្ធ ក៏ដូចជាដល់ការវិនិយោគ។ |
| **ជំហានបន្ទាប់៖** | ផ្នែកនេះបរិយាយអំពីជំហានបន្ទាប់ដែលត្រូវការចាំបាច់សម្រាប់គម្រោងរួមទាំងទិន្នន័យដែលត្រូវការអ្នកពាក់ព័ន្ធដែលត្រូវជួបពិភាក្សាយោបល់ ។ ប្រសិនបើគម្រោងមានភាពលម្អិត ផ្នែកនេះក៏នឹងបរិយាយផងដែរអំពីជំហានបន្ទាប់ដែលត្រូវការសម្រាប់វដ្តនៃការគ្រប់គ្រងគម្រោង។ |
| **ជនបង្គោល សម្រាប់ទំនាក់ទំនង៖** | ផ្នែកនេះបង្ហាញពី ជនបង្គោលសម្រាប់ធ្វើការទំនាក់ទំនងពាក់ព័ន្ធទៅនឹងគម្រោង និងអាស័យដ្ឋានសម្រាប់ទំនាក់ទំនងផងដែរ។ |
| **ផ្នែក ខ៖ ផលប្រយោជន៍នៃការអភិវឌ្ឍបៃតង** | |
| **ការប្រើប្រាស់ធនធាន៖** | ផ្នែកនេះបង្ហាញពី ការសន្សំសំចៃនៃការប្រើប្រាស់ធនធានតាមរយៈការវិភាគ BAU (ឧ. ការប្រើប្រាស់ទឹក ថាមពល ។ល។) បើសិនជាមាន ផ្នែកនេះបង្ហាញពីទំហំប៉ាន់ប្រមាណនៃការសន្សំពីការប្រើប្រាស់ធនធាន។ |
| **ការកាត់បន្ថយការបំពុល៖** | ផ្នែកនេះបង្ហាញពីទំហំនៃការកាត់បន្ថយការបំពុលដែលផលប្រយោជន៍កើតចេញពីការអនុវត្តគម្រោង។ បើសិនជាមាន ផ្នែកនេះបង្ហាញពីទំហំប៉ាន់ប្រមាណនៃការកាត់បន្ថយផងដែរ។ |

| | |
|---|---|
| **បង្កើតការងារបៃតង៖** | ផ្នែកនេះបង្ហាញពី ទំហំការងារបៃតងដែលអាចកើតមានពីការអនុវត្តគម្រោង។ |
| **ការគិតពីសង្គមគ្រប់ជ្រុងជ្រោយ និងការកាត់បន្ថយភាពក្រីក្រ៖** | ផ្នែកនេះបង្ហាញពី ផលប្រយោជន៍ដល់សង្គមបានគ្រប់ជ្រុងជ្រោយ និងការកាត់បន្ថយភាពក្រីក្រដែលទទួលបានពីការអនុវត្តគម្រោង។ |
| **ផ្នែក គ៖ កត្តា (ប៉ារ៉ាម៉ែត្រ) ហិរញ្ញវត្ថុ និងការវិនិយោគ**<br>ផ្នែកនេះបរិយាយអំពីកត្តា (ប៉ារ៉ាម៉ែត្រ) ហិរញ្ញវត្ថុសំខាន់ៗរបស់គម្រោង។ មុននឹងធ្វើការសិក្សាអំពីលទ្ធភាពអនុវត្តគម្រោងបឋម ឬការសិក្សាពីលទ្ធភាពគម្រោង តួលេខក្នុងការគណនាប៉ារ៉ាម៉ែត្រនៅក្នុងផ្នែកនេះ គឺមិនមានជាក់លាក់ទេ បើទោះជាមានការប៉ាន់ប្រមាណពីទំហំណាមួយដែលផ្អែកលើគម្រោងប្រហាក់ប្រហែលគ្នានៅកម្ពុជា ឬពីប្រទេសដ៏ទៃទៀតក៏ដោយ។ ទាំងនេះគឺវាពាក់ព័ន្ធខ្លាំងទៅនឹងគម្រោងវិនិយោគ ដែលស្វះស្វែងរកប្រភពហិរញ្ញវត្ថុពីវិស័យឯកជន។ | |
| **ដើមទុនចំណាយ៖** | ផ្នែកនេះបង្ហាញពី ដើមទុនប៉ាន់ប្រមាណក្នុងការចំណាយ ជាដុល្លារអាមេរិក និងជាប្រាក់រៀល ដោយបង្ហាញពីការបែងចែកតាមប្រភេទនៃចំណាយ បើសិនជាអាច។ ផ្នែកនេះក៏បង្ហាញពីមតិយោបល់ពាក់ព័ន្ធនិងចំណាយដែលមិនទាន់ច្បាស់លាស់ ផងដែរ។ |
| **ការចំណាយក្នុងការអនុវត្ត៖** | ផ្នែកនេះបង្ហាញពី ការចំណាយប៉ាន់ប្រមាណពីការអនុវត្តគម្រោង រួមបញ្ចូលទាំងចំណាយប្រចាំឆ្នាំ និងចំណាយជាទៀងទាត់ដែលនឹងកើតមាន។ (ឧ. ចំណាយលើការជួសជុលកែលម្អ ។ល។) ផ្នែកនេះក៏បង្ហាញពី មតិយោបល់ពាក់ព័ន្ធនឹងចំណាយដែលមិនទាន់ច្បាស់លាស់ផងដែរ។ |
| **ចំណូល៖** | ផ្នែកនេះបង្ហាញពី ទំហំប៉ាន់ប្រមាណនៃចំណូលពីការអនុវត្តគម្រោងមួយនៅពេលបញ្ចប់។ វាក៏បង្ហាញពីការគណនាចំណូលលម្អិតផងដែរ និងចំណូលដែលមិនទាន់ច្បាស់លាស់។ |
| **រយៈពេល ទទួលផលមកវិញ៖** | ផ្នែកនេះបង្ហាញពី ការប៉ាន់ប្រមាណពេលវេលាដែលនឹងផ្តល់ត្រឡប់មកវិញផ្អែកលើប៉ារ៉ាម៉ែត្រនៅក្នុង**ផ្នែក** គ។ |
| **ប្រភពនៃហិរញ្ញប្បទានពីវិស័យឯកជនដែលមានសក្តានុពល និងរចនាសម្ព័ន្ធហិរញ្ញប្បទាន៖** | ផ្នែកនេះបង្ហាញពី ប្រភពនៃហិរញ្ញប្បទានពីវិស័យឯកជនដែលមានសក្តានុពល ការចំណាយ និងរចនាសម្ព័ន្ធហិរញ្ញប្បទាន។ |
| **ប្រភពនៃហិរញ្ញប្បទានពីម្ចាស់ជំនួយដែលមានសក្តានុពល និងរចនាសម្ព័ន្ធហិរញ្ញប្បទាន៖** | ផ្នែកនេះបង្ហាញពី ប្រភពនៃហិរញ្ញប្បទានពីម្ចាស់ជំនួយដែលមានសក្តានុពល ការចំណាយ និងរចនាសម្ព័ន្ធហិរញ្ញប្បទាន។ |
| **ការប៉ាន់ប្រមាណពីផលទទួលបានចេញពីការវិនិយោគ៖** | ផ្នែកនេះបង្ហាញពី ទំហំប៉ាន់ប្រមាណនៃផលត្រឡប់មកវិញពីការវិនិយោគ ផ្អែកលើប៉ារ៉ាម៉ែត្រនៅក្នុងផ្នែក គ។ |

# ១០. ការអនុវត្តការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង

ការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតង គឺជាដំណើរការមួយដែលអាចប្រើរយៈពេល ៩ ទៅ១២ខែ។ នៅពេលបញ្ចប់ និងនៅពេលផែនការត្រូវបានអនុម័ត និងផ្ទៀងផ្ទាត់ លទ្ធផលដំបូងគឺ**ការបង្កើតភាពជឿជាក់ ព្រមទាំងការយល់ដឹងកាន់តែប្រសើរក្នុងចំណោមអ្នកពាក់ព័ន្ធ អាជ្ញាធរសាធារណៈ និងសហគមន៍**។ លទ្ធផលសំខាន់ផ្សេងមួយទៀត គឺជាសេចក្តីរំពឹងទុករបស់សាធារណៈជន ដើម្បីឃើញពីភាពជាក់ស្តែងក្នុងការផ្លាស់ប្តូរតំបន់កណ្តាលនៃទីប្រជុំជន ឱ្យកាន់តែមាននិរន្តរភាពជាងមុន។

ដើម្បីស្របទៅនឹងការរំពឹងទុកបែបនេះ ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង នឹងត្រូវឈានដល់ដំណាក់កាលអនុវត្ត។ នេះនឹងទាមទារនូវ**ការធ្វើស្ថាប័ននីយកម្ម និងធ្វើឱ្យមាននិរន្តរភាពនៃដំណើរការរៀបចំ ដែលត្រូវនឹងត្រូវកំណត់ឱ្យបានសម្រាប់ការអនុវត្តក្នុងការរៀបចំផែនការ**។ គណៈកម្មការប្រឹក្សាយោបល់ និងក្រុមការងារបច្ចេកទេស គួរតែត្រូវបានបង្កើតឡើងដើម្បីជួយគាំទ្រដល់ស្ថាប័នដែលដឹកនាំការងារនេះ (ពោលគឺ រាជធានី ក្រុង/ខេត្ត ស្រុក) ដើម្បីដឹកនាំ និងសម្របសម្រួលការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង។

តួនាទីចម្បងនៃគណៈកម្មការប្រឹក្សាយោបល់ គឺដើម្បីផ្តល់នូវគំនិតយោបល់ជាយុទ្ធសាស្ត្រ និងធ្វើការត្រួតពិនិត្យទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រ។ គោលបំណងនៃការរៀបចំរចនាសម្ព័ន្ធ គឺដើម្បីធានាថា ទស្សនៈវិស័យ និងបេសកម្មរបស់ក្រុមការងារ នឹងសម្រេចបាន ហើយគោលដៅរំពឹងទុកនឹងទទួលបានជោគជ័យ ហើយផែនការយុទ្ធសាស្ត្រ នឹងមានការអនុវត្តប្រកបដោយជោគជ័យទៅតាមពេលវេលាដែលបានកំណត់។

តួនាទីរបស់គណៈកម្មការប្រឹក្សាយោបល់មានដូចខាងក្រោម៖

១. ផ្តល់ការត្រួតពិនិត្យ និងបង្ហាញពីទិសដៅជាយុទ្ធសាស្ត្រ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងត្រូវធ្វើឱ្យប្រាកដថា ទស្សនៈវិស័យ និងបេសកម្មដែលចែងនៅក្នុងផែនការនេះ នឹងអាចសម្រេចបាន ហើយគោលដៅរំពឹងទុកនឹងទទួលបានជោគជ័យ ហើយផែនការយុទ្ធសាស្ត្រនឹងមានការអនុវត្តប្រកបដោយជោគជ័យទៅតាមពេលវេលាដែលបានកំណត់។

២. ធ្វើការចាត់តាំងមន្ត្រីពីក្រសួងរបស់ខ្លួនឱ្យធ្វើជាសមាជិកនៃក្រុមការងារបច្ចេកទេសតាមវិស័យមួយ ឬច្រើនទៅតាមជំនាញ។

៣. ធ្វើការអនុម័ត និងផ្តល់ការគាំទ្រទៅដល់ការអនុវត្តសកម្មភាពផែនការយុទ្ធសាស្ត្ររបស់ស្ថាប័នដែលដឹកនាំការអនុវត្តផែនការ (ពោលគឺសាលារាជធានីក្រុង/ខេត្ត ខណ្ឌ/ស្រុក)។

៤. មានកិច្ចប្រជុំសមាជិកជាទៀងទាត់ ដើម្បីត្រួតពិនិត្យ និងតាមដានបច្ចុប្បន្នភាពនៃការអនុវត្ត និងលទ្ធផលដែលសម្រេចបាន។

គោលបំណងជំរួមរបស់ក្រុមការងារបច្ចេកទេសតាមវិស័យ គឺដើម្បីគាំទ្រស្ថាប័នដែលដឹកនាំការអនុវត្តផែនការយុទ្ធសាស្ត្រនេះ តាមរយៈការផ្តល់នូវមតិយោបល់ និងគាំទ្រផ្នែកបច្ចេកទេស ដើម្បីសម្រេចបាននូវគោលដៅ គោលបំណង និងសកម្មភាពអាទិភាពដែលបានគ្រោងទុក។ តួនាទី និងទំនួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសតាមវិស័យរួមមាន៖

- ផ្តល់នូវធាតុចូលផ្នែកបច្ចេកទេសសម្រាប់ការអនុវត្តផែនការ
- បង្កើតនូវផែនការសកម្មភាពរយៈពេលខ្លី និងរយៈពេលវែង ទៅតាមវិស័យអាទិភាពនីមួយៗ
- ធ្វើការកៀរគរធនធាន សម្រាប់ការអនុវត្តគម្រោងវិនិយោគជាអាទិភាពសម្រាប់ទីក្រុងបៃតង
- ធ្វើការតាមដានការវិវត្តរបស់ផែនការយុទ្ធសាស្ត្រ ដោយផ្ទៀងផ្ទាត់ទៅនឹងគោលដៅទីប្រជុំជនបៃតងទៅតាមវិស័យនីមួយៗ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ
- ធ្វើសេចក្តីរាយការណ៍ទៅកាន់គណៈកម្មការប្រឹក្សាយោបល់ និងស្ថាប័នដឹកនាំការអនុវត្តជាប្រចាំ

**រូបភាពទី ១៧៖ រចនាសម្ព័ន្ធដែលត្រូវបានស្នើរឡើង សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងសម្រាប់រាជធានីភ្នំពេញ**




ការអនុវត្តគម្រោងដែលមានក្នុងបញ្ជីជ្រើសរើសដំបូង នឹងអាស្រ័យទៅលើ**ការកំណត់ និងការធានានូវធនធានផ្នែកហិរញ្ញវត្ថុដែលចាំបាច់ត្រូវយកទៅអនុវត្តន៍។** ប្រភពហិរញ្ញវត្ថុដែលមានសក្តានុពលសម្រាប់សកម្មភាពគម្រោងវិនិយោគការអភិវឌ្ឍបៃតង រួមមានដូចខាងក្រោម:

- <u>ហិរញ្ញវត្ថុសាធារណៈជាតិ៖</u> មូលនិធិជាតិសាធារណៈ រួមទាំងការគាំទ្រថវិកាដោយផ្ទាល់ និងផ្តល់ហិរញ្ញវត្ថុដែលបែងចែកសម្រាប់គម្រោង និងកម្មវិធីជាក់លាក់
- <u>មូលនិធិវិនិយោគដែលគ្រប់គ្រងថ្នាក់ជាតិ៖</u> ពល់មូលនិធិវិនិយោគសាធារណៈ ដែលអាចបង្កើតជាមូលនិធិឥតសំណង ឬប្រាក់កម្ចីសម្រាប់សកម្មភាពបៃតង
- <u>ការផ្តល់មូលនិធិកម្មវិធីជំនួយ៖</u> ការផ្តល់ជំនួយលើកិច្ចសហប្រតិបត្តិការពហុភាគី សម្រាប់កម្មវិធីអភិវឌ្ឍន៍

ទីក្រុងបៃតងនៅទីប្រជុំជនថ្នាក់ជាតិ និងនៅថ្នាក់រាជធានី

- ធនាគារពាណិជ្ជក្នុងស្រុក៖ ការផ្តល់ប្រាក់កម្ចីពីធនាគារពាណិជ្ជលើគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទីប្រជុំជននៅក្នុងប្រទេស
- វិស័យឯកជនក្នុងស្រុកផ្សេងទៀត៖ គម្រោង និងតារាងតុល្យការក្នុងការវិនិយោគពីសាជីវកម្មឯកជន
- ហិរញ្ញប្បទានកាបូន៖ ដូចជាយន្តការអភិវឌ្ឍន៍ស្អាត ការអនុវត្តរួមគ្នា យន្តការធ្វើជំនួញអន្តរជាតិសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័ន
- ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ៖ ការផ្គត់ផ្គង់ប្រាក់កម្ចី មូលនិធិឥតសំណង សម្រាប់ការវិនិយោគនៅរាជធានី ការគាំទ្រផ្នែកបច្ចេកទេស និងប្រភេទនៃការធានារ៉ាប់រង និងឧបករណ៍ក្នុងការកាត់បន្ថយហានិភ័យ សម្រាប់អ្នកវិនិយោគដែលមានសក្តានុពល
- អ្នកអភិវឌ្ឍន៍គម្រោងឯកជនអន្តរជាតិ៖ ជាធម្មតាបទបញ្ញត្តិរបស់ក្រុមហ៊ុនហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម ព្រមទាំងក្រុមហ៊ុនធម្មតា និង
- ធនាគារពាណិជ្ជបរទេស៖ ទាំងនេះជាធម្មតា ផ្តល់ប្រាក់កម្ចីទៅឱ្យអ្នកអភិវឌ្ឍន៍គម្រោងសម្រាប់ភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

ប្រភពនៃការផ្តល់ហិរញ្ញប្បទានទាំងនេះ នឹងខុសៗគ្នាទៅតាមប្រភេទ និងទំហំនៃការផ្តល់ហិរញ្ញប្បទានដែលពួកគេអាចផ្តល់ឱ្យ ព្រមទាំងលក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទាននីមួយៗ។ ទំហំនៃប្រភពទាំងនេះដែលអាចប្រមូលបាន អាស្រ័យទៅតាមកត្តាជាច្រើន ទាក់ទងទៅនឹងហានិភ័យដែលទទួលបាន លទ្ធផលត្រឡប់ដែលរំពឹងទុក និងបញ្ហាស្ថាប័នពាក់ព័ន្ធនឹងការលុបចោលការវិនិយោគ។

**ការទទួលខុសត្រូវលើការអនុវត្តគម្រោងជាក់លាក់ណាមួយ** គឺវានឹងអាស្រ័យលើវិស័យដែលពាក់ព័ន្ធ។ នាយកដ្ឋានរបស់រដ្ឋាភិបាលដែលទទួលបន្ទុកលើវិស័យជំនាញ នឹងត្រូវបានកោះហៅឱ្យមានការចូលរួម ព្រមទាំងបំពាក់បំប៉នសមត្ថភាពបន្ថែមប្រសិនបើត្រូវការ ដើម្បីឱ្យប្រាកដថាការអនុវត្តគម្រោងមានភាពពេញលេញ និងស្ថិតស្ថេរ ព្រមទាំងការដំណើរការបន្ទាប់អាចធ្វើទៅបាន។ លំហូរហិរញ្ញវត្ថុនៃប្រភពគម្រោងដែលពាក់ព័ន្ធ នឹងត្រូវបានរៀបចំឡើងបន្ទាប់ពីនោះ។

សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងបៃតង និងការអនុវត្តគម្រោងវិនិយោគអាទិភាពសម្រាប់ទីក្រុងបៃតង គឺត្រូវផ្សារភ្ជាប់ជាមួយនឹង**ដំណើរការត្រួតពិនិត្យ និងវាយតម្លៃ**។ បន្ថែមទៅលើការតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រ និងគម្រោងវិនិយោគប្រចាំឆ្នាំ គឺការត្រួតពិនិត្យ និងវាយតម្លៃពាក់កណ្តាលអាណត្តិ ដែលនឹងត្រូវធ្វើនៅក្នុងឆ្នាំ២០២០ និងការវាយតម្លៃបញ្ចប់នឹងត្រូវធ្វើនៅក្នុងឆ្នាំ ២០២៥។ ជាផ្នែកមួយនៃការត្រួតពិនិត្យប្រចាំឆ្នាំ ក្រុមការងារបច្ចេកទេសតាមវិស័យនីមួយៗ នឹងតម្រូវឱ្យធ្វើរបាយការណ៍ទៅស្ថាប័នដឹកនាំការអនុវត្ត ដែលនឹងត្រូវរៀបរាប់អំពីវឌ្ឍនភាពនៃការអនុវត្ត និងបញ្ហាប្រឈមនានាដែលអាចជួបប្រទះពេលកំពុងអនុវត្តផែនការសកម្មភាពជាអាទិភាព គម្រោងវិនិយោគបៃតង និងការកៀរគរប្រភពធនធាន។ ស្ថាប័នដែលដឹកនាំការអនុវត្តផែនការយុទ្ធសាស្ត្រ នឹងប្រមូលបញ្ចូលគ្នានូវរបាយការណ៍ទាំងនោះតាមវិស័យនីមួយៗដើម្បីធ្វើជារបាយការណ៍រួមដាក់ជូនទៅគណៈកម្មការប្រឹក្សាយោបល់។ ការត្រួតពិនិត្យ និងវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងក្រោយ គួរតែត្រូវធ្វើឡើងដោយអ្នកជំនាញការពីខាងក្រៅក្រោមការដឹកនាំដោយស្ថាប័នដែលអនុវត្តផែនការយុទ្ធសាស្ត្រ ។ លទ្ធផលដែលចេញពីការត្រួតពិនិត្យ និងវាយតម្លៃនឹងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ជាចុងក្រោយ កត្តាដែលសំខាន់មួយទៀត គឺ**កម្មវិធីផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយពីកម្មវិធីអភិវឌ្ឍន៍ទាំងមូល និងរក្សានូវការធ្វើទំនាក់ទំនងជាមួយសាធារណៈជន នៅក្នុងដំណាក់កាលនៃការអនុវត្ត** ដើម្បីឱ្យប្រាកដថា លទ្ធផលនៃគម្រោងទីក្រុងបៃតង ត្រូវបានគេស្គាល់ និងដើម្បីបញ្ជាក់ពីថាអ្វីដែលបានរំពឹងទុកពីការធ្វើផែនការយុទ្ធសាស្ត្រ នៅក្នុងដំណាក់កាលនៃការរៀបចំផែនការ គឺទទួលបានផ្លែផ្កា។ កម្មវិធីទំនាក់ទំនង និងការផ្សព្វផ្សាយ គួររួមបញ្ចូលនូវយន្តការសម្រាប់ទទួលយោបល់ត្រលប់ពីក្រុមអ្នកពាក់ព័ន្ធ និងពីសាធារណៈ ព្រមទាំងសម្រាប់ការដាក់ចេញជាយោបល់ និងសំណើគម្រោង។